# ការវិភាគ ច្បាប់ថវិកាជាតិឆ្នាំ២០២៥

# និងអនុសាសន៍សម្រាប់ច្បាប់ថវិកាឆ្នាំ២០២៦ និងឆ្នាំបន្តបន្ទាប់

# មាតិកា


I. សេចក្តីសង្ខេប ......................................................3
II. ទិដ្ឋភាពទូទៅនៃថវិការដ្ឋឆ្នាំ២០២៥ ......................................11
III. ថវិកាចំណូល ថវិកាចំណាយរដ្ឋ និងឱនភាពថវិកា ..........................12
IV. បំណុលសាធារណៈ......................................................14

V. ប្រភពចំណូលថវិការដ្ឋ......................................................17
1. ចំណូលសារពើពន្ធក្នុងប្រទេស៖ ពន្ធផ្ទាល់ និងពន្ធប្រយោល........................18
2. ចំណូលពីពន្ធលើតម្លៃបន្ថែម និងពន្ធលើប្រាក់ចំណូល..............................19
3. ចំណូលពីពន្ធលើផលិតផលថ្នាំជក់ គ្រឿងស្រវឹង និងភេសជ្ជមានជាតិស្ករ និង អាហារមានកម្រិតសារជាតិចិញ្ចឹមទាប.......................................20
4. ចំណូលពីពន្ធលើអចលនទ្រព្យ......................................................22
5. ពន្ធលើប្រេងឥន្ធនៈ......................................................25

VI. ការលើកទឹកចិត្តផ្នែកពន្ធ និងការចំណាយ......................................26
VII. ការចំណាយសម្រាប់វិស័យអប់រំ សុខាភិបាល និងកិច្ចគាំពារសង្គមនៅក្រោមខ្ទង់ថវិកានៃក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ..........................28
1. វិស័យអប់រំ......................................................29
2. វិស័យសុខាភិបាល ......................................................31
3. កិច្ចគាំពារសង្គម និងការអនុវត្តថវិកាជំនួយសង្គមសម្រាប់ប្រជាពលរដ្ឋ ............32

VIII. ស្ថាប័នត្រួតពិនិត្យ......................................................35
IX. ការប្រើប្រាស់កម្ចីបរទេសទៅលើការវិនិយោគសាធារណៈសំខាន់ៗ....................37
X. តម្លាភាព និងគណនេយ្យភាពថវិកា......................................................40
XI. ការចំណាយមិនបានគ្រោងទុក (ថវិកាបម្រុង)......................................41
XII. ថវិកាប្រតិបត្តិការសម្រាប់មន្ទីររាជធានី ខេត្ត និងក្រសួងថ្នាក់កណ្តាល..................42
XIII. ថវិកាចំណាយលើលាភការ និងប្រាក់បំណាច់នៃមន្ត្រីអំណាចសាធារណៈ (គណនី ៦៤០១)......................................................43
XIV. . ការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ......................................43
XV. វេទនាសម្ព័ន្ធនៃឯកសារថវិកា......................................................46

# I. សេចក្ដីសង្ខេប៖

ក្រុមការងារថវិការបស់អង្គការសង្គមស៊ីវិល (CSO BWG) ដែលជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិលដែលធ្វើការផ្ដោតទាំងស្រុងដល់ការលើកកម្ពស់ ការបើកចំហ គណនេយ្យភាព និងការត្រួតពិនិត្យថវិកា បានធ្វើការវិភាគ និងបង្កើតឯកសារគោលជំហររួមមួយស្ដីពីការវិភាគច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ដែលត្រូវបានគេស្គាល់ជាទូទៅថាជាច្បាប់ថវិកាជាតិ។

ការវិភាគថវិកានេះមានគោលបំណងផ្ដល់នូវការយល់ដឹងទូលំទូលាយអំពីថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល និងផ្ដល់នូវធាតុចូលដ៏មានតម្លៃ និងអនុសាសន៍សំខាន់ៗដល់រាជរដ្ឋាភិបាល និងសភាកម្ពុជា។ នេះជាគំនិតផ្ដួចផ្ដើមក្នុងការស្វែងរកការកែលម្អគោលនយោបាយសារពើពន្ធដើម្បីដោះស្រាយតម្រូវការសាធារណៈកាន់តែប្រសើរឡើង ក្នុងពេលដំណាលគ្នានឹងបង្កើនតម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងថវិកា។

ការវិភាគថវិកាជាតិឆ្នាំ ២០២៥នេះ ផ្ដោតលើចំណូល ចំណាយ បំណុលសាធារណៈ ការចំណាយដែលមិនបានគ្រោងទុក និងការបែងចែកថវិកាចំពោះវិស័យសំខាន់ៗដូចជា ការអប់រំ សុខភាព និងកិច្ចគាំពារសង្គម។ ការវិភាគវាយតម្លៃការកៀរគរធនធាន ការបែងចែក និងការអនុវត្តថវិកាប្រតិបត្តិដោយប្រើប្រាស់វិធីសាស្ត្រការសិក្សាស្រាវជ្រាវ និងពិនិត្យឡើងវិញនូវឯកសារដែលមានស្រាប់ និងធ្វើការប្រៀបធៀបជាមួយនឹងច្បាប់ថវិកានាពេលកន្លមក ស្តង់ដារ ឬសូចនាករដែលទទួលស្គាល់ដោយអន្តរជាតិ និងការអនុវត្តល្អបំផុត។ ការវិភាគនេះប្រើប្រាស់អត្រាប្តូរប្រាក់ដែលកំណត់ក្នុងក្របខណ្ឌសារពើពន្ធរយៈពេលមធ្យម (២០២៥ ដល់ ២០២៧) ដើម្បីគណនាប្រាក់រៀលទៅជាប្រាក់ដុល្លារ។ លទ្ធផលនៃការវិភាគនេះមានគោលបំណងបង្ហាញពីលទ្ធផលសម្រេចបាន ការដោះស្រាយនូវការខ្វះខាតថវិកានាពេលខាងមុខ និងព្រមទាំងផ្ដល់នូវអនុសាសន៍ដើម្បីបង្កើនតម្លាភាពថវិកា គណនេយ្យភាព ការចូលរួមជាសាធារណៈ និងការត្រួតពិនិត្យថវិកានៅកម្ពុជា។

ការអនុម័តច្បាប់ថ្មីស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌសារពើពន្ធរយៈពេលមធ្យម (MTFF) ២០២៥ ដល់ ២០២៧ បង្ហាញពីវឌ្ឍនភាពដ៏សំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំថវិកាជាតិ។ ចាប់តាំងពីឆ្នាំ ២០២៤មក ក្របខ័ណ្ឌច្បាប់សំខាន់ៗទាំងនេះបានកំណត់នូវដំណាក់កាលសម្រាប់ការពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងគោលនយោបាយសារពើពន្ធរបស់កម្ពុជា។

សេចក្ដីសង្ខេបប្រតិបត្តិស្ដីពីសេចក្ដីព្រាងច្បាប់ថវិកាជាតិដែលធ្លាប់ចេញផ្សាយនាពេលកន្លងមក នៅឆ្នាំ២០២៥នេះមិនបានចេញផ្សាយឡើយ។ ការមិនចេញផ្សាយនេះអាចបង្កឡើងនូវបញ្ហាប្រឈមចម្បងចំពោះតម្លាភាពថវិកា។ សេចក្ដីសង្ខេបនេះជាធម្មតាបង្ហាញពីសូចនាករកំណើនសេដ្ឋកិច្ចសំខាន់ៗ និងគូសបញ្ជាក់ពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលសម្រាប់ការបែងចែកថវិកា ហើយសេចក្ដីសង្ខេបនេះត្រូវបានកំណត់ថាជាឯកសារបុរេថវិកាដ៏សំខាន់មួយ (pre-budget statement)។ ការមិនបាន

ចេញផ្សាយនេះធ្វើឱ្យធ្លាក់ចុះនូវការទទួលបានជាសាធារណៈនូវព័ត៌មានសំខាន់ៗសម្រាប់ការរៀបចំផែនការសារពើពន្ធប្រកបដោយតម្លាភាព និងគណនេយ្យភាព។

មតិយោបល់៖

ការធានា និងការគ្រប់គ្រងបានដោយជោគជ័យលើបំណុលសាធារណៈគឺ មានសារៈសំខាន់បំផុតចំពោះរដ្ឋាភិបាល ដើម្បីកាត់បន្ថយវត្តមាននៃរចនាសម្ព័ន្ធ និងយុទ្ធវិធីនៃបំណុលប្រកបដោយគ្រោះថ្នាក់ ព្រមទាំងទប់ស្កាត់ ចំពោះហានិភ័យនានាដល់អធិបតេយ្យភាពជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុល។ សារៈសំខាន់នៃតម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រងបំណុលសាធារណៈ ព្រមទាំងសុចរិតភាពនៃស្ថាប័នសាធារណៈ ដែលទទួលខុសត្រូវចំពោះកិច្ចការនេះ មិនអាចមិនយកចិត្តទុកដាក់បានឡើយ។ កត្តាចាំបាច់ទាំងនេះ មិនត្រឹមតែការកាត់បន្ថយហានិភ័យ ប៉ុន្តែថែមទាំងសម្រាប់ការជំរុញទំនុកចិត្តសាធារណៈផងដែរ។ នៅក្នុងបរិបទនេះ សវនករខាងក្រៅប្រកបដោយសមត្ថភាពគប្បីចូលរួមក្នុងដំណើរការដើម្បីធានាសុចរិតភាពនៃការគ្រប់គ្រងបំណុល។ សកម្មភាពគ្រប់គ្រង និងចាត់ចែងបំណុលសាធារណៈគប្បីឆ្លងកាត់សវនកម្មខាងក្រៅជាប្រចាំឆ្នាំ ដើម្បីប្រកាន់ខ្ជាប់ខ្លួននូវការអនុលោមទៅតាមស្តង់ដាដែលកំពុងមាន។ លទ្ធផល និងអនុសាសន៍ទទួលបានពីសវនកម្មនេះ គប្បីត្រូវរាយការណ៍ដល់ស្ថាប័នត្រួតពិនិត្យពាក់ព័ន្ធ។ បន្ថែមលើនេះ របាយការណ៍សំខាន់ៗពាក់ព័ន្ធនឹងសកម្មភាពគ្រប់គ្រងបំណុល គប្បីបង្ហាញផ្សាយដល់សាធារណជន។

**ខាងក្រោមគឺជាសម្រង់មតិយោបល់៖**

1. រាជរដ្ឋាភិបាលគប្បីបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីធានានូវ យុត្តិធម៌ និងតម្លាភាពនៅក្នុងការប្រមូលចំណូល ដើម្បីជៀសវាងការបាត់បង់សក្តានុពលចំណូលថវិការដ្ឋ ។ ការពង្រឹង ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដោយហ្មត់ចត់ និងដោយស្មើភាពគ្នាចំពោះអ្នកបង់ពន្ធគ្រប់រូបជាពិសេសក្រុមហ៊ុនផលិតផលគ្រឿងស្រវឹង នឹងបង្កើនចំណូលថវិការដ្ឋ និងជំរុញឱ្យមានលក្ខខណ្ឌស្មើភាពគ្នាក្នុងការប្រកួតប្រជែង។
2. រដ្ឋាភិបាលគប្បីយកពន្ធដែលមានអាត្រាកំណើនខ្ពស់ (Progressive tax rate) លើទំនិញប្រណិត និងបន្ថយពន្ធលើទំនិញសំខាន់ៗ ដើម្បីជៀសវាងបន្ទុកកាតព្វកិច្ចដល់ក្រុមងាយរងគ្រោះ។ ផលិតផលថ្នាំជក់ គ្រឿងស្រវឹង និងស្ករគួរតែត្រូវបានជាប់យ៉ាងច្រើន ខណៈដែលប្រេងឥន្ធនៈគួរតែត្រូវបានលើកលែង ដើម្បីទប់ការកើនឡើងតម្លៃទំនិញលើទីផ្សារ ដែលរងការប៉ះពាល់ពីខ្សែច្រវាក់ផ្គត់ផ្គង់។
3. ដើម្បីកាត់បន្ថយឥទ្ធិពលប្រកបដោយគ្រោះថ្នាក់របស់បារី និងគ្រឿងស្រវឹងទៅលើប្រជាពលរដ្ឋវ័យក្មេង រួមទាំងកុមារ រាជរដ្ឋាភិបាលចាំបាច់ត្រូវចេញប្រកាស សេចក្តីណែនាំ ឬអនុម័តច្បាប់គ្រប់គ្រងគ្រឿងស្រវឹងដែលបញ្ជាក់អំពីការកំណត់អាយុសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹង។

ការផ្សាយពាណិជ្ជកម្មបារី និងគ្រឿងស្រវឹងនៅតាមទីសាធារណៈគប្បីត្រូវបានហាមឃាត់ ដើម្បីកាត់បន្ថយការទទួលបាននូវព័ត៌មានទាំងនោះជាសាធារណៈពីសំណាក់សាធារណជនទូទៅ។

4. បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពិចារណាពង្រីកវិសាលភាពនៃការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធ ហើយបង្កើនអត្រាពន្ធទៅលើភេសជ្ជនាំចូលដែលមានជាតិស្ករ។ ផលិតផលដែលមានជាតិស្ករកាន់តែខ្ពស់គប្បីត្រូវបង់ពន្ធក្នុងអត្រាកាន់តែច្រើន។ រាជរដ្ឋាភិបាលក៏គប្បីគ្រប់គ្រងលើសារធាតុចិញ្ចឹមនៅក្នុងអាហារតម្លៃថ្លៃតែមានសារធាតុចិញ្ចឹមទាប ដែលមានឥទ្ធិពលអវិជ្ជមានលើកុមារនៅតាមសាលារៀន និងកុមារតូចៗផងដែរ។
5. ដើម្បីជួយសម្រាលដល់ទុកលំបាករបស់ក្រុមជនងាយរងគ្រោះស្ត្រីកុមារនៅមូលដ្ឋាន រដ្ឋាភិបាលគួរវិភាជថវិកាចំណាយប្រចាំឆ្នាំលើការងារសង្គម សេវាសាធារៈដល់ថ្នាក់ក្រោមជាតិ ឃុំសង្កាត់ (ពិសេសសេវាសុខភាព និងការអប់រំ) ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុនពីមួយឆ្នាំទៅឆ្នាំ ដើម្បីកាត់បន្ថយហានិភ័យផ្សេងៗដល់ជីវភាពរស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។
6. ដើម្បីលើកស្ទួយដល់ជនងាយរងគ្រោះ និងប្រជាពលរដ្ឋដែលប្រកបមុខរបរនេសាទដែលរស់នៅលើទឹក និងតាមមាត់បឹងទន្លេសាប និងបង្កើនជីវជាតិអាហារូបត្ថម្ភដល់កុមារ រាជរដ្ឋាភិបាលគួរលើកទឹកចិត្ត ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបែងចែកថវិកាវិនិយោគរបស់ខ្លួន (ជាពិសេសរដ្ឋបាលឃុំ សង្កាត់) សម្រាប់សកម្មភាព គ្រប់គ្រង ការពារ និងថែទាំ ប្រព័ន្ធអេកូឡូស៊ីត្រី ឱ្យបានល្អ និងមាននិរន្តរភាព។
7. ដើម្បីលើកស្ទួយដល់ជនងាយរងគ្រោះ និងប្រជាពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាល ដែលពិបាកក្នុង ការរកការងារធ្វើ រាជរដ្ឋាភិបាលគួរលើកទឹកចិត្ត ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបែងចែកថវិកាវិនិយោគរបស់ខ្លួន (ជាពិសេសរដ្ឋបាលឃុំ សង្កាត់) សម្រាប់សកម្មភាព គ្រប់គ្រង ការពារ និងថែទាំ ប្រព័ន្ធអេកូឡូស៊ីលើគោក រួមមាន សហគមន៍ព្រៃឈើ តំបន់ការពារធម្មជាតិ និងលើកទឹកចិត្តដល់សហគមន៍ទាំងអស់នោះ ឱ្យមានការរៀបចំតំបន់អេកូទេសចរណ៍ធម្មជាតិ ដើម្បីមាននិរន្តរភាពសហគមន៍។
8. បង្កើនប្រាក់ចំណូលពន្ធលើអចលនទ្រព្យ៖ កែលម្អការចុះបញ្ជីអចលនទ្រព្យ ពង្រីកមូលដ្ឋានពន្ធ ធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្លៃទីផ្សារ និងពង្រឹងការគ្រប់គ្រងតាមវិធានការបច្ចេកវិទ្យា។ ផ្តល់ការបន្ធូរបន្ថយពន្ធ ដើម្បីដោះស្រាយបញ្ហាសមធម៌សង្គម។
9. បន្តរក្សាកំណើនចំណូល៖ បង្កើនចំណូលពន្ធអចលនទ្រព្យដល់ ១%-១,៥% នៃផលិតផលក្នុងស្រុកសរុប (GDP) តាមរយៈការអនុវត្តគោលនយោបាយដែលមានប្រសិទ្ធភាព និងគួរឱ្យជឿជាក់ ដើម្បីកាត់បន្ថយផលប៉ះពាល់លើអ្នកបង់ពន្ធដែលងាយរងគ្រោះ។
10. គោលនយោបាយអត្រាពន្ធកើន៖ រក្សានូវកម្រិតចំណូលជាពេលបច្ចុប្បន្ន ប៉ុន្តែត្រូវអនុវត្តការគាំទ្រដល់អ្នកងាយរងគ្រោះ និងអនុវត្តអត្រាពន្ធកើនជាពិសេសលើដីដែលមិនបានប្រើប្រាស់ ដើម្បីបង្កើនសមធម៌ និងចំណូលជាតិ។

11. ប្រយុទ្ធប្រឆាំងអំពើពុករលួយ៖ អនុវត្តគោលនយោបាយគ្មានការអត់ឱនដើម្បីប្រឆាំងនឹងអំពើពុករលួយ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាក្នុងការគ្រប់គ្រងរដ្ឋបាលពន្ធ បង្ហាញព័ត៌មានការទូទាត់ និងបង្កើនគណនេយ្យភាព។
12. ការកែលម្អជាប្រព័ន្ធក្នុងរយៈពេលយូរ ៖ ដោះស្រាយបញ្ហាប្រឈមដូចជា នគរូបនីយកម្ម ទីផ្សារដីធ្លីក្រៅផ្លូវការ និងឧបសគ្គរារាំងផ្សេងក្នុងស្ថាប័ន តាមរយៈផ្តោតលើការអប់រំអ្នកបង់ពន្ធ ការធ្វើអនុលោមភាព និងការផ្តល់ហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្កើតប្រព័ន្ធពន្ធអចលនទ្រព្យប្រកបដោយប្រសិទ្ធភាព។
13. ចាត់វិធានការលើជនខិលខូច ដែលតែងតែឆបោក ប្រជាពលរដ្ឋស្លូតត្រង់ និងមានជីវភាពកម្រិតធម្យម និងខ្ពស់ ក្នុងការវិនិយោគលើអចលទ្រព្យរបស់ពួកគាត់។
14. ពង្រឹងសិទ្ធិលំនៅដ្ឋានរបស់ប្រជាពលរដ្ឋឲ្យកាន់តែមានតម្លាភាព គណនេយ្យភាព ដោយមិនមិនការរំលោភសិទ្ធិ និងការគៀបសង្កត់ផ្សេងៗ
15. រដ្ឋាភិបាលអាចបន្ធូរបន្ថយការកើនឡើងថ្លៃប្រេងដោយការកាត់បន្ថយពន្ធលើប្រេងសាំង តាមរយៈការកាត់បន្ថយអត្រាពន្ធលើតម្លៃបន្ថែមពី ១០% ទៅ ៥% វិធានការនេះនឹងជួយសំរាលបន្ទុកដល់អ្នកប្រើបានប្រមាណ ១៥០ លានដុល្លារ នឹងកាត់បន្ថយការចំណាយលើទំនិញ សេវាកម្ម និងផលិតកម្ម ដែលផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច។
16. ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល ស្នើរាជរដ្ឋាភិបាលបោះពុម្ពផ្សាយជាប្រចាំនូវព័ត៌មានទាក់ទងនឹងនឹងការវាយតម្លៃលើប្រសិទ្ធភាពនៃការលើកទឹកចិត្តផ្នែកពន្ធ ជាពិសេសព័ត៌មានទាក់ទងនឹងការចំណាយតាមរយៈការអនុវត្តការលើកទឹកចិត្តនេះ និងផលជះត្រឡប់នៃឥរិយាបទអ្នកវិនិយោគ។
17. រដ្ឋាភិបាលត្រូវបើកចំហព័ត៌មានថវិកាជាសាធារណៈ លើបណ្តាញសង្គមរបស់រដ្ឋ និងជូនដំណឹងដល់ប្រជាពលរដ្ឋជាប្រចាំ ដើម្បីលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន និងការចូលរួមមតិយោបល់កែលម្អផ្សេងៗ កាន់តែធ្វើរដ្ឋាភិបាលមានធាតុចូលក្នុងការដោះស្រាយបញ្ហារាំងស្ទះទាំងឡាយប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងប្រយោជន៍រួមរបស់ប្រជាពលរដ្ឋរបស់ខ្លួន។

18. ដើម្បីជំរុញការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព រដ្ឋាភិបាលគួរតែផ្តល់អាទិភាពដល់ការវិភាជថវិកាសម្រាប់ការអប់រំ សុខភាពសាធារណៈ និងកិច្ចគាំពារសង្គម ស្របពេលជាមួយកែលម្អការផ្តល់សេវាសាធារណៈផងដែរ។ ថវិកាសុខភាពសាធារណៈអាចត្រូវបានធ្វើឱ្យប្រសើរដោយការលើកទឹកចិត្តដល់កិច្ចសហការរវាងមណ្ឌលសុខភាព និងមេឃុំ/សង្កាត់ ដើម្បីបង្កើនសេវា និងបរិក្ខារសុខាភិបាលនៅតាមមូលដ្ឋាន។ ការដោះស្រាយវិសមភាពនៅតាមជនបទ ទាមទារការកៀរគរធនធានមនុស្ស និងធានាឱ្យមានលទ្ធភាពទទួលបានសេវាប្រកបដោយសមធម៌។ កម្មវិធីកសាងសមត្ថភាពគួរផ្តោតលើការលើកកម្ពស់សុចរិតភាព គណនេយ្យភាព និងអភិបាលកិច្ច

ប្រកបដោយក្រមសីលធម៌។ ម៉្យាងវិញទៀត ដើម្បីកាត់បន្ថយការចំណាយសុខភាពប្រជាជនលើជម្ងឺទូទៅឬជម្ងឺមិនឆ្លង រដ្ឋាភិបាលគួរពិចារណាក្នុងការចំណាយថ្លៃពិនិត្យ សុខភាពដល់ប្រជាជនទូទៅចាប់ពីអាយុ ៣៥ ដល់ ៥០ឲ្យបាន២ដងក្នុងមួយឆ្នាំ ដើម្បីធានាថា ការថែទាំសុខភាពមុនឈានទៅដល់ការចំណាយច្រើន។

**សម្រាប់វិស័យអប់រំ**

19. រាជរដ្ឋាភិបាលកម្ពុជា គួរវិភាជថវិកាជាបន្តបន្ទាប់ដល់ចំនួន ២០% នៃចំណាយថ្នាក់ជាតិ លើវិស័យអប់រំ ដូចដែលបានសន្យានៅឆ្នាំ ២០២១។ ទន្ទឹមនឹងនេះ គប្បីខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពខុសគ្នានៃគុណភាពរវាងសាលារៀនឯកជន និងសាលារៀនរដ្ឋនៅទូទាំងប្រទេស។ ការបង្កើនថវិកានេះគប្បីត្រូវបានវិនិយោគលើការពង្រឹងគុណភាពនៃការអប់រំ (ទាំងគុណភាពនៃការរៀនសូត្រ និងគុណភាពនៃការបង្រៀន) ជាពិសេស ការអប់រំមូលដ្ឋានរយៈពេលប្រាំបួនឆ្នាំ។ កុមារគប្បីទៅរៀននៅសាលារៀនល្អៗនោះគឺ "សាលារៀនគំរូ" នៅក្នុងទីតាំងដែលពួកគេអាចធ្វើដំណើរទៅដល់បាន ហេតុនេះ រាជរដ្ឋាភិបាលគប្បីវិនិយោគលើការគាំទ្រដល់សាលារៀននៅតាមទីជនបទ ដើម្បីឱ្យក្លាយទៅជា "សាលារៀនគំរូ"។

20. ធានាបាននូវលទ្ធភាពទទួលបានការអប់រំរយៈពេលប្រាំបួនឆ្នាំសម្រាប់កុមារទាំងអស់ រួមទាំងមានការគាំទ្របន្ថែមសម្រាប់ក្រុមជួបការលំបាកក្រោយជំងឺកូវីដ-១៩។

21. បែងចែកថវិកាសម្រាប់ការជួសជុលសាលារៀន ហេដ្ឋារចនាសម្ព័ន្ធ សៀវភៅសិក្សា និងការកែលម្អបច្ចេកវិទ្យា។

22. ការពង្រឹងការបណ្តុះបណ្តាលគ្រូបង្រៀនដោយប្រើប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់នាយកសាលា និងគ្រូបង្រៀន។

23. កៀរគរធនធាន និងភាពជាដៃគូជាមួយសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍ ដើម្បីបង្កើនគុណភាពអប់រំ។

24. ការលើកកម្ពស់តម្លាភាព និងការផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអំឡុងពេលផ្ទេរមុខងារ និងធនធាន។

សម្រាប់វិស័យកិច្ចគាំពារសង្គម៖

25. រាជរដ្ឋាភិបាលគប្បីពង្រីកវិសាលភាព និងសមធម៌នៃគោលនយោបាយកិច្ចគាំពារសង្គម ដើម្បីគ្របដណ្តប់ទៅដល់ក្រុមងាយរងគ្រោះ ដូចជាអ្នកទាំងឡាយដែលធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មនុស្សចាស់ ជនមានពិការភាព និងសហគមន៍ជនជាតិដើម។ គោលនយោបាយ

ទាំងនេះគប្បីចាត់អាទិភាពលើសន្តិសុខប្រាក់ចំណូល សម្រាប់យុវជន ពលករចំណាកស្រុក និងជនអត់ការងារធ្វើ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពង្រីកការគ្របដណ្តប់នៃកិច្ចគាំពារសង្គមទៅដល់សហគ្រាសមីក្រូខ្នាតតូច និងមធ្យម (MSMEs) និងកសិករម្ចាស់ចម្ការតូចៗនៅក្នុងវិស័យនានា ដូចជា ចម្ការកៅស៊ូ អំពៅ ចេក និងវិស័យកសិកម្មផ្សេងទៀត។ ការតម្រូវឲ្យបានទាំងស្រុងអំពីការពង្រឹងការអនុវត្តកាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម និងនិយោជក ចំពោះការផ្តល់នូវរបបសន្តិសុខសង្គមដល់និយោជិត តាមរយៈការដាក់ចេញនូវការអនុវត្តច្បាប់កាន់តែម៉ឺងម៉ាត់ពីសំណាក់ មន្ត្រី ប.ស.ស និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងធានាបានថាបុគ្គលទាំងនេះអាចទទួលបានអត្ថប្រយោជន៍ពីវិធានការកិច្ចគាំពារសង្គម។

26. វិភាជថវិកា ៥,១% នៃ GDP ដល់កិច្ចគាំពារសង្គម តាមអនុសាសន៍សកលសម្រាប់ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។
27. ការបង្កើនថវិកាសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ចាស់ជរា និងជនពិការ រួមទាំងការពិនិត្យឡើងវិញនូវគោលនយោបាយសោធននិវត្តន៍ និងការបង្កើតមណ្ឌលថែទាំសុខភាព។
28. ការពង្រីកអត្ថប្រយោជន៍ថែទាំសុខភាពរបស់បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីបង្កើនគុណភាពសេវាកម្ម ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា និងការជឿទុកចិត្ត។
29. សាកល្បងគម្រោងវិភាគទាន និងឧបត្ថម្ភធនសម្រាប់កម្មករក្រៅផ្លូវការ និងកសិករខ្នាតតូច ដើម្បីបង្កើនបរិយាប័ន្ន និងនិរន្តរភាព។
30. ផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្មរបស់ បេឡាជាតិរបបសន្តិសុខសង្គម និងមូលនិធិជំនួយសង្គមជាតិ ដើម្បីធានាតម្លាភាព។
31. កំណត់អង្គភាពស្ថាប័នដែលទទួលខុសត្រូវចំពោះគោលនយោបាយគាំពារសង្គម ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកាក្រោមគណនីរង ៦២០២៨ ដែលគាំទ្រដល់ប្រយោជន៍សាធារណៈ។

32. វាយតម្លៃ និងធ្វើវិសោធនកម្មប្រចាំលើការងារចំណាយថវិកា របស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យមានប្រសិទ្ធភាព និងតម្លាភាព គណនេយ្យភាព កាត់បន្ថយអំពើរពុករលួយ។
33. ស្ថាប័ននីតិប្បញ្ញត្តិដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យការចំណាយ និងចំណូលសាធារណៈ។ CSO BWG ផ្តល់អនុសាសន៍ឱ្យមានការចូលរួមរបស់ស្ថាប័នរដ្ឋសភាឲ្យកាន់តែពេញលេញក្នុងវដ្តថវិកាទាំងមូល - ពីការកសាងផែនការថវិកា រហូតដល់ការអនុវត្ត និងការត្រួតពិនិត្យ ជាជាងផ្តោតតែលើសវនកម្មក្រោយពេលអនុវត្តចប់។
34. ដើម្បីបង្កើនការធ្វើសេចក្តីសម្រេចប្រកបដោយការយល់ដឹង តាមរយៈការបង្កើតការិយាល័យថវិការបស់សភា នៅព្រឹទ្ធសភា និងរដ្ឋសភាដែលមានធនធានគ្រប់គ្រាន់ដើម្បីឱ្យការិយាល័យនេះបំពេញមុខងារប្រកបដោយប្រសិទ្ធភាព។

35. រដ្ឋាភិបាលគួរពង្រឹង រឹតបន្តឹងលើប្រព័ន្ធត្រួតពិនិត្យការចំណាយថវិកាសូមឲ្យមានតម្លាភាព និងមានវិធានការលើមន្ត្រីខិលខូច ដោយប្រើប្រាស់ច្បាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ។

36. ការប្រើប្រាស់ប្រាក់កម្ចីប្រកបដោយប្រសិទ្ធភាពគឺចាំបាច់ដើម្បីជៀសវាងការជាប់បំណុល និងធានាបាននូវអត្ថប្រយោជន៍រយៈពេលវែង។ ការវិនិយោគគួរតែផ្តល់អាទិភាពដល់គម្រោងដែលអាចសម្រេចបានផ្នែកសេដ្ឋកិច្ច លើកកំពស់សុខុមាលភាពសង្គម និងគាំទ្រដល់ក្រុមដែលងាយរងគ្រោះរួមមានស្ត្រី កុមារ និងមនុស្សចាស់។ រាជរដ្ឋាភិបាលគប្បីប្រើប្រាស់កម្ចីជាលក្ខណៈយុទ្ធសាស្ត្រ ដើម្បីបង្កើតភាពរីកចម្រើនរយៈពេលវែងលើផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ គឺជារឿងសំខាន់ ដើម្បីពង្រឹងការភ្ជាប់ទំនាក់ទំនង និងភាពប្រកួតប្រជែងសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយបន្ទុកចំណាយផ្នែកភស្តុភារ និងផលិតកម្ម។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគប្បីកើតឡើងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងគម្រោងនៅថ្នាក់ឃុំសង្កាត់ ដូចជា បណ្តាញដឹកជញ្ជូន ការផ្គត់ផ្គង់ទឹក អគ្គិសនី និងការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត។

37. រាជរដ្ឋាភិបាលគប្បីអនុវត្តគោលនយោបាយដែលមិនអត់ឱនចំពោះអំពើពុករលួយ គឺ ចាំបាច់នៅក្នុងការគ្រប់គ្រងថវិកាសាធារណៈ។ តម្លាភាពដំណើរការលទ្ធកម្មសាធារណៈ សវនកម្មឯករាជ្យ និងការបង្ហាញជាសាធារណៈនូវកិច្ចសន្យា កិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងសាធារណៈ និង BOT គឺចាំបាច់ដើម្បីធានាឱ្យមានគណនេយ្យភាព និងការចូលរួមជាសាធារណៈ។

38. រដ្ឋាភិបាលគួរមានការប្រុងប្រយ័ត្នខ្ពស់ចំពោះកម្ចីណាដែលបានផ្តល់ហានិភ័យដល់ប្រទេសជាតិទាំងមូល និងមានផលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរបស់ខ្លួន និងប៉ាន់ប្រមាណសមត្ថភាពកម្រិតចំណូលជាតិប្រចាំឆ្នាំ និងចំណាយប្រចាំឆ្នាំ និងការសងត្រឡប់ទៅឲ្យគេវិញ។

39. រដ្ឋាភិបាលគួរយកកម្ចីណាដែលជួយសម្រាលដល់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ផ្នែកសេដ្ឋកិច្ច ឬចរន្តសេដ្ឋកិច្ចដែលប្រជាពលរដ្ឋរបស់ខ្លួនកំពុងអាស្រ័យផល ពឹងផ្អែកលើសេដ្ឋកិច្ចរបស់ពួកគាត់ប្រចាំថ្ងៃ ជាឧទាហរណ៍ផ្នែកកសិកម្មជាដើម។

40. រដ្ឋាភិបាលគួរពិចារណាលើការសាងសង់ផ្លូវ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើយ៉ាងណាកុំឲ្យមានការចំណាយប្រចាំឆ្នាំរហូត និងបង្កើនគុណភាពផ្លូវឲ្យបានរឹងមាំ យូរអង្វែង កុំឲ្យថវិកាជាតិរវល់តែគិតលើហេដ្ឋារចនាសម្ព័ន្ធប្រចាំ នោះថវិកាជាតិនិងមិនការអភិវឌ្ឍ អាទិភាពផ្សេងទៀតបានច្រើនទៀតទេនៅឆ្នាំបន្ទាប់។

41. រដ្ឋាភិបាលចាំបាច់ បង្កើតវេទិកាអនឡាញ ដើម្បីប្រមូល និងបញ្ចូលមតិសាធារណជនទៅក្នុងគោលនយោបាយសារពើពន្ធ និងការកសាងផែនកាថវិកា ហើយជំរុញឱ្យមានមានតម្លាភាព និងរួមបញ្ចូលនូវធាតុចូលកាន់តែប្រសើរឡើងក្នុងដំណើរការថវិកា។

42. រដ្ឋាភិបាលចាំបាច់បើកចំហព័ត៌មានថវិកា និងព័ត៌មានលទ្ធកម្មសាធារណៈ ប្រកបដោយតម្លាភាព គណនេយ្យភាព តាមរយៈប្រព័ន្ធអនឡាយ ឬការផ្សព្វផ្សាយជាសាធារណៈផ្សេងៗ ដើម្បីឲ្យប្រជាពលរដ្ឋបានដឹង និងចូលរួមធ្វើសេចក្តីសម្រេចចិត្ត មតិកែកម្មលើចំណូលចំណាយ សាធារណៈផ្សេងរបស់រដ្ឋ ដើម្បីកាត់បន្ថយចំណាយណាដែលឥតប្រយោជន៍ បង្កើនចំណាយណាដែលមានប្រយោជន៍សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរបស់ខ្លួន កាន់តែប្រសើរ

43. ថវិកាមិនបានគ្រោងទុកប្រចាំឆ្នាំរបស់កម្ពុជា គប្បីត្រូវបានកំណត់នៅត្រឹម ៣% ក្នុងមួយឆ្នាំដែល ហើយរៀបវិភាជកាន់តែច្រើនដល់វិស័យសំខាន់ៗដូចជា សុខាភិបាល ការអប់រំ កិច្ចគាំពារសង្គម និងថវិកាអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។

44. រាជរដ្ឋាភិបាលគប្បីបង្កើនចំណែកនៃថវិកា ដែលត្រូវវិភាជទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិដោយបង្កើនទៅដល់ ៣០% នៃការចំណាយប្រចាំឆ្នាំរបស់រដ្ឋ ដែល១០% គប្បីត្រូវវិភាជសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំណែកឯ ១០% ទៀតគប្បីត្រូវវិភាជទៅដល់រដ្ឋបាលឃុំ/សង្កាត់។ ការវិភាជថវិកាបន្ថែម នេះនឹងផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ជាតិទាំងនេះនៅក្នុងការបំពេញភារកិច្ចជាកាតព្វកិច្ចរបស់ពួកគាត់ េប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយភាពខ្វះខាត ក្នុងការចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល និងមុខងារថ្មីៗ។

45. រាជរដ្ឋាភិបាលគប្បីតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាពនូវការអនុវត្តអនុក្រឹត្យលេខ ១៥២ និង១៥៣ ដែលបានណែនាំរដ្ឋបាលឃុំសង្កាត់ និងក្រុង ស្រុកខណ្ឌវិភាជថវិកាដល់កិច្ចការសង្គមកិច្ច ការពារធនធានធម្មជាតិ និងបរិស្ថាន ព្រមទាំងការសម្របខ្លួនទៅតាមការប្រែប្រួលអាកាសធាតុ។

46. រាជរដ្ឋាភិបាលគប្បីពង្រឹងសមត្ថភាពរបស់មន្ត្រីក្នុងការគ្រប់គ្រង និងអនុវត្តថវិកាឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈកម្មវិធីកសាងសមត្ថភាពដែលឆ្លើយតបទៅនឹងតម្រូវការ។ កម្មវិធីទាំងនេះគប្បីបញ្ចូលវដ្តនៃការគ្រប់គ្រងថវិកា ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀនសូត្រ (MEL) រួមជាមួយនឹងសវនកម្មផ្ទៃក្នុង។

47. រាជរដ្ឋាភិបាលគប្បីបង្កើត និងអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធសវនកម្មផ្ទៃក្នុង សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងពេលតំណាលគ្នានេះដែរ រដ្ឋាភិបាលគប្បីធានានូវការបំពេញមុខងារ តួនាទីត្រួតពិនិត្យពេញលេញ និងប្រកបដោយប្រសិទ្ធភាពទៅលើក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនៅក្នុងការពិនិត្យតាមដានវឌ្ឍនភាពនៃអនុវត្តថវិកា។

48. រាជរដ្ឋាភិបាលគប្បីសកម្មក្នុងការលើកទឹកចិត្តការចូលរួមរបស់ប្រជាពលរដ្ឋ និងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការរៀបចំថវិកា ដើម្បីជំរុញភាពជាម្ចាស់របស់ប្រជាពលរដ្ឋទៅលើផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគាត់។

49. រាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គប្បីពង្រឹងការយល់ដឹងជាសាធារណៈអំពីថវិកាសាធារណៈ និងតម្លាភាពនៃការអនុវត្តថវិកា ជាពិសេសបើកចំហរព័ត៌មានលទ្ធកម្មសាធារណៈ និងលើកកម្ពស់ការចូលរួម តាមរយៈការបង្កើតក្របខណ្ឌ និងទម្រង់ជាស្តង់ដាសម្រាប់ច្បាប់ទាំងពីរប្រភេទនេះ ដែលសម្របសម្រួលដល់ការផ្ទៀងផ្ទាត់ និងការពិនិត្យមើលថវិកាឡើងវិញ។

## II. ទិដ្ឋភាពទូទៅនៃថវិការដ្ឋឆ្នាំ២០២៥៖

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥ ដែលមាន ០៦ជំពូក និង ១៥មាត្រា មានគោលបំណង ធានានូវនិរន្តរភាពរបស់រដ្ឋ និងអនុវត្តគោលនយោបាយអាទិភាពសំខាន់ៗ ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់ប្រទេសកម្ពុជា[1]។ ទោះបីជាមានការប្រឈមផ្នែកសេដ្ឋកិច្ចក៏ដោយ ក្របខណ្ឌសារពើពន្ធរយៈពេលមធ្យម (MTFF) ២០២៥ ដល់២០២៧ ព្យាករណ៍កំណើន ផ.ស.ស (GDP) មានចំនួន ៦,៣% ក្នុងឆ្នាំ ២០២៥ ដែលឈានដល់ ២០៩.១៦៣ ពាន់លានរៀល (៥១,៣៩៨ ពាន់លានដុល្លារ)[2]។ កំណើននេះ ខ្ពស់ជាង ផ.ស.ស ដែលបានប៉ាន់ប្រមាណឆ្នាំ ២០២៤ ដែលមានត្រឹមតែ ១៩២.៩៥៧ ពាន់លានរៀល (៣៥,១៧៦ ពាន់លានដុល្លារ)[3]។

ច្បាប់ថវិកាជាតិឆ្នាំ ២០២៥ បានគ្រោងថវិកាចំនួន ៣៧.៩៥០.៣៨៥ លានរៀល (៩,៣២៧ពាន់លានដុល្លារ) សម្រាប់ចំណាយរដ្ឋ ដែលកើនឡើង ២,២៦% ធៀបនឹងឆ្នាំ ២០២៤។ គម្រោងនៃថវិកាចំណាយនេះមានចំនួនប្រមាណ ១៨,១៤% នៃផ.ស.សសរុប។ ៦៩%នៃថវិកានេះ គឺគ្រោងសម្រាប់ចំណាយចរន្ត (២៦.០៥៤.០១៩លានរៀល ឬ៦.៤០៣ លានដុល្លារ) ហើយ ៣១% ត្រូវបាន គ្រោងសម្រាប់ចំណាយមូលធន (១១.៨៩៦.៣៦៦លានរៀល ឬ២.៩២៤លានដុល្លារអាមេរិក) ហើយការបែងចែកនេះ បើគិតជាភាគរយ គឺស្រដៀងគ្នាទៅនឹងឆ្នាំ ២០២៤។

ថវិកាឆ្នាំ ២០២៥ បង្ហាញអំពីការបន្តពុះពាររបស់កម្ពុជានូវបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចទាំងខាងក្នុង និងខាងក្រៅប្រទេសដែលជាផលប៉ះពាល់ពីនៃជម្លោះសកលលោក និងការធ្លាក់ចុះនៃវិស័យសំខាន់ៗដូចជា ទេសចរណ៍ អចលនទ្រព្យ និងវាយនភណ្ឌ។ សម្ពាធពីខាងក្រៅ ដូចជាឥទ្ធិពលលើតម្លៃប្រេងសាំង[4]ដែលបង្កដោយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងផលប៉ះពាល់សេដ្ឋកិច្ចដែលបង្កដោយជម្លោះអ៊ីស្រាអែល-ប៉ាឡេស្ទីន ធ្វើឱ្យស្ថានភាពកាន់តែស្មុគស្មាញ[5]។ លើសពីនេះ ការធ្លាក់ចុះនៃសេដ្ឋកិច្ច

[1] Press release by Government's Spokesman Unit issued on 25 October 2024
[2] Ibid
[3] Executive summary for budget law 2024
[4] https://www.imf.org/en/Publications/fandd/issues/2022/03/the-long-lasting-economic-shock-of-war
[5] https://www.bloomberg.com/news/features/2023-10-12/israel-hamas-war-impact-could-tip-global-economy-into-recession

របស់ប្រទេសចិន ធ្វើឱ្យបញ្ហាប្រឈមរបស់កម្ពុជាកាន់តែធ្ងន់ធ្ងរឡើង ដោយសារប្រទេសទាំងពីរមានទំនាក់ទំនងពាណិជ្ជកម្មដ៏សំខាន់ ជាពិសេសក្នុងវិស័យអចលនទ្រព្យ និងទេសចរណ៍[6]។

ចំណូលថវិការដ្ឋឆ្នាំ ២០២៥ ត្រូវបានព្យាករណ៍ថាមានចំនួន ៣១.៥៩៨.០៧៣ លានរៀល (៧.៧៦៥ លានដុល្លារ) ដែលថយចុះចំនួន ២,៨% ធៀបនឹងឆ្នាំ ២០២៤។ ទោះបីជា កំណើនចំណូលថវិការដ្ឋនៅមានកម្រិតក៏ដោយ ក៏រាជរដ្ឋាភិបាលបានបង្កើនការថវិកាចំណាយរបស់ខ្លួនចំនួន ២,២៦% ហើយអតិផរណាត្រូវបានព្យាករណ៍មានអាត្រាចំនួន២,៥%។ នេះបង្ហាញពីជំហរគោលនយោបាយសារពើពន្ធដែបុរេសកម្មដែលមានគោលបំណងឆ្លើយតបនឹងអតិផរណា ជាជាងការពង្រីកសក្តានុពលទីផ្សារសេដ្ឋកិច្ច។

ឱនភាពថវិកាសម្រាប់ឆ្នាំ ២០២៥ គ្រោងនឹងកើនឡើងដល់ ១៦,៧៤% ដែលជាការកើនឡើងចំនួន ០៥ពិន្ទុជាភាគរយ បើប្រៀបធៀបនឹងឆ្នាំ២០២៤ ដែលនេះបង្ហាញពីការពឹងផ្អែករបស់ រដ្ឋាភិបាលលើការបង្កើនការចំណាយដើម្បីដោះស្រាយបញ្ហាប្រឈមសេដ្ឋកិច្ចចំពេលថវិកាចំណូលមាននៅមានកម្រិត។ ច្បាប់ថវិកាបង្ហាញថា ថវិកាទូទាត់បំណុលមិនត្រូវបានរាប់បញ្ចូលក្នុងចំណាយមូលធនឡើយ។

## III. ថវិកាចំណូល ថវិកាចំណាយរដ្ឋ និងឱនភាពថវិកា៖

ក្នុងរយៈពេលបីឆ្នាំកន្លងមក ការចំណាយរដ្ឋរបស់កម្ពុជាមានការប្រែប្រួលមានកំនើន និងធ្លាក់ចុះ ។ នៅឆ្នាំ២០២៥ មានការកើនឡើងវិញបន្តិចដែលមានអត្រាប្រមាណ ២,២៦% បើធៀបនឹងឆ្នាំ ២០២៤ ប៉ុន្តែកំណើននេះនៅមិនទាន់ដល់ចំនួនថវិកាចំណាយឆ្នាំ២០២៣ឡើយ។

ឯកតា លានរៀល

| សេចក្តីបរិយាយ | 2024 | 2025 |
|---|---|---|
| ចំណាយសរុបថវិការដ្ឋ | 37,110,404.00 | 37,950,385.00 |
| ចំណូលសរុបថវិការដ្ឋ | 32,508,940.00 | 31,598,073.00 |
| ឱនភាពថវិកា | (4,601,464.00) | (6,352,312.00) |
| ភាគរយឱនភាពថវិកា | 12.40% | 16.74% |
| ការខ្ចីពីបរទេស | 3,464,464.00 | 3,877,330.00 |
| ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ | 697,000.00 | 1,974,982.00 |
| ការបោះផ្សាយមូលបត្ររដ្ឋ | 440,000.00 | 500,000.00 |
| ការខ្ចីពីបរទេសសម្រាប់ទូរទាត់បំណុលសាធារណៈ | 2,114,685.00 | 2,428,140.00 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០២៤ ដល់ ២០២៥

នៅឆ្នាំ ២០២៥ ចំណូលថវិការដ្ឋត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះ ២,៨០% មកនៅត្រឹមចំនួន ៣១.៥៩៨.០៧៣ លានរៀល (៧,៧៧ ពាន់លានដុល្លារ)។ ក្នុងឆ្នាំ ២០២៤ ចំណូលថវិការដ្ឋមានចំនួន៣២.៥០៨.៩៤០លានរៀល។ ការធ្លាក់ចុះនេះ នាំអោយមានឱនភាពថវិកាធំជាងឆ្នាំ២០២៤ ដែលស្មើនឹងប្រមាណ ១៦,៧៤ % (៦.៣៥២.៤២០ លានរៀល) ខណៈដែលឆ្នាំ២០២៤ ឱនភាពថវិកាមានប្រមាណ ១២,៤០%។ ការថយចុះនៃថវិកាចំណូលរដ្ឋ នេះបណ្តាលមកពីការថយចុះនៃចំណូលពន្ធ ទោះបីជាមានការបន្តកើនឡើងនូវចំណូលមិនមែនសារពើពន្ធជាបន្តបន្ទាប់ចំនួន ២៩,៤៧% ក្នុងឆ្នាំ ២០២៤ និង១៩,២៦

6 https://time.com/6308850/china-economy-slowdown-global-effects/

ក្នុងឆ្នាំ ២០២៥។ ចំណូលថវិកាចរន្តសម្រាប់ឆ្នាំ ២០២៥ ត្រូវបានគ្រោង ឈានដល់ ៣០.៣៨៨.៨៧៧ លានរៀល ដែលមានការថយចុះចំនួន ២,៩២% ធៀបនឹងឆ្នាំ២០២៤។

នៅឆ្នាំ ២០២៥ ការចំណាយមូលធនត្រូវបានគ្រោងកើនឡើង ៥,៩៧% ខណៈពេលដែលការចំណាយចរន្តត្រូវបានគ្រោងកើនឡើងតិចតួច គឺ 0,៦៦% បើធៀបនឹងឆ្នាំ ២០២៤។ ច្បាប់នេះបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការវិភាជហិរញ្ញប្បទានក្នុងស្រុកចំនួន ៥.០២៥.០៩៦ លានរៀលសម្រាប់គម្រោងវិនិយោគសាធារណៈក្នុងឆ្នាំ ២០២៥ ដែលរក្សាបាននូវការវិភាជថវិកាដូចគ្នានឹងឆ្នាំ២០២៤។ បើធៀបនឹងឆ្នាំ២០២៣ ការវិភាជនេះធ្លាក់ចុះ ៣១%។ ទោះជាយ៉ាងណាក៏ដោយ ថវិកាសម្រាប់គម្រោងវិយោគផ្ទាល់ដោយរាជរដ្ឋាភិបាល នឹងធ្លាក់ចុះយ៉ាងខ្លាំងប្រហែល ៣៨% ពី ២.៩៨៧.៧៥១ លានរៀលក្នុងឆ្នាំ ២០២៤ ដល់ ១.៨៥៣.៤៥៧ លានរៀលក្នុងឆ្នាំ ២០២៥។

គម្រោងវិនិយោគសាធារណៈដោយផ្ទាល់របស់រដ្ឋាភិបាល ជាធម្មតាត្រូវប្រើប្រាស់ថវិកាចំណូលក្នុងប្រទេស។ ចំណូលចរន្តសម្រាប់ឆ្នាំ ២០២៥ ដែលត្រូវបានគ្រោងធ្លាក់ចុះបន្តិច បានជះឥទ្ធិពលដល់ថវិកាសម្រាប់គម្រោងវិនិយោគសាធារណៈ ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលបានជ្រើសរើសពឹងផ្អែកខ្លាំងលើហិរញ្ញប្បទានបរទេសសម្រាប់ការចំណាយមូលធន។ ច្បាប់នេះបញ្ជាក់បន្ថែមទៀតអំពីបំណងរបស់រដ្ឋាភិបាលក្នុងការវិភាជថវិកាប្រមាណ ៣១% នៃការចំណាយរបស់រដ្ឋទៅជាចំណាយមូលធន។

រដ្ឋាភិបាល ក្នុងឆ្នាំ២០២៥នេះ រក្សានូវការវិភាជចំណាយចរន្ត ដោយបែងចែកជាការចំណាយលើបុគ្គលិក និងមិនមែនបុគ្គលិក។ ចំណាយបុគ្គលិកកើនឡើងចំនួន ៣,៦៦% កើនឡើងពី ១១.៧៩៤.៧៨០ លានរៀលក្នុងឆ្នាំ ២០២៤ ដល់ ១២.២២៦.៤២៥លានរៀល។ ការកើនឡើងនេះសម្រាប់គាំទ្រដល់ការដំឡើងប្រាក់បៀវត្សដល់មន្ត្រីរាជការ បើទោះជាមានការថយចុះនូវចំនួនមន្ត្រីរាជការ។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងចំណាយបន្ទុកបុគ្គលិកបង្កើតបន្ទុកនៃការដាក់កម្រិតចំនួនថវិកាចំណាយក្រៅបន្ទុកបុគ្គលិក ដែលមានសារៈសំខាន់សម្រាប់ប្រតិបត្តិការ និងអនុវត្តកម្មវិធីរបស់ក្រសួងនីមួយៗ។ ជាមួយនឹងការធ្លាក់ចុះនៃចំណូលថវិកាចរន្តឆ្នាំ ២០២៥ ការចំណាយក្រៅបន្ទុកបុគ្គលិកនឹងថយចុះចំនួន១,៩៣% ពី ១៣.៥៥០.៨៧១ លានរៀលក្នុងឆ្នាំ ២០២៤ មក ១៣.២៨៩.៦៨៧ លានរៀល។

រដ្ឋាភិបាលព្យាករនូវអតិរេកចរន្តចំនួន ៣.៩៦៧.៥៩៤ លានរៀល សម្រាប់ឆ្នាំសារពើពន្ធឆ្នាំ ២០២៥ ។ ទោះជាយ៉ាងណាក៏ដោយ ថវិកាអតិរេកចរន្តនេះថយចុះគួរឱ្យកត់សម្គាល់ចំនួន ២១% បើធៀបនឹងឆ្នាំ ២០២៤ ពីចំនួន ៥.០៣០.៦៣៩លានរៀល មកចំនួន ៣.៩៦៧.៥៩៤ លានរៀល។ ការថយចុះនេះស្មើនឹង 0.៧៥ ពិន្ទុភាគរយ នៃផ.ស.ស (GDP)។

ប្រឈមមុខនឹងការថយចុះនៃការប្រមូលចំណូល រដ្ឋាភិបាលនឹងមានឱនភាពថវិកាចំនួន ៨.៧៨០.៤៥២ លានរៀល (២.១៥៧,៨៨លានដុល្លារ) ស្មើនឹង ៤,២០% នៃផលិតផលក្នុងស្រុកសរុប (GDP) ដើម្បីទ្រទ្រង់លើការខ្វះខាតចំនួន១៦,៧៤% នៃថវិកាចំណាយរដ្ឋសរុប រួមទាំងការទូទាត់បំណុលសាធារណៈចំនួន ៥៩៦,៧៤ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៥។

គេសង្កេតឃើញថា រដ្ឋាភិបាលជាធម្មតាដោះស្រាយបញ្ហាឱនភាពថវិកាតាមរយៈការទទួល បានការទ្រទ្រង់ថវិកាពីប្រភពមួយចំនួន រួមមានការខ្ចីប្រាក់ពីបរទេស ជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ ការបោះផ្សាយលក់មូលប័ត្រសាធារណៈ និងការដកប្រាក់បញ្ញើរបស់រដ្ឋាភិបាល។ ជាក់ស្តែង ដើម្បីទប់ទល់នឹងឱនភាពនៃការចំណាយថវិការដ្ឋឆ្នាំ ២០២៥ រដ្ឋាភិបាលគ្រោងនឹងខ្ចីប្រាក់ជាបំណុលសាធារណៈចំនួន ៣% នៃផលិតផលក្នុងស្រុកសរុប (១.៥៤៩,៦៣ លានដុល្លារ) ពីដៃគូទ្វេភាគី និងពហុភាគីបរទេស ហើយគ្រោងនឹងទទួលបានថវិកាបន្ថែមចំនួន ៤៨៥,៣៧ លានដុល្លារ (0,៩៤% នៃ GDP) ពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ។ ហើយមូលបត្របំណុលសាធារណៈរបស់រដ្ឋចំនួន ១២២ លានដុល្លារនឹងបោះផ្សាយលក់ផងដែរ ឱនភាពថវិកាបានកើនឡើងពី ១២,៤0% ក្នុងឆ្នាំ ២០២៤ ដល់ ១៦,៧៤% ក្នុងឆ្នាំ ២០២៥។ រដ្ឋាភិបាលក៏មានតម្រូវការគណទានចំនួន៥៩៦,៧៤ លានដុល្លារអាមេរិក សម្រាប់ការទូទាត់បំណុលសាធារណៈនៅឆ្នាំ ២០២៥។

## IV. បំណុលសាធារណៈ

គិតត្រឹមត្រីមាសទី ២ ឆ្នាំ ២០២៤ បំណុលសាធារណៈរបស់កម្ពុជាមានចំនួនសរុប ១១.២៧០,៦៩ លានដុល្លារ ដែល ៩៨,៩% (១១.១៥៧, ៤៨ លានដុល្លារ) ជាបំណុលខាងក្រៅ។ ការទូទាត់បំណុលបរទេសសាធារណៈបានថយចុះ ៧% បើធៀបនឹងត្រីមាសទី ២ ឆ្នាំ ២០២៣ ពី ២៤៧ លានដុល្លារដល់ ២២៩ លានដុល្លារ ដោយសារតែការធ្លាក់ចុះចំនួន ១៣% នៃការសងបំណុលរបស់រដ្ឋាភិ

ឯកតា លានដុល្លារអាមេរិក

| សេចក្តីបរិយាយ | 2022(Q1-Q2) | 2023(Q1-Q2) | | | | | 2024(Q1-Q2) | | | | | ប្រែប្រួលជា % | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | សរុប | ប្រាក់ដើម | % | ការប្រាក់ | % | សរុប | ប្រាក់ដើម | % | ការប្រាក់ | % | 2023 | 2024 |
| **ការទូរទាត់បំណុលសរុប** | 218.51 | 247.09 | 190.99 | 77% | 56.1 | 23% | 229.09 | 176.68 | 77% | 52.41 | 23% | 13% | -7% |
| សងទៅពហុភាគី | 63.39 | 66.85 | 51.1 | 76% | 15.75 | 24% | 72.86 | 53.89 | 74% | 18.97 | 26% | 5% | 9% |
| សងទៅទ្វេភាគី | 155.12 | 180.24 | 139.89 | 78% | 40.35 | 22% | 156.25 | 122.80 | 79% | 33.45 | 21% | 16% | -13% |

ប្រភព: ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា លេខ ២៣ ទំព័រ ១៨,
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែសីហា ២០២៤

បាលដល់ភាគីទ្វេភាគី។ ទាំងនៅក្នុងត្រីមាសទី២ នៃឆ្នាំ២០២៣ និងឆ្នាំ២០២៤ ថវិកាប្រមាណ ២៣% សម្រាប់ទូទាត់បំណុល គឺការប្រាក់ និង ៧៧% គឺជាប្រាក់ដើម។

ត្រឹមត្រីមាសទី២ ឆ្នាំ២០២៤ រដ្ឋាភិបាលបានទូទាត់សងបំណុលសាធារណៈក្នុងប្រទេសចំនួន ១,៩០ លានដុល្លារអាមេរិកដែល៥០% គឺជាការប្រាក់[7]។

នៅឆ្នាំ ២០២៥ រដ្ឋាភិបាលគ្រោងនឹងខ្ចីប្រាក់ចំនួន ២.០០០ លាន SDR (២.៦៤៤,៦៦ លានដុល្លារ) ដែលកើនឡើង ១៧,៦៥% ពីឆ្នាំ ២០២៤។ ច្បាប់ថវិកាឆ្នាំ ២០២៥ អនុញ្ញាតអោយមានការខ្ចីបំណុលសាធារណៈច្រើនជាងមុនបើធៀបទៅនឹងឆ្នាំកន្លងមក ពោលគឺ១.៦០០ លាន SDR ក្នុងឆ្នាំ ២០២២ និង ១.៧០០ លានSDR ក្នុងឆ្នាំ២០២៣ និង២០២៤។ នៅក្នុងខែឧសភាឆ្នាំ ២០២៤ រដ្ឋាភិបាលបានដាក់ចេញនូវអត្រាផលិតផលក្នុងស្រុកសរុប (GDP)ថ្មី ដែលរំពឹងថានឹងឈានដល់ ៥១.៤០៤ លានដុល្លារក្នុងឆ្នាំ ២០២៥។

នៅឆ្នាំ ២០២៥ រដ្ឋាភិបាលគ្រោងនឹងវិភាជថវិកាខ្ចីពីបរទេសដើម្បីដោះស្រាយឱភាពថវិកាប្រមាណ ១៦% នៃថវិកាចំណាយរដ្ឋ និង ៥៩៦,៧៤ លានដុល្លារសម្រាប់ការសងបំណុលដែលកើនឡើង៧៦ លានដុល្លារពីឆ្នាំ ២០២៤ ។ ការសងបំណុលសធារណៈត្រូវបានព្យាករណ៍ថាមានចំនួនប្រមាណ ២២,៦% នៃការខ្ចីសរុបនៅឆ្នាំ ២០២៥ ។

ត្រឹមចុងឆ្នាំ ២០២៤ ស្តុកបំណុលរបស់កម្ពុជាត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១២.៥៨៤ លានដុល្លារអាមេរិក ដែលស្មើនឹង ៣៦% នៃផលិតផលក្នុងស្រុកសរុប (GDP) ដែលព្យាករណ៍មុនខែឧសភា ឆ្នាំ២០២៤។ ទោះបីជាយ៉ាងណាក៏ដោយ បើធៀបនឹងផលិតផលក្នុងស្រុកសរុបថ្មី (GDP Rebased) ដែលប៉ាន់ស្មានចំនួន ៤៧.២៣៤ លានដុល្លារ ស្តុកបំណុលសាធារណៈរបស់កម្ពុជាមានចំនួនប្រហែលត្រឹមតែ២៦,៦៤% តែប៉ុណ្ណោះ។

ឯកតា លានដុល្លារអាមេរិក

| សេចក្តីបរិយាយ | ត្រឹមចុងឆ្នាំ2024 | | ត្រឹមចុងឆ្នាំ2025 | |
|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស | ចំនួនទឹកប្រាក់ | % នៃ ផ.ស.ស |
| ផ.ស.ស សរុប | 47,234 | | 51404.03 | |
| ស្តុកបំណុលសាធារណៈ | 12,584 | 26.64% | 13,706 | 26.66% |
| ពិដាននៃការខ្ចីប្រាក់ | 2233 | | 2644.66 | |
| ការដកសាច់ប្រាក់ (៦៥%) (1) | 1451.45 | | 1719.03 | |
| ទឹកប្រាក់ទូរទាត់ការខ្ចី(2) | | | 596.74 | |
| ទឹកប្រាក់បំណុលបន្ថែមលើស្តុកបំណុល២០២៤:(1)-(2) | | | 1122.29 | |

ប្រភព: 1) ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ២០២៣ 2) ច្បាប់ថវិកា ឆ្នាំ២០២៤ និង 3)សេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ២០២៥

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការបញ្ចេញនូវសាច់ប្រាក់កម្ចីជាមធ្យមមានចំនួនប្រមាណ ៦៥% នៃពិដានបំណុល។ ផ្អែកលើការប៉ាន់ប្រមាណនេះ នៅឆ្នាំ ២០២៥ រដ្ឋាភិបាលអាចបញ្ចេញសាច់ប្រាក់កម្ចីពីបរទេសដើម្បីប្រើប្រាស់ប្រមាណ ១.៧១៩ លានដុល្លារពីបំណុលទ្វេភាគី និងពហុភាគី ខណៈដែលរដ្ឋាភិបាលគ្រោងនឹងទូទាត់បំណុលចំនួន ៥៩៦,៧៤ លានដុល្លារ។ បំណុលសាធារណៈត្រូវបានព្យាករណ៍ថានឹងកើនឡើងចំនួន ១.១១៣ លានដុល្លារអាមេរិក ដែលឈានដល់ ១៣.៧០៦ លានដុល្លារអាមេរិក ដែលស្មើនឹង ២៦.៦៦% នៃផលិតផលក្នុងស្រុកសរុប (GDP) នៅ

[7] Cambodia Public Debt Statistical Bulletin, Vol 23, page 19, Ministry of Economy and Finance, August 2024,

ចុងឆ្នាំ ២០២៥។ ទោះបីជាមានការកើនឡើងនៃកម្រិតបំណុលធៀបនឹងឆ្នាំមុនក៏ដោយ រដ្ឋាភិបាលមានគោលបំណងរក្សាអនុបាតបំណុលនៅប្រហែល ២៦% នៃផលិតផលក្នុងស្រុកសរុប។

ដោយសារផលិតផលក្នុងស្រុកសរុប (GDP) ដែលមានមូលដ្ឋានព្យាករណ៍នៅឆ្នាំ២០២៤ បំណុលសាធារណៈរបស់កម្ពុជាបន្តរក្សាបាននូវកម្រិតទាបជាងកម្រិតពិដាន ដែលផ្តល់ឱ្យរដ្ឋាភិបាលមានលទ្ធភាពខ្ចីបំណុលសាធារណៈសម្រាប់ប្រើប្រាស់ជាធនធានបន្ថែម។ យោងតាម IMF អនុបាតបំណុលសាធារណៈធៀបនឹងGDP មិនគួរលើសពី៤០%ទេ។ ខណៈពេលដែលកម្រិតបំណុលសាធារណៈនៅអាចគ្រប់គ្រងបាន រដ្ឋាភិបាលគួរតែប្រកាន់យកវិធានការណ៍បុរេសកម្ម ដើម្បីជៀស វាងការជាប់អន្ទាក់បំណុលសាធារណៈជាមួយបរទេស។

គិតត្រឹមត្រីមាសទី ២ ឆ្នាំ ២០២៤ ប្រទេសចិនជាម្ចាស់បំណុលចំនួន ៣៦% នៃបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា បន្ទាប់មកធនាគារអភិវឌ្ឍន៍អាស៊ី (២២%) ធនាគារពិភពលោក (១២%) និងម្ចាស់បំណុលទ្វេភាគី និងពហុភាគីផ្សេងទៀត (៣០%) ។ ដើម្បីជៀសវាងហានិភ័យ និងអន្ទាក់បំណុលដ៏គ្រោះថ្នាក់ កម្ពុជាត្រូវតែរក្សាការគ្រប់គ្រងបំណុលប្រកបដោយប្រសិទ្ធភាពដែលគួរតែ ផ្តោតលើការវិនិយោគដោយបំណុលសាធារណៈលើការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ខណៈពេលដែលធានាបាននូវតម្លាភាព និងគណនេយ្យភាពផងដែរ។

| |
|---|
| មតិយោបល់៖<br><br>ការធានា និងការគ្រប់គ្រងបានដោយជោគជ័យលើបំណុលសាធារណៈគឺ មានសារៈសំខាន់បំផុតចំពោះរដ្ឋាភិបាល ដើម្បីកាត់បន្ថយវត្តមាននៃរចនាសម្ព័ន្ធ និងយុទ្ធវិធីនៃបំណុលប្រកបដោយគ្រោះថ្នាក់ ព្រមទាំងទប់ស្កាត់ ចំពោះហានិភ័យនានាដល់អធិបតេយ្យភាពជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុល។ សារៈសំខាន់នៃតម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រងបំណុលសាធារណៈព្រមទាំងសុចរិតភាពនៃស្ថាប័នសាធារណៈ ដែលទទួលខុសត្រូវចំពោះកិច្ចការនេះ មិនអាចមិនយកចិត្តទុកដាក់បានឡើយ។ កត្តាចាំបាច់ទាំងនេះ មិនត្រឹមតែការកាត់បន្ថយហានិភ័យ ប៉ុន្តែថែមទាំងសម្រាប់ការជំរុញទំនុកចិត្តសាធារណៈផងដែរ។ នៅក្នុងបរិបទនេះ សវនករខាងក្រៅប្រកបដោយសមត្ថភាពគប្បីចូលរួមក្នុងដំណើរការដើម្បីធានាសុចរិតភាពនៃការគ្រប់គ្រងបំណុល។ សកម្មភាពគ្រប់គ្រង និងចាត់ចែងបំណុលសាធារណៈគប្បីឆ្លងកាត់សវនកម្មខាងក្រៅជាប្រចាំឆ្នាំ ដើម្បីប្រកាន់ខ្ជាប់ខ្ជួននូវការអនុលោមទៅតាមស្តង់ដាដែលកំពុងមាន។ លទ្ធផល និងអនុសាសន៍ទទួលបានពីសវនកម្មនេះ គប្បីត្រូវរាយការណ៍ដល់ស្ថាប័នត្រួតពិនិត្យពាក់ព័ន្ធ។ បន្ថែមលើនេះ របាយការណ៍សំខាន់ៗពាក់ព័ន្ធនឹងសកម្មភាពគ្រប់គ្រងបំណុល គប្បីបង្ហាញផ្សាយដល់សាធារណជន។ |

## V. ប្រភពចំណូលថវិការដ្ឋ៖

រដ្ឋាភិបាលបានបោះជំហានយ៉ាងសំខាន់ក្នុងការធ្វើកំណែទម្រង់គោលនយោបាយសារពើពន្ធ និងការធ្វើទំនើបកម្មការគ្រប់គ្រងចំណូលក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរធនធានសាធារណៈ (២០១៤-២០១៨, ២០១៩-២០២៥)។ នៅឆ្នាំ ២០២៥ ការប្រមូលចំណូលត្រូវបានព្យាករណ៍ថា ចំណូលសារពើពន្ធនឹងប្រមូលចំនួន ៨៧% ឈានដល់ចំនួន ៦.៤៩២ លានដុល្លារអាមេរិក ដែលធ្លាក់ចុះ៥.៥៦% បើធៀបនឹងឆ្នាំមុន។
ប្រភពចំណូលរបស់កម្ពុជា រួមមានចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ខណៈពេលដែលចំណូលសារពើពន្ធត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះក្នុងកម្រិតមធ្យម ចំណូលមិនមែនសារពើពន្ធត្រូវបានព្យាករណ៍ថានឹងកើនឡើងពី ៨១៩,៣៩ លានដុល្លារក្នុងឆ្នាំ ២០២៤ ដល់ ៩៧៥,៨៥ លានដុល្លារក្នុងឆ្នាំ ២០២៥ ដែលជាការកើនឡើងគួរឱ្យកត់សម្គាល់គឺ១៩,២១% ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ប្រាក់ចំណូលមិនមែនសារពើពន្ធមានកំណើនដ៏រឹងមាំ គឺកើនឡើង២៩,៥% ក្នុងឆ្នាំ ២០២៤ បើធៀបនឹងឆ្នាំ ២០២៣។

ប្រាក់ចំណូលមិនមែនសារពើពន្ធត្រូវបានព្យាករណ៍ថានឹងកើនឡើង ១៩,២១% ក្នុងឆ្នាំ ២០២៥ បើធៀបនឹងឆ្នាំ ២០២៤ ចំណូលនេះពឹងផ្អែកជាចំបងលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ផលទុនពីទ្រព្យសម្បត្តិរដ្ឋដែលកើនឡើង ២១៩% ក្នុងឆ្នាំ ២០២៤ ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះ ៦,៤២% នៅឆ្នាំ ២០២៥ ពី ១៣៦ លានដុល្លារទៅ ១២៧ លានដុល្លារ។ ផ្ទុយទៅវិញ ប្រាក់ចំណូលពីការលក់ ជួលទ្រព្យសម្បត្តិ និងការផ្តល់សេវាកម្មរបស់រដ្ឋត្រូវបានព្យាករណ៍ថានឹងកើនឡើង ២៧% កើនឡើងពី ៥៣១ លានដុល្លារក្នុងឆ្នាំ ២០២៤ ដល់ ៦៧៤ លានដុល្លារក្នុងឆ្នាំ ២០២៥ ធៀបនឹង ៣៩១ លានដុល្លារក្នុងឆ្នាំ ២០២៣។ លើសពីនេះ ចំណូលពីការផាកពិន័យ និងដាក់ទណ្ឌកម្មនឹងកើនឡើង ៧% ពី ១៥,៩២ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០២៤ ទៅ ១៧,១៦ លានដុល្លារក្នុងឆ្នាំ២០២៥ ដែលមានកម្រិតដូចគ្នាបើធៀបនឹងឆ្នាំ២០២៣។

ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | | | | | | | ប្រែប្រួល ជា% | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
| ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 273,822.79 | 401,169.24 | 205,084.50 | 173,953.00 | 173,809.40 | 555,925.80 | 520,235.50 | 46.51 | -48.88 | -15.18 | -0.08 | 219.85 | -6.42 |
| ផលទុននៃការលក់ ជួលទ្រព្យសម្បត្តិរដ្ឋ និងការផ្តល់សេវា និងរួមចំណែក | 2,291,834.75 | 1,246,303.45 | 1,470,910.20 | 1,326,046.30 | 1,593,326.10 | 2,160,153.90 | 2,746,328.60 | -45.62 | 18.02 | -9.85 | 20.16 | 35.58 | 27.14 |
| ចំណូលពីការផាកពិន័យ និងដាក់ទណ្ឌកម្ម | 44,124.30 | 80,943.75 | 59,787.30 | 65,765.30 | 71,419.10 | 64,699.30 | 69,807.90 | 83.44 | -26.14 | 10.00 | 8.60 | -9.41 | 7.90 |
| ផលហិរញ្ញវត្ថុ | 169,962.51 | 139,951.25 | 120,007.00 | 173,328.00 | 211,638.40 | 296,631.00 | 333,654.00 | -17.66 | -14.25 | 44.43 | 22.10 | 40.16 | 12.48 |
| ផលផ្សេងៗ និងផលពិសេស | 94,603.81 | 50,706.46 | 39.00 | 40.40 | 6.00 | 6.00 | 6.00 | -46.40 | -99.92 | 3.59 | -85.15 | 0.00 | 0.00 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០២១ ដល់ ២០២៥, ច្បាប់ទូរទាត់ថវិកាជាតិ ឆ្នាំ២០១៩-២០២០

ការធ្លាក់ចុះនៃចំណូលសារពើពន្ធរបស់រដ្ឋាភិបាលបង្កឱ្យមានការព្រួយបារម្ភ និងទាមទារឱ្យមានការឆ្លើយតបយ៉ាងសកម្ម ដើម្បីរក្សាភាពជឿទុកចិត្តបាននៃថវិកាជាតិ។ សក្តានុពល និងឱកាសក្នុងការបង្កើនចំណូលសារពើពន្ធសម្រាប់ការអភិវឌ្ឍន៍ជាតិត្រូវបានគេមើលឃើញ ស្របពេលជាមួយដែលតម្រូវឲ្យមានកាត់បន្ថយបន្ទុកកាតព្វពន្ធតាមរយៈប្រព័ន្ធអនុគ្រោះពន្ធដល់ក្រុមងាយរងគ្រោះ។ ការ

ជំរុញចំណូលសារពើពន្ធ ជាជាងការពឹងផ្អែកលើចំណូលមិនមែនពន្ធ អាចជួយបង្កើនភាពជឿទុកចិត្តលើថវិកាជាតិបានប្រសើរជាងមុន។ ដោយមើលឃើញពីកិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ដើម្បីពង្រឹងការប្រមូលចំណូលសារពើពន្ធ ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល ស្នើនូវអនុសាសន៍ជាក់លាក់ ដើម្បីដោះស្រាយបញ្ហានេះដូចរៀបរាប់ខាងក្រោម។

## V.1 ចំណូលសារពើពន្ធក្នុងប្រទេស៖ ពន្ធផ្ទាល់ និងពន្ធប្រយោល

ឯកតា លានរៀល

| សេចក្ដីបរិយាយ | ចំនួនទឹកប្រាក់ | | | | | %ធៀប | ប្រែប្រួល ជា% | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 2021 | 2022 | 2023 | 2024 | 2025 | | 2022 | 2023 | 2024 | 2025 |
| **ចំណូលសារពន្ធក្នុងស្រុក** | 15224600 | 17815300 | 20882942 | 23200707.7 | 22047113 | | 17.02 | 17.22 | 11.10 | -4.97 |
| ពន្ធផ្ទាល់ | 4,304,000.00 | 5,481,000.00 | 7,257,989.00 | 8,953,173.00 | 8,827,000.00 | 40.04% | 27.35 | 32.42 | 23.36 | -1.41 |
| ពន្ធប្រយោល (VAT) | 6,276,800.00 | 7,049,000.00 | 8,005,355.00 | 8,297,024.00 | 8,091,622.00 | 36.70% | 12.30 | 13.57 | 3.64 | -2.48 |
| អាករពិសេស | 4,508,800.00 | 5,125,300.00 | 5,459,550.00 | 5,789,510.70 | 4,966,800.00 | 22.53% | 13.67 | 6.52 | 6.04 | -14.21 |
| ចំណូលសារពើពន្ធផ្សេងៗ | 135,000.00 | 160,000.00 | 160,048.00 | 161,000.00 | 161,691.00 | 0.73% | 18.52 | 0.03 | 0.59 | 0.43 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០២១ ដល់ ២០២៥

រដ្ឋាភិបាលបង្កើតចំណូលជាចម្បងតាមរយៈពន្ធក្នុងប្រទេសដែលប្រមូលជាចំបងរដ្ឋាភិបាលកណ្ដាល។ នៅឆ្នាំ ២០២៥ រាជរដ្ឋាភិបាលគ្រោងនឹងប្រមូល ២.១៦៣,៣២ លានដុល្លារអាមេរិក (៤០%) ពីពន្ធផ្ទាល់ និង ១.៩៨៨,៦០ លានដុល្លារអាមេរិក (៣៦%) ពីពន្ធប្រយោល។ ទិន្នន័យនេះបង្ហាញពីការពឹងផ្អែករបស់រដ្ឋាភិបាលលើការប្រមូលពន្ធផ្ទាល់ និងពន្ធប្រយោលរបស់រូបវន្តបុគ្គល និងអាជីវកម្ម ដែលជាប្រភពចំណូលដ៏សំខាន់របស់ជាតិ។

## V.2 ចំណូលពីពន្ធលើតម្លៃបន្ថែម និងពន្ធលើប្រាក់ចំណូល

ពន្ធលើតម្លៃបន្ថែម (VAT) ដែលត្រូវបានចាត់ថ្នាក់ក្រោមលេខកូដគណនីចំនួនបី (៧០០២២, ៧០០២៥, និង ៧០០២៦) នៅក្នុងច្បាប់ថវិកាជាតិ គឺជាពន្ធដែលមានអត្រាជាប់ពន្ធ១០% លើទំនិញ និងសេវាកម្មដែលបានអនុវត្តនៅដំណាក់កាលនីមួយៗនៃសង្វាក់ផ្គត់ផ្គង់[8]។ ក្នុងឆ្នាំ ២០២៥ រដ្ឋាភិបាលមានគ្រោងរកចំណូលពីពន្ធនេះចំនួន ១.៩៨៨,៦០ លានដុល្លារ។ បន្ទាប់ពីការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ ២០២៣ ប្រាក់ចំណូលពន្ធលើតម្លៃបន្ថែមបានកើនឡើងជាមធ្យម ៣.៦៤% ក្នុងឆ្នាំ ២០២៤ ប៉ុន្តែត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះ ២,៤៨% ក្នុងឆ្នាំ២០២៥។

| សេចក្ដីបរិយាយ | ចំនួនទឹកប្រាក់ | | | | | ប្រែប្រួល ជា% | | | |
|---|---|---|---|---|---|---|---|---|---|
| | **2021** | **2022** | **2023** | **2024** | **2025** | **2022** | **2023** | **2024** | **2025** |
| **ពន្ធប្រយោល (អាករលើតម្លៃបន្ថែម)** | 6,276,800.00 | 7,049,000.00 | 8,005,355.00 | 8,297,024.00 | 8,091,622.00 | 12.30 | 13.57 | 3.64 | -2.48 |
| អាករលើតម្លៃបន្ថែម (VAT) | 2,640,000.00 | 3,111,000.00 | 3,517,000.00 | 4,027,097.00 | 3,815,000.00 | 17.84 | 13.05 | 14.50 | -5.27 |
| អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 841,700.00 | 800,500.00 | 897,600.00 | 967,484.00 | 1,179,800.00 | -4.89 | 12.13 | 7.79 | 21.95 |
| អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2,795,100.00 | 3,137,500.00 | 3,590,755.00 | 3,302,443.00 | 3,096,822.00 | 12.25 | 14.45 | -8.03 | -6.23 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០២១ ដល់ ២០២៥

ទោះបីជាមានការធ្លាក់ចុះនៃចំណូលពន្ធលើតម្លៃបន្ថែម ដោយសារតែចំណូលក្នុងប្រទេសនៅមានកម្រិតក៏ដោយ រដ្ឋាភិបាលរំពឹងថា ចំណូលពន្ធលើតម្លៃបន្ថែមពីប្រេងសាំង នឹងកើនឡើង ២២% ពី ២៣៨ លានដុល្លារក្នុងឆ្នាំ ២០២៤ ដល់ ២៨៩,៩ លានដុល្លារក្នុងឆ្នាំ ២០២៥។ ទោះជាយ៉ាងណាក៏ដោយ CSO BWG បានសម្តែងការព្រួយបារម្ភថាការពង្រឹងការអនុវត្តពន្ធលើតម្លៃបន្ថែមអាចធ្វើឲ្យធ្លាក់ចុះនូវប្រព័ន្ធដែលគាំទ្រដល់ជន

[8] https://www.rd.go.th/fileadmin/user_upload/AEC/AseanTax-Cambodia.pdf

ងាយរងគ្រោះ និងរារាំងសកម្មភាពអាជីវកម្មថ្មីៗដែលមានទ្រង់ទ្រាយតូចៗ។ ការថយចុះនៃចំណូលពន្ធលើតម្លៃបន្ថែមនៅឆ្នាំ ២០២៥ ត្រូវបានសន្មតថាជាការថយចុះនៃកិច្ចខិតខំប្រឹងប្រែងកៀរគរធនធានរបស់រដ្ឋាភិបាល។

ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | | | | | %ធៀប 2025 | ប្រែប្រួល ជា% | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 2021 | 2022 | 2023 | 2024 | 2025 | | 2022 | 2023 | 2024 | 2025 |
| **ពន្ធផ្ទាល់** | 4,304,000.00 | 5,481,000.00 | 7,257,989.00 | 8,953,173.00 | 8,827,000.00 | | 27.35 | 32.42 | 23.36 | -1.41 |
| ពន្ធលើប្រាក់ចំណូល(រូបវន្តបុគ្គល) | 144,000.00 | 86,000.00 | 45,000.00 | 45,000.00 | 45,000.00 | 0.51% | -40.28 | -47.67 | 0.00 | 0.00 |
| ពន្ធលើប្រាក់ចំណូល(នីតិបុគ្គល) | 3,410,000.00 | 4,400,000.00 | 5,900,000.00 | 7,300,000.00 | 7,100,000.00 | 80.44% | 29.03 | 34.09 | 23.73 | -2.74 |
| ពន្ធលើប្រាក់បៀវត្ស | 750,000.00 | 995,000.00 | 1,312,989.00 | 1,608,173.00 | 1,682,000.00 | 19.06% | 32.67 | 31.96 | 22.48 | 4.59 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០២១ ដល់ ២០២៥

ចាប់តាំងពីឆ្នាំ២០២១ គោលនយោបាយពន្ធដារថ្មីៗត្រូវបានរៀបចំ និងអនុវត្តរួមមានពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ និងពន្ធលើចំណេញមូលធន ដោយសាររាជរដ្ឋាភិបាលព្យាយាមធ្វើពិពិធកម្មផ្នែកប្រភពចំណូលរបស់ខ្លួន និងបង្កើនចំណូលថវិការដ្ឋ។ នៅឆ្នាំ២០២៥ រាជរដ្ឋាភិបាលគ្រោងនឹងប្រមូលថវិកាចំនួនប្រមាណ ១.៧៤៤ លានដុល្លារអាមេរិក ឬ ៨០% នៃពន្ធផ្ទាល់ពីនីតិបុគ្គលដែលជាប់កាតព្វកិច្ចបង់ពន្ធ។ ធៀបនឹងឆ្នាំ២០២៤ ចំនួននេះបានធ្លាក់ចុះចំនួន ២,៧៣%។ ចំណូលពីពន្ធលើប្រាក់ចំណូល ដែលប្រមូលពីរូបវន្តបុគ្គលគ្រោងនឹងបន្តរក្សាបាន ចំនួន១១លានដុល្លារអាមេរិក (០,៥០%) នៃពន្ធផ្ទាល់ ដែលដូចគ្នានឹងចំណូលនៅឆ្នាំ២០២៣ និង ២០២៤។ ពាក់ព័ន្ធនឹងចំណូលពីពន្ធលើប្រាក់បៀវត្សរ៍ មានកំណើនកម្រិតមធ្យមចំនួន ៤.៥៩% ឈានដល់ ៤១៣ លានដុល្លារអាមេរិក ក្រោយពីបានកើនឡើងចំនួន២២% នៅឆ្នាំ២០២៤ បើធៀបនឹងឆ្នាំ២០២៣។

## V.3 ចំណូលពីពន្ធលើផលិតផលថ្នាំជក់ គ្រឿងស្រវឹង និងភេសជ្ជមានជាតិស្ករ និង អាហារមានកម្រិតសារជាតិចិញ្ចឹមទាបៈ

អាករពិសេសនេះគឺជាពន្ធប្រយោលលើទំនិញជាក់លាក់ដូចជាគ្រឿងស្រវឹង ថ្នាំជក់ និងប្រេងឥន្ធនៈ ឬសកម្មភាពសេដ្ឋកិច្ចដូចជាល្បែងស៊ីសងជាដើម។ អាករនេះត្រូវបានរួមបញ្ចូលក្នុងតម្លៃផលិតផលទាំងនេះ ហើយជួយបង្កើតចំណូលជាតិ ដើម្បីធ្វើឲ្យល្អប្រសើរឡើងបញ្ហាសង្គម និងបរិស្ថាន។

ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | | | | |
|---|---|---|---|---|---|
| | 2021 | 2022 | 2023 | 2024 | 2025 |
| **GDP (ឆ្នាំគោល2014) (1)** | 150,793,000.00 | 164,059,000.00 | 177,036,000.00 | 192,005,000.00 | 209,163,000.00 |
| **ចំណូលសារពន្ធក្នុងស្រុក (2)** | 15,224,600.00 | 17,815,300.00 | 20,882,942.00 | 23,200,707.70 | 22,047,113.00 |
| អាករពិសេស (3) | 4,508,800.00 | 5,125,300.00 | 5,459,550.00 | 5,789,510.70 | 4,966,800.00 |
| % នៃ (3) ធៀប (1) | 1248.98% | 1385.22% | 1324.17% | 1472.52% | 1095.82% |
| % នៃ (3) ធៀប (2) | 29.62% | 28.77% | 26.14% | 24.95% | 22.53% |
| % នៃការប្រែប្រួលទឹកប្រាក់នៃ(3) | | 13.67% | 6.52% | 6.04% | -14.21% |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០២១ ដល់ ២០២៥

នៅឆ្នាំ ២០២៥ រដ្ឋាភិបាលរំពឹងថានឹងរកប្រាក់ចំណូលបាន ១.២២០ លានដុល្លារពីអាករពិសេស។ បន្ទាប់ពី COVID-19 កំណើនប្រាក់ចំណូលពីពន្ធនេះបានងើបមកវិញជាបណ្តើរៗគឺ ៦% សម្រាប់ឆ្នាំ ២០២៣ និង ២០២៤ ប៉ុន្តែត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះវិញ ១៤% នៅឆ្នាំ ២០២៥។ អាករ

ពិសេសនឹងបង្កើតបានត្រឹមតែ ២២.៥៣% នៃចំណូលពន្ធក្នុងស្រុកក្នុងឆ្នាំ ២០២៥ នេះនិន្នាការធ្លាក់ចុះចាប់តាំងពីឆ្នាំ ២០២៣មក។ ពន្ធនេះអាចជាការសន្សំសំចៃការចំណាយសាធារណៈលើវិស័យសុខភាពសាធារណៈ តាមរយៈការទប់ស្កាត់ការប្រើប្រាស់ផលិតផលដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពពីសំណាក់សាធារណជន។

ភស្តុតាងបង្ហាញពីផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃគ្រឿងស្រវឹង និងភេសជ្ជៈផ្អែមលើសុខភាពប្រជាពលរដ្ឋ និងប្រព័ន្ធថែទាំសុខភាពសាធារណៈ។ យោងតាមការសិក្សាឆ្នាំ២០២០ របស់អង្គការសុខភាពពិភពលោក ប្រជាជនកម្ពុជាដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ប្រើប្រាស់គ្រឿងស្រវឹងសុទ្ធជាមធ្យម ៦,៧ លីត្រក្នុងមួយឆ្នាំ.[9]។ ក្រសួងសុខាភិបាលបានធ្វើការកត់សម្គាល់ខ្ពស់ពីការបែងចែកថវិកាថែទាំសុខភាពរបស់រដ្ឋាភិបាលសម្រាប់ជំងឺមិនឆ្លងទាក់ទងនឹងការប្រើប្រាស់គ្រឿងស្រវឹងនេះ
[10]

ការសិក្សារបស់ UNDP បានបង្ហាញថា អត្រាពន្ធបារីរបស់កម្ពុជា (២៥-៣១% នៃតម្លៃលក់រាយ) គឺជាអត្រាទាបបំផុតមួយក្នុងអាស៊ាន។ ការបង្កើនពន្ធនេះជាបណ្តើរៗរហូតដល់ ៧៥% អាចបង្កើតចំណូលបន្ថែម ៩២០ ពាន់លានរៀលក្នុងរយៈពេល៥ឆ្នាំ[11]។ WHO ប៉ាន់ប្រមាណថា ការតម្លើងពន្ធបារី ៥០០រៀល នឹងបង្កើនតម្លៃ ១៥% ហើយនឹងកាត់បន្ថយអ្នកជក់បារី ៣០.០០០នាក់ និងសង្គ្រោះជីវិតមនុស្ស ១០.០០០នាក់ពីការស្លាប់ដោយសារការជក់បារីក្នុងរយៈពេល ១០-១៥ឆ្នាំ ហើយថែមទាំង បន្ថែមចំណូលជាតិចំនួន ៥៣លានដុល្លារជារៀងរាល់ឆ្នាំ[12]។

នៅឆ្នាំ ២០២៣ រដ្ឋាភិបាលបានដំឡើងពន្ធលើភេសជ្ជៈគ្មានជាតិអាល់កុលក្នុងស្រុកចំនួន១៥%[13]។ ទោះជាយ៉ាងណាក៏ដោយ CSO BWG ជំរុញឱ្យមានការបង្កើនបន្ថែមពន្ធនេះបន្ថែមទៀតលើថ្នាំជក់ គ្រឿងស្រវឹង ភេសជ្ជៈមានជាតិស្ករ និងផលិតផលអាហាររូបត្ថម្ភទាបផ្សេងទៀត ដើម្បីបង្កើនសុខភាពសាធារណៈ។ អត្រាពន្ធកើន (Progressive tax rate) គួរអនុវត្តឆ្ពោះទៅរកទំនិញដែលបង្កគ្រោះថ្នាក់ដោយមិនធ្វើឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះផងដែរ។ រដ្ឋាភិបាលគួរធ្វើការវាយតម្លៃដើម្បីបង្កើនសក្តានុពលនៃចំណូល ខណៈពេលដែលការពារស្ថិរភាពសេដ្ឋកិច្ច ដោយធ្វើតាមគំរូដែលប្រទេសផ្សេងទៀតនៅក្នុងតំបន់បានធ្វើរួចមកហើយ។ ចំណូលពីផលិតផលទាំងនេះអាចត្រូវបានវិភាគ ដើម្បីបង្កើនប្រព័ន្ធថែទាំសុខភាពសាធារណៈ កែលម្អការផ្តល់សេវាជូនប្រជាពលរដ្ឋ និងការផ្តល់មូលនិធិព្យាបាល ជំងឺមិនឆ្លង។

---

[9] https://www.who.int/data/gho/data/indicators/indicator-details/GHO/total-(recorded-unrecorded)-alcohol-per-capita-(15-)-consumption
[10] https://www.facebook.com/watch/?v=539604785318134&ref=sharing&_rdr
[11] UNDP, RIT International, WHO, WHO FCTC Secretariat, *Policy Brief: Benefits of tobacco control for lower-income Cambodians*, March 2021, https://www.undp.org/cambodia/publications/benefits-tobacco-control-lower-income-cambodians
[12] https://m.postkhmer.com/national/2023-08-18-1029253676.html?fbclid=IwAR0HvEvK4HXI07oQ8DpOo4IbQ3Beyl7poRA_hv8SlRxr7gSE5do7K6049qU
[13] https://www.tax.gov.kh/km/categories/4Vhve01119351942

**មតិយោបល់៖**

- រាជរដ្ឋាភិបាលគប្បីបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីធានានូវ យុត្តិធម៌ និងតម្លាភាពនៅក្នុងការប្រមូលចំណូល ដើម្បីជៀសវាងការបាត់បង់សក្តានុពលចំណូលថវិការដ្ឋ ។ ការពង្រឹង ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដោយហ្មត់ចត់ និងដោយស្មើភាពគ្នាចំពោះអ្នកបង់ពន្ធគ្រប់រូបជាពិសេសក្រុមហ៊ុនផលិតផលគ្រឿងស្រវឹង នឹងបង្កើនចំណូលថវិការដ្ឋ និងជំរុញឱ្យមានលក្ខខណ្ឌស្មើភាពគ្នាក្នុងការប្រកួតប្រជែង។
- រដ្ឋាភិបាលគប្បីយកពន្ធដែលមានអាត្រាកំណើនខ្ពស់ (Progressive tax rate) លើទំនិញប្រណិត និងបន្ថយពន្ធលើទំនិញសំខាន់ៗ ដើម្បីជៀសវាងបន្ទុកកាតព្វកិច្ចដល់ក្រុមងាយរងគ្រោះ។ ផលិតផលថ្នាំជក់ គ្រឿងស្រវឹង និងស្ករគួរតែត្រូវបានជាប់យ៉ាងច្រើន ខណៈដែលប្រេងឥន្ធនៈគួរតែត្រូវបានលើកលែង ដើម្បីទប់ការកើនឡើងតម្លៃទំនិញលើទីផ្សារ ដែលរងការប៉ះពាល់ពីខ្សែច្រវាក់ផ្គត់ផ្គង់។
- ដើម្បីកាត់បន្ថយឥទ្ធិពលប្រកបដោយគ្រោះថ្នាក់របស់បារី និងគ្រឿងស្រវឹងទៅលើប្រជាពលរដ្ឋ វ័យក្មេង រួមទាំងកុមារ រាជរដ្ឋាភិបាលចាំបាច់ត្រូវចេញប្រកាស សេចក្តីណែនាំ ឬអនុម័តច្បាប់គ្រប់គ្រងគ្រឿងស្រវឹងដែលបញ្ជាក់អំពីការកំណត់អាយុសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹង។ ការផ្សាយពាណិជ្ជកម្មបារី និងគ្រឿងស្រវឹងនៅតាមទីសាធារណៈគប្បីត្រូវបានហាមឃាត់ ដើម្បីកាត់បន្ថយការទទួលបាននូវព័ត៌មានទាំងនោះជាសាធារណៈពីសំណាក់សាធារណជនទូទៅ។
- បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពិចារណាពង្រីកវិសាលភាពនៃការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធ ហើយបង្កើនអត្រាពន្ធទៅលើភេសជ្ជនាំចូលដែលមានជាតិស្ករ។ ផលិតផលដែលមានជាតិស្ករកាន់តែខ្ពស់គប្បីត្រូវបង់ពន្ធក្នុងអត្រាកាន់តែច្រើន។ រាជរដ្ឋាភិបាលក៏គប្បីគ្រប់គ្រងលើសារធាតុចិញ្ចឹមនៅក្នុងអាហារតម្លៃថ្លៃតែមានសារជាតុចិញ្ចឹមទាប ដែលមានឥទ្ធិពលអវិជ្ជមានលើកុមារនៅតាមសាលារៀន និងកុមារតូចៗផងដែរ។
- ដើម្បីជួយសម្រាលដល់ទុកលំបាករបស់ក្រុមជនងាយរងគ្រោះស្ត្រីកុមារនៅមូលដ្ឋាន រដ្ឋាភិបាលគួរវិភាជថវិកាចំណាយប្រចាំឆ្នាំលើការងារសង្គម សេវាសាធារៈដល់ថ្នាក់ក្រោមជាតិ ឃុំសង្កាត់ (ពិសេសសេវាសុខភាព និងការអប់រំ) ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុនពីមួយឆ្នាំទៅឆ្នាំ ដើម្បីកាត់បន្ថយហានិភ័យផ្សេងៗដល់ជីវភាពរស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។
- ដើម្បីលើកស្ទួយដល់ជនងាយរងគ្រោះ និងប្រជាពលរដ្ឋដែលប្រកបមុខរបរនេសាទដែលរស់នៅលើទឹក និងតាមមាត់បឹងទន្លេសាប និងបង្កើនជីវជាតិអាហារូបត្ថម្ភដល់កុមារ រាជរដ្ឋាភិបាលគួរលើកទឹកចិត្ត ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបែងចែកថវិកាវិនិយោគរបស់ខ្លួន (ជា

ពិសេសរដ្ឋបាលឃុំ សង្កាត់) សម្រាប់សកម្មភាព គ្រប់គ្រង ការពារ និងថែទាំ ប្រព័ន្ធអេកូឡូស៊ីត្រី ឱ្យបានល្អ និងមាននិរន្តរភាព ។

ដើម្បីលើកស្ទួយដល់ជនងាយរងគ្រោះ និងប្រជាពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាល ដែលពិបាកក្នុង ការរកការងារធ្វើ រាជរដ្ឋាភិបាលគួរលើកទឹកចិត្ត ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបែងចែកថវិកាវិនិយោគរបស់ខ្លួន (ជាពិសេសរដ្ឋបាលឃុំ សង្កាត់) សម្រាប់សកម្មភាព គ្រប់គ្រង ការពារ និងថែទាំ ប្រព័ន្ធអេកូឡូស៊ីលើគោក រួមមាន សហគមន៍ព្រៃឈើ តំបន់ការពារធម្មជាតិ និង លើកទឹកចិត្តដល់សហគមន៍ទាំងអស់នោះ ឱ្យមានការរៀបចំតំបន់អេកូទេសចរណ៍ធម្មជាតិ ដើម្បីមាននិរន្តរភាពសហគមន៍ ។

## V.4 ចំណូលពីពន្ធលើអចលនទ្រព្យ៖

ចំណូលពន្ធលើអចលនទ្រព្យមានសក្តានុពល គួរឱ្យកត់សម្គាល់សម្រាប់ការអភិវឌ្ឍប្រទេស និងត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថា ជាទម្រង់ល្អបំផុតមួយនៃការប្រមូលចំណូល សម្រាប់ការលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ លក្ខណៈសម្បត្តិនៃពន្ធប្រភេទនេះរួមមាន លទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការរួមចំណែកចំពោះសមធម៌សង្គមតាមរយៈគោលនយោបាយអំពីការបែងចែកអត្ថប្រយោជន៍ ដែលអាចជួយបង្រួមស្ថានភាពគម្លាតទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ។ នៅក្នុងប្រទេសមួយចំនួន ចំណូលនេះត្រូវបានប្រើប្រាស់សម្រាប់ផ្តល់មូលនិធិដល់ការអប់រំ សន្តិសុខ ហេដ្ឋារចនាសម្ព័ន្ធ និងប្រើប្រាស់សេវាប្រើប្រាស់ជាប្រចាំរបស់ពលរដ្ឋ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ចំណូលពន្ធលើអចលនទ្រព្យត្រូវបានបូកបញ្ចូលគ្នាជាមួយនឹងពន្ធផ្សេងទៀត ដើម្បីគាំទ្រដល់អាទិភាពនៃការអភិវឌ្ឍន៍ជាតិ។

កម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធពន្ធលើអចលនទ្រព្យកាលពីឆ្នាំ២០១១ ដើម្បីបង្កើតចំណូលថវិកាជាតិ។ ពន្ធនេះរួមមាន:

1. ពន្ធលើអចលនទ្រព្យ (TIP)៖ មានអត្រាពន្ធប្រចាំឆ្នាំ 0,១% លើអចលនវត្ថុដែលមានតម្លៃលើសពី ២៥,000 ដុល្លារ (១00 លានរៀល)។ អចលនទ្រព្យទាំងនេះរួមបញ្ចូលទាំងដី ផ្ទះ អគារ និងហេដ្ឋារចនាសម្ព័ន្ធ។
2. ពន្ធលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ (TTTIP): មានអត្រាពន្ធ ៤% លើការផ្ទេរអចលនទ្រព្យ។
3. ពន្ធលើដីដែលមិនប្រើប្រាស់ (TUL): មានអត្រាពន្ធប្រចាំឆ្នាំ ២% លើតម្លៃទីផ្សារដែលបានវាយតម្លៃ ក្នុងមួយម៉ែត្រការ៉េ។

ប្រភេទពន្ធទាំងនេះរួមចំណែកដល់ការធ្វើពិពិធកម្មចំណូលថវិការបស់កម្ពុជា។ អចលនទ្រព្យមួយចំនួន ដូចជាដីកសិកម្ម និងជាកម្មសិទ្ធិរបស់រដ្ឋ ត្រូវបានលើកលែងពីពន្ធលើអចលនទ្រព្យនៅកម្ពុជា។ តម្លៃទីផ្សារនៃអចលនវត្ថុត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រដ្ឋាភិបាលបង្កើតបានចំណូលកម្រិតមធ្យមពីពន្ធលើអចលនទ្រព្យ រួមទាំងពន្ធលើការផ្ទេរអចលនទ្រព្យ (TTTIP) អចលនទ្រព្យប្រចាំឆ្នាំ និងដីដែលមិនបានប្រើប្រាស់ ដែលត្រូវបានកំណត់ក្នុងគណនីចំណូលនៅក្នុងច្បាប់ថវិកាជាតិរួមមាន៧០០៦១, ៧០០៧១, ៧០០៧២ និង ៧០០៧៣ នៅក្នុងច្បាប់ថវិកាជាតិ។

នៅឆ្នាំ ២០២៥ រដ្ឋាភិបាលនឹងប្រមូលពន្ធអចលនទ្រព្យចំនួន ២០៦,៩៧ លានដុល្លារអាមេរិក ធ្លាក់ចុះ ១៣% ពី ២៣៦,៨៦ លានដុល្លារក្នុងឆ្នាំ ២០២៤[14] ស្មើប្រមាណ ០,៤% នៃផលិតផលក្នុងស្រុកសរុប(GDP)។ ចំណូលពន្ធលើអចលនទ្រព្យមានការប្រែប្រួលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាមួយនឹងការកើនឡើងបន្តិចនៅឆ្នាំ ២០២៣ ក្រោយមកធ្លាក់ចុះនៅឆ្នាំ ២០២៤ និង ២០២៥។ ហើយពន្ធលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យមានចំនួន ៧៥-៨០% នៃ ចំណូលសរុបទទួលបានពីពន្ធលើអចលនទ្រព្យ។

ក្នុងឆ្នាំ ២០២៥ ទោះបីជាមានការថយចុះនចំណូលពន្ធលើអចលនទ្រព្យក៏ដោយ រដ្ឋាភិបាលរំពឹងថានឹងកើនឡើង៣% នៃពន្ធអចលនទ្រព្យប្រចាំឆ្នាំលើផ្ទះ និងសំណង់អគារ។ ចំណូលពីពន្ធលើដីដែលមិនប្រើប្រាស់នឹងធ្លាក់ចុះមកត្រឹម ០,៧៥ លានដុល្លារអាមេរិក ដោយសារតែការលើកលែងពន្ធដែលបានដាក់ចេញនៅឆ្នាំ ២០២៤ ដើម្បីបន្ធូរបន្ថយបន្ទុកបញ្ហាសេដ្ឋកិច្ចលើគ្រួសារដែលមានចំណូលទាប ។ ហើយវិធានការនេះ គឺជាការរួមចំណែកចំពោះការកាត់បន្ថយគម្លាត ខុសគ្នានៃទ្រព្យសម្បត្តិនៅក្នុងចំណោមប្រជាពលរដ្ឋផងដែរ[15]។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មាននិន្នាការគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងប្រជាពលរដ្ឋទិញដីធ្លី នៅតំបន់ជាយក្រុង ដែលជាផ្នែកមួយនៃការរៀបចំផែនការគ្រួសាររបស់ពួកគេដើម្បីធានាបាននូវការមានផ្ទះ

**ចំណូលប្រមូលពីពន្ធលើអចលនទ្រព្យ** ឯកតា លានរៀល

| សេចក្តីបរិយាយ | ការប្រែប្រួលទឹកប្រាក់ (%) | | | | | | |
|---|---|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
| ពន្ធប្រតាប់ត្រាផ្ទេរកម្មសិទ្ធិអចលនទ្រព្យ (TTTIP) | 45% | -14% | -8% | 14% | 4% | -11% | -14% |
| ពន្ធលើអចលនទ្រព្យប្រចាំឆ្នាំ (រូបវន្តបុគ្គល) (TaIP_I) | 13% | -5% | 4% | 6% | 8% | 14% | 3% |
| ពន្ធលើអចលនទ្រព្យប្រចាំឆ្នាំ (នីតិបុគ្គល) (TaIP_E) | 58% | 28% | -22% | 60% | -28% | 56% | 3% |
| ពន្ធលើដីធ្លីមិនប្រើប្រាស់ (TUL) | 45% | -20% | 34% | 14% | -44% | 24% | -86% |
| **សរុបពន្ធលើអចលនទ្រព្យ** | 41% | -13% | -6% | 13% | 3% | -6% | -13% |

ប្រភព៖ ច្បាប់ថវិកាជាតិ ២០១៩ ដល់២០២៥

**ចំណូលប្រមូលពីពន្ធលើអចលនទ្រព្យ** ឯកតា លានរៀល

**ផលធៀបនឹងGDP នៃចំណូលប្រមូលពីពន្ធលើអចលនទ្រព្យ** ឯកតា លានរៀល

| សេចក្តីបរិយាយ | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|---|
| ពន្ធប្រតាប់ត្រាផ្ទេរកម្មសិទ្ធិអចលនទ្រព្យ (TTTIP) | 0.62% | 0.55% | 0.48% | 0.50% | 0.48% | 0.39% | 0.31% |
| ពន្ធលើអចលនទ្រព្យប្រចាំឆ្នាំ (រូបវន្តបុគ្គល និងនីតិបុគ្គល) (TaIP_I and E) | 0.09% | 0.09% | 0.09% | 0.09% | 0.09% | 0.10% | 0.09% |
| ពន្ធលើដីធ្លីមិនប្រើប្រាស់ (TUL) | 0.017% | 0.015% | 0.018% | 0.019% | 0.010% | 0.011% | 0.001% |
| **សរុបពន្ធលើអចលនទ្រព្យ** | 0.72% | 0.66% | 0.58% | 0.61% | 0.58% | 0.50% | 0.40% |

ប្រភព៖ ច្បាប់ថវិកាជាតិ ២០១៩ ដល់២០២៥

[14] KHR 962,840.7 million/KHR4,065, an annual rate for 2024 issued by Ministry of Economy and Finance (MEF)
[15] t.ly/JAwYG

សម្បែងសមរម្យនាពេលអនាគត។ យោងតាមជំរឿនប្រជាពលរដ្ឋនៅឆ្នាំ២០១៩ គ្រួសារកម្ពុជាចំនួនជាង ៦២% រស់នៅក្នុងផ្ទះល្វែងដែលមានតែមួយបន្ទប់[16]។

ការពង្រឹងការអនុវត្តពន្ធលើដីដែលមិនប្រើប្រាស់អាចធ្វើឲ្យ ការគៀងគរចំណូលជាតិកាន់តែប្រសើរឡើង។ រដ្ឋាភិបាលគួរតែស្វែងយល់ពីគោលនយោបាយពន្ធអាត្រាពន្ធកើន (Progressive tax) និងផ្សារភ្ជាប់ប្រភេទពន្ធនេះទៅនឹងសកម្មភាពសេដ្ឋកិច្ច។ ដំណើរការវាយតម្លៃ និងចំណាត់ថ្នាក់ដីមានភាពប្រសើរឡើង គឺចាំបាច់សម្រាប់ការប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធពន្ធអចលនទ្រព្យតាមបែបអាត្រាពន្ធកើន ដែលកំណត់ អត្រាពន្ធខ្ពស់សម្រាប់ដីដែលមិនប្រើប្រាស់មានទំហំធំអាចរារាំងការវិនិយោគដោយប្រថុយទៅលើដីធ្លី។ អត្រាពន្ធបច្ចុប្បន្នចំនួន ២% គឺជាកម្រិតទាបធៀបនឹងប្រទេសអាស៊ានផ្សេងទៀត។

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិលជឿជាក់ថា ពន្ធលើអចលទ្រព្យនៅកម្ពុជាមានសក្តានុពលក្នុងការបង្កើតចំណូលគួរឱ្យកត់សម្គាល់។ ប្រព័ន្ធពន្ធលើអចលនទ្រព្យដោយផ្អែកលើការវាយតម្លៃនូវតម្លៃតាមទី ផ្សារ គឺចាំបាច់ត្រូវការទីផ្សារអចលនទ្រព្យសកម្ម និងប្រកបដោយតម្លាភាព ដែលផ្តល់ប្រភពនៃទិន្នន័យប្រតិបត្តិការត្រឹមត្រូវសម្រាប់ការវាយតម្លៃពិតប្រាកដលើតម្លៃទីផ្សារនៃអចលនទ្រព្យគ្រប់ប្រភេទ និងនៅគ្រប់ទីកន្លែង។ រាជរដ្ឋាភិបាលអាចបង្កើនអត្រាពន្ធ និងពង្រីកមូលដ្ឋានជាប់ពន្ធសម្រាប់អចលនទ្រព្យ។ តាមការអនុវត្តនាពេលបច្ចុប្បន្ន មូលដ្ឋានជាប់ពន្ធត្រូវបានកម្រិតត្រឹមតែរាជធានី និងក្រុងតាមបណ្តាខេត្តប៉ុណ្ណោះ ដែលធ្វើឲ្យមូលដ្ឋានជាប់ពន្ធរួមតូច ស្របពេលដែលមានការរីកចម្រើនយ៉ាងរហ័សនូវហេដ្ឋារចនាសម្ព័ននៅតាមទីប្រជុំជនផ្សេងៗ។ ការកំណត់រយៈពេលខ្លីសម្រាប់ការវាយតម្លៃអចលនទ្រព្យឡើងវិញ ក៏មានសារៈសំខាន់ដែរ ដើម្បីធានាថាតម្លៃអចលនទ្រព្យត្រូវបានធ្វើបច្ចុប្បន្នជាបន្តបន្ទាប់។

ការអនុវត្តពន្ធលើអចលនទ្រព្យគឺមានភាពយុត្តិធម៌ ដោយសារពន្ធនេះបានដាក់បន្ទុកចំពោះតែ លើម្ចាស់កម្មសិទ្ធិអចលនទ្រព្យ ដែលទទួលបានអត្ថប្រយោជន៍កាន់តែច្រើនពីតម្លៃអចលនទ្រព្យដោយសារការរីកចម្រើន និងការកែលម្អហេដ្ឋារចនាសម្ព័ននៅតាមភូមិសាស្ត្រនានា។ អចលនទ្រព្យដែលជាមូលដ្ឋានជាប់ពន្ធត្រូវបានឃើញនិងកំណត់បានយ៉ាងច្បាស់ប្រកបដោយតម្លាភាព ដោយសារតែវាពិបាកលាក់បាំង ឬរត់គេចបាន។

**មតិយោបល់៖**

- បង្កើនប្រាក់ចំណូលពន្ធលើអចលនទ្រព្យ៖ កែលម្អការចុះបញ្ជីអចលនទ្រព្យ ពង្រីកមូលដ្ឋានពន្ធ ធ្វើបច្ចុប្បន្នភាពការវាយតម្លៃតម្លៃទីផ្សារ និងពង្រឹងការគ្រប់គ្រងតាមវិធានការបច្ចេកវិទ្យា។ ផ្តល់ការបន្ធូរបន្ថយពន្ធ ដើម្បីដោះស្រាយបញ្ហាសមធម៌សង្គម។

[16] https://www.habitat.org/where-we-build/cambodia

- ➢ បន្តរក្សាកំណើនចំណូលៈ បង្កើនចំណូលពន្ធអចលនទ្រព្យដល់ ១%-១,៥% នៃផលិតផលក្នុងស្រុកសរុប (GDP) តាមរយៈការអនុវត្តគោលនយោបាយដែលមានប្រសិទ្ធភាព និងគួរឱ្យជឿជាក់ ដើម្បីកាត់បន្ថយផលប៉ះពាល់លើអ្នកបង់ពន្ធដែលងាយរងគ្រោះ។
- ➢ គោលនយោបាយអត្រាពន្ធកើនៈ រក្សានូវកម្រិតចំណូលជាពេលបច្ចុប្បន្ន ប៉ុន្តែត្រូវអនុវត្តការគាំទ្រដល់អ្នកងាយរងគ្រោះ និងអនុវត្តអត្រាពន្ធកើនជាពិសេសលើដីដែលមិនបានប្រើប្រាស់ដើម្បីបង្កើនសមធម៌ និងចំណូលជាតិ។
- ➢ ប្រយុទ្ធប្រឆាំងអំពើពុករលួយៈ អនុវត្តគោលនយោបាយគ្មានការអត់ឱនដើម្បីប្រឆាំងនឹងអំពើពុករលួយ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាក្នុងការគ្រប់គ្រងរដ្ឋបាលពន្ធ បង្ហាញព័ត៌មានការទូទាត់ និងបង្កើនគណនេយ្យភាព។
- ➢ ការកែលម្អជាប្រព័ន្ធក្នុងរយៈពេលយូរ ៖ ដោះស្រាយបញ្ហាប្រឈមដូចជា នគរូបនីយកម្ម ទីផ្សារដីធ្លីក្រៅផ្លូវការ និងឧបសគ្គរារាំងផ្សេងក្នុងស្ថាប័ន តាមរយៈផ្តោតលើការអប់រំអ្នកបង់ពន្ធការធ្វើអនុលោមភាព និងការផ្តល់ហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្កើតប្រព័ន្ធពន្ធអចលនទ្រព្យប្រកបដោយប្រសិទ្ធភាព។
- ➢ ចាត់វិធានការលើជនខិលខូច ដែលតែងតែឆបោក ប្រជាពលរដ្ឋស្លូតត្រង់ និងមានជីវភាពកម្រិតមធ្យម និងខ្ពស់ ក្នុងការវិនិយោគលើអចលទ្រព្យរបស់ពួកគាត់។
- ➢ ពង្រឹងសិទ្ធិលំនៅដ្ឋានរបស់ប្រជាពលរដ្ឋឲ្យកាន់តែមានតម្លាភាព គណនេយ្យភាព ដោយមិនមិនការរំលោភសិទ្ធិ និងការគៀបសង្កត់ផ្សេងៗ

## V.5 ពន្ធលើប្រេងឥន្ធនៈ៖

ពន្ធលើផលិតផលប្រេងសាំងនៅកម្ពុជាផ្តល់មូលនិធិដល់ការសាងសង់ផ្លូវ ការថែទាំ និងការដឹកជញ្ជូនសាធារណៈ។ នៅឆ្នាំ ២០២៥ រដ្ឋាភិបាលគ្រោងនឹងប្រមូលពន្ធនេះចំនួន ១១១,៣៩លានដុល្លារអាមេរិក កើនឡើងពី ៩៦ លានដុល្លារក្នុងឆ្នាំ ២០២៤ ។ ការកើនឡើងនេះស្របតាមការវិនិយោគកាន់តែច្រើនក្នុងការថែទាំ និងការកែលម្អផ្លូវដែលបានកើនឡើងពី ១៣៤ លានដុល្លារក្នុងឆ្នាំ ២០២៣ ដល់ ១៤២ លានដុល្លារក្នុងឆ្នាំ ២០២៤[17] ។

នៅដើមឆ្នាំ ២០២៤ រដ្ឋាភិបាលបានកាត់

ឯកតា លានរៀល

| អាករពិសេសលើផលិតផលប្រេងសាំងសម្រាប់កែលម្អផ្លូវថ្នល់ | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| ចំនួនទឹកប្រាក់ | 361,000.00 | 370,000.00 | 412,300.00 | 393,169.00 | 453,250.00 |
| ការប្រែប្រួលទឹកប្រាក់គិតជា% | | 2.49% | 11.43% | -4.64% | 15.28% |

ប្រភពៈ ច្បាប់ថវិកាជាតិ ឆ្នាំ២០២១ ដល់ ២០២៥

បន្ថយពន្ធគយលើប្រេងសាំងពី ១៥% (0,0៨៤៧ ដុល្លា/លីត្រ) មកត្រឹម 0% ។ នាពេលបច្ចុប្បន្នប្រេងឥន្ធនៈត្រូវបានជាប់ពន្ធតាមដូចជាអាករលើតម្លៃបន្ថែម (១០%) អាករពិសេស (0,១៥៧១ ដុល្លា/លីត្រ កើនឡើងពី 0,0៦៦៩ដុល្លា) និងអាករបន្ថែម (0,0២00ដុល្លា/លីត្រ)។អាករពិសេស (លេខកូដគណនី ៧១00៤) ត្រូវបានគេរំពឹងថានឹងបង្កើតបាន ១១១ លានដុល្លារក្នុងឆ្នាំ ២០២៥ ខ

[17] MEF, Budget in Brief 2023 and 2024

ណៈដែលអាករលើតម្លៃបន្ថែមនឹងរួមចំណែក ២៨៩,៩៤ លានដុល្លារ។ រដ្ឋាភិបាលព្យាករថា ការប្រើប្រាស់សាំងកាន់តែខ្ពស់ ហើយគួរពិចារណាលើការកំណត់ចំណូលពន្ធឡើងវិញ ដើម្បីចៀសវាងការបង្កើនបន្ទុកយ៉ាងខ្លាំងចំពោះអ្នកបង់ពន្ធ។

ប្រេងសាំងមានសារៈសំខាន់សម្រាប់ការដឹកជញ្ជូន និងផលិតកម្ម ដែលប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ និងស្ថិរភាពសេដ្ឋកិច្ច[18]។ តម្លៃសមរម្យអាចលើកកម្ពស់ជីវភាពរស់នៅ ខណៈដែលគោលនយោបាយសារពើពន្ធក្នុងស្រុកដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់តម្លៃក្នុងស្រុកទោះបីមានការប្រែប្រួលទីផ្សារអន្តរជាតិក៏ដោយ។

តម្លៃសាំងនៅកម្ពុជា ត្រូវបានបង្ហាញថាតម្លៃលក់រាយខ្ពស់ជាងប្រទេសជិតខាងដូចជា ប្រទេសថៃ (១,០៤ដុល្លារ/លីត្រ) និងវៀតណាម (០,៧៨ ដុល្លារ/លីត្រ) កម្ពុជាតម្លៃលើរាយគឺ ១,១៥ ដុល្លារ/លីត្រ គិតត្រឹមចុងខែតុលា ឆ្នាំ ២០២៤[19] ។ ការវិភាគនេះស្នើឱ្យកាត់បន្ថយពន្ធសាំងដើម្បីបញ្ចុះតម្លៃ និងលើកកំពស់ជីវភាពរស់នៅ ខណៈការស្នើសុំឲ្យជំនួសមកវិញនូវការប្រមូលចំណូលបន្ថែមពីពន្ធលើអចលនទ្រព្យ ភេសជ្ជៈជាតិស្ករ។ វិធានការទាំងនេះអាចកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សមធម៌ និងលើកកំពស់សុខុមាលភាពទូទៅដោយការដោះស្រាយវិសមភាពទ្រព្យសម្បត្តិ និងការមិនលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលដែលបង្កគ្រោះថ្នាក់។

**មតិយោល់**

រដ្ឋាភិបាលអាចបន្ធូរបន្ថយការកើនឡើងថ្លៃប្រេងដោយការកាត់បន្ថយពន្ធលើប្រេងសាំង តាមរយៈការកាត់បន្ថយអត្រាពន្ធលើតម្លៃបន្ថែមពី ១០% ទៅ ៥% វិធានការនេះនឹងជួយសំរាលបន្ទុកដល់អ្នកប្រើបានប្រមាណ ១៥០ លានដុល្លារ នឹងកាត់បន្ថយការចំណាយលើទំនិញ សេវាកម្ម និងផលិតកម្ម ដែលផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច។

## VI. ការលើកទឹកចិត្តផ្នែកពន្ធ និងការចំណាយ៖

ប្រទេសកម្ពុជាប្រើប្រាស់ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់គោលបំណងជាច្រើន រួមទាំងការសម្របសម្រួលការបង្កើតឱកាសការងារ និងការជំរុញការរួមចំណែកនៃការវិនិយោគចំពោះសេដ្ឋកិច្ចក្នុងស្រុក តាមរយៈការចំណាយលើទំនិញ និងសេវានានា ព្រមទាំងការបំពេញកាតព្វកិច្ចបង់ពន្ធ ដូចជាពន្ធលើប្រាក់ខែ និងអាករតម្លៃបន្ថែម (VAT)។ ក្នុងរយៈពេល ១០ឆ្នាំកន្លងទៅ ប្រទេសកម្ពុជាបានជួបប្រទះនឹងកំណើនគួរឱ្យកត់សម្គាល់នូវការវិនិយោគអភិវឌ្ឍន៍បរទេស (FDI) បើធៀបនឹងផលិតផលក្នុងស្រុកសរុប (GDP)របស់ខ្លួន មានអត្រាកំណើនប្រចាំឆ្នាំជាមធ្យមចំនួន ៤,៦%។ ទោះបីជាយ៉ាងនេះក្តី កម្រិតដែលការលើកទឹកចិត្តផ្នែកពន្ធរួមចំណែកចំពោះការទាក់ទាញ FDI នៅតែមិន

[18] https://www.nytimes.com/2022/10/25/upshot/gas-prices-biden-midterms.html

19 https://tradingeconomics.com/country-list/gasoline-prices?continent=asia

ច្បាស់លាស់ ដោយសារសហគ្រាសអន្តរជាតិអាចនឹងវិនិយោគនៅកម្ពុជា ដោយមិនគិតអំពីការមានការលើកទឹកចិត្តបែបនេះឡើយ។ ថ្វីបើមានការលើកទឹកចិត្តផ្នែកពន្ធក្តី ប្រទេសកម្ពុជា គឺជាទីកន្លែងទាក់ទាញសម្រាប់ការវិនិយោគរួចហើយ ដោយសារកត្តាមួយចំនួនរួមមាន ការទទួលបានកម្លាំងពលកម្មដែលមានប្រសិទ្ធភាពសក្តិសមនឹងតម្លៃ ការមានកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្នែកខ្លះដែលគេចង់បាន ដូចជា EBA និង GSP ។ បទដ្ឋានគតិយុត្តិធូរស្រាលលើភាពជាម្ចាស់កម្មសិទ្ធិរបស់បរទេសដែលអនុញ្ញាតឲ្យមានក្រុមហ៊ុនបរទេស ១០០% និងលទ្ធភាពរបស់ជនបរទេសក្នុងការមានភាពជាកម្មសិទ្ធិលើទ្រព្យសម្បត្តិ ព្រមទាំងលទ្ធភាពប្រើប្រាស់ប្រាក់ដុល្លារអាមេរិកក្នុងទម្រង់ជារូបិយវត្ថុ។ ចាំបាច់ត្រូវកត់សម្គាល់ថា ការវាយតម្លៃគ្រប់ជ្រុងជ្រោយលើសក្តិសិទ្ធិភាពនៃការលើកទឹកចិត្តផ្នែកពន្ធមិនទាន់ត្រូវបានធ្វើនៅឡើយ។ ការប្រើប្រាស់ការវាយតម្លៃនេះក្នុងលក្ខណៈមួយ ដែលធ្វើឱ្យប្រសើរឡើងនូវផលប្រយោជន៍នានា ស្របពេលដែលកាត់បន្ថយបន្ទុកចំណាយ គឺជាការចាំបាច់ ដោយសារការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះអាចមានឥទ្ធិពលអវិជ្ជមានលើចំណូលរបស់ជាតិ។ តម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រងការលើកទឹកចិត្តផ្នែកពន្ធ គឺជាអាទិភាពខ្ពស់បំផុត។

មតិយោបល់៖

ក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល ស្នើរាជរដ្ឋាភិបាលបោះពុម្ពផ្សាយជាប្រចាំនូវព័ត៌មានទាក់ទងនឹងនឹងការវាយតម្លៃលើប្រសិទ្ធភាពនៃការលើកទឹកចិត្តផ្នែកពន្ធ ជាពិសេសព័ត៌មានទាក់ទងនឹងការចំណាយតាមរយៈការអនុវត្តការលើកទឹកចិត្តនេះ និងផលជះត្រឡប់នៃឥរិយាបទអ្នកវិនិយោគ។

រដ្ឋាភិបាលត្រូវបើកចំហព័ត៌មានថវិកាជាសាធារណៈ លើបណ្តាញសង្គមរបស់រដ្ឋ និងជូនដំណឹងដល់ប្រជាពលរដ្ឋជាប្រចាំ ដើម្បីលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន និងការចូលរួមមតិយោបល់កែលម្អផ្សេងៗ កាន់តែធ្វើរដ្ឋាភិបាលមានធាតុចូលក្នុងការដោះស្រាយបញ្ហារាំងស្ទះទាំងឡាយប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងប្រយោជន៍រួមរបស់ប្រជាពលរដ្ឋរបស់ខ្លួន។

## VII. ការចំណាយសម្រាប់វិស័យអប់រំ សុខាភិបាល និងកិច្ចគាំពារសង្គមនៅក្រោមខ្ទង់ថវិកានៃក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖

ថវិកាជាតិឆ្នាំ ២០២៥ ឆ្លុះបញ្ចាំងពីការវិភាគយ៉ាងប្រុងប្រយ័ត្ន ដោយសារឧបសគ្គនៃការប្រមូលចំណូល ជាពិសេសចំណូលសារពើពន្ធ។ ការវិភាគថវិកានេះហើយត្រូវបានពិពណ៌នាថាការឆ្ពោះទៅមុខក្នុងគោលបំណងដោះស្រាយបញ្ហាប្រឈម និងការសម្រេចបាននូវគោលនយោបាយ។ រដ្ឋាភិបាលផ្តល់អាទិភាពលើការលើកកម្ពស់ធនធានមនុស្សជាសសរស្តម្ភយុទ្ធសាស្ត្រ តាមរយៈការបង្កើនការវិនិយោគលើវិស័យអប់រំ សុខភាពសាធារណៈ និងកិច្ចគាំពារសង្គម។

ឯកតា លានរៀល

| សេចក្តីបរិយាយ | ឆ្នាំ2019 ចំនួនទឹកប្រាក់ | % នៃ GDP | % នៃការចំណាយថ្នាក់ជាតិ | ឆ្នាំ2020 ចំនួនទឹកប្រាក់ | % នៃ GDP | % នៃការចំណាយថ្នាក់ជាតិ | ឆ្នាំ2021 ចំនួនទឹកប្រាក់ | % នៃ GDP | % នៃការចំណាយថ្នាក់ជាតិ | ឆ្នាំ2022 ចំនួនទឹកប្រាក់ (% | % នៃ GDP | % នៃការចំណាយថ្នាក់ជាតិ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ.ស. ស (GDP) | 148,985,000.0 | | | 142,503,000.0 | | | 150,793,000.0 | | | 164,059,000.0 | | |
| សរុបរួមចំណាយថវិកាថ្នាក់ជាតិ | 25,765,028.0 | | | 31,095,855.0 | | | 30,491,336.0 | | | 32,576,866.0 | | |
| ក្រសួងសុខាភិបាល | 1,820,925.0 | 1.22 | 7.07 | 2,102,899.4 | 1.48 | 6.76 | 2,228,069.0 | 1.48 | 7.31 | 2,888,090.4 | 1.76 | 8.87 |
| ក្រសួងអប់រំ យុវជន និងកីឡា | 3,661,670.2 | 2.46 | 14.21 | 3,738,130.3 | 2.62 | 12.02 | 3,436,236.0 | 2.28 | 11.27 | 3,382,658.2 | 2.06 | 10.38 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 1,007,390.9 | 0.68 | 3.91 | 1,142,664.4 | 0.80 | 3.67 | 1,301,249.0 | 0.86 | 4.27 | 1,426,095.0 | 0.87 | 4.38 |

| សេចក្តីបរិយាយ | ឆ្នាំ2023 ចំនួនទឹកប្រាក់ | % នៃ GDP | % នៃការចំណាយថ្នាក់ជាតិ | ឆ្នាំ2024 ចំនួនទឹកប្រាក់ | % នៃ GDP | % នៃការចំណាយថ្នាក់ជាតិ | ឆ្នាំ2025 ចំនួនទឹកប្រាក់ | % នៃ GDP | % នៃការចំណាយថ្នាក់ជាតិ | ប្រែប្រួល (ឆ្នាំ2024-2025) ចំនួនទឹកប្រាក់ (%) | ពិន្ទុ% នៃ GDP | ពិន្ទុ% នៃការចំណាយថ្នាក់ជាតិ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ.ស. ស (GDP) | 177,036,000.0 | | | 192,005,000.0 | | | 209,163,000.0 | | | | | |
| សរុបរួមចំណាយថវិកាថ្នាក់ជាតិ | 36,603,698.0 | | | 34,497,444.0 | | | 35,398,175.0 | | | | | |
| ក្រសួងសុខាភិបាល | 2,880,574.6 | 1.63 | 7.87 | 2,668,153.0 | 1.39 | 7.73 | 2,670,042.0 | 1.28 | 7.54 | 0.07 | -0.113 | -0.191 |
| ក្រសួងអប់រំ យុវជន និងកីឡា | 3,730,157.0 | 2.11 | 10.19 | 4,051,781.0 | 2.11 | 11.75 | 4,393,805.4 | 2.10 | 12.41 | 8.44 | -0.010 | 0.667 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 1,468,855.0 | 0.83 | 4.01 | 2,314,645.0 | 1.21 | 6.71 | 2,316,500.0 | 1.11 | 6.54 | 0.08 | -0.098 | -0.165 |

ប្រភពច្បាប់ថវិការជាតិឆ្នាំ ២០១៩,២០២០,២០២១,២០២២,២០២៣,២០២៤ និង២០២៥

គួរកត់សម្គាល់ថា ក្រសួងអប់រំ យុវជន និងកីឡា មានការកើនឡើងថវិកា ៨% ដែលលើសពីអត្រាអតិផរណាដែលបានព្យាករចំនួន ២%។ បើប្រៀបធៀបនឹង GDP ក្រសួងអប់រំ យុវជន និងកីឡា ទទួលបានថវិកា ២.១០% ក្រសួងសុខាភិបាល ១.២៨% និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១.១១%។ ក្នុងចំណោមក្រសួងទាំងអស់ វិស័យអប់រំទទួលបានការបែងចែកថវិកាច្រើនជាងគេ បន្ទាប់មកក្រសួងការពារជាតិមាន ១,៤២% នៃផលិតផលក្នុងស្រុកសរុប។

រដ្ឋាភិបាលបានព្យាករណ៍ពីអត្រាអតិផរណា ២% សម្រាប់ឆ្នាំ ២០២៤ និង ២,៥% សម្រាប់ឆ្នាំ ២០២៥។ ដោយទូទាត់នឹងចំណាយលើអត្រាអតិផរណា ការវិភាជថវិកាសម្រាប់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងសុខាភិបាលប្រឈមនឹងការថយចុះបន្តិច បើធៀបនឹងឆ្នាំ ២០២៤។ ការធ្លាក់ចុះនេះធ្វើឱ្យមានការព្រួយបារម្ភអំពីសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការរក្សាគុណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈត្រឹមកម្រិតដែលបានអនុវត្តឆ្នាំ២០២៤។

ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ឆ្នាំ ២០២៤ | ទឹប្រាក់សម្រាប់ អតិផរណាឆ្នាំ ២០២៥: ២,៥% | ទឹកប្រាក់ ឆ្នាំ២០២៥ (មុនដកអតិផរណា) | ទឹកប្រាក់ ឆ្នាំ២០២៥ (ក្រោយដកអតិផរណា) | ទឹកប្រាក់ ប្រែប្រួលពិតប្រាកដ ជា% (ឆ្នាំ២០២៤-២០២៥) |
|---|---|---|---|---|---|
| ក្រសួងសុខាភិបាល | 2,668,153.00 | 53,363.06 | 2,670,042.00 | 2,616,678.94 | -1.93 |
| ក្រសួងអប់រំ យុវជន និងកីឡា | 4,051,781.00 | 81,035.62 | 4,393,805.40 | 4,312,769.78 | 6.44 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 2,314,645.00 | 46,292.90 | 2,316,500.00 | 2,270,207.10 | -1.92 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០២៤ និង ២០២៥, និង
MTFF 2024 of MoEF

លើសពីនេះ ថវិកាជាតិឆ្នាំ ២០២៥ រួមមានការកើនឡើង ៣,៥% នៃការចំណាយបន្ទុកបុគ្គលិកដែលជាបន្ទុកចំណាយចរន្ត។ ការកើនឡើងនេះ គួបផ្សំនឹងការអត្រាអតិផរណា អាចជាដែនកំណត់លើសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការផ្តល់សេវា ដោយសារផ្នែកសំខាន់នៃថវិកាត្រូវបានស្រូបយកដោយការកើនឡើងលើចំណាយបន្ទុកបុគ្គលិក ជាជាងការដោះស្រាយតម្រូវការសាធារណៈជាទូទៅ។

## VII.1 វិស័យអប់រំ

ថវិកាអប់រំក្រោមក្រសួងអប់រំ និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ ២០២៥ នៅតែស្ថិតក្នុងកម្រិត ២,១០% នៃផលិតផលក្នុងស្រុកសរុប (១.០៧៩,៨២ លានដុល្លារ) ស្ទើរតែមិនផ្លាស់ប្តូរពីឆ្នាំ ២០២៤ (២.១១%) ហើយនៅតែទាបជាងកម្រិតមុនកូវីដ-១៩ (២.៤៦%) ក្នុងឆ្នាំ ២០១៩។ ទោះបីជាមានការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការកែលម្អគុណភាពអប់រំជាសកលក៏ដោយ ថវិកាវិស័យអប់រំមានចំនួនតិច ជាងអនុសាសន៍ដែលបានកំណត់ (២០%) នៃការចំណាយសរុប។ ការរីកចំរើនលើការចំណាយលើវិស័យអប់រំរបស់ប្រទេសកម្ពុជាក៏តិចជាងអត្រាចំណាយក្នុងតំបន់ដែលមានចំនួន ៤,៧%ជាមធ្យម នៃ GDP[20]។

របាយការណ៍ស្តីពីវិស័យអប់រំនៅកម្ពុជាបង្ហាញថា ៨០% នៃថវិកាចរន្ត ត្រូវបានវិភាគសម្រាប់ប្រាក់បៀវត្សបុគ្គលិកអប់រំ និងគ្រូបង្រៀន នៅសល់តែ ២០% សម្រាប់ការចំណាយក្រៅបន្ទុកបុគ្គលិក។

[20] Cambodia Human Capital Index 2020, www.worldbank.org/humancapital

អតុល្យភាពនេះគូសបញ្ជាក់អំពីការវិនិយោគនៅមានដែនកំណត់ក្នុងបញ្ហាសំខាន់ផ្សេងៗទៀតនៃវិស័យអប់រំ ដែលអាចមានផលប៉ះពាល់ដល់គុណភាពអប់រំ និងធនធានទាំងមូល[21]។

យោងតាមទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានឱ្យដឹងថា ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២២ ប្រទេសកម្ពុជាមានអត្រាចុះឈ្មោះសិស្សចូលរៀនជាមធ្យមចំនួន ៣.១៨ លាននាក់ក្នុងមួយឆ្នាំសិក្សា។ ចំនួននេះគឺការចុះចូលរៀននៅកម្រិតសិក្សាចំណេះដឹងទូទៅនៃការអប់រំសាធារណៈ ដោយមិនរាប់បញ្ចូលនិស្សិតសាកលវិទ្យាល័យ។ ផ្អែកលើតួលេខចុះឈ្មោះចូលរៀននេះ រដ្ឋាភិបាលបានវិនិយោគថវិកាប្រមាណ ១,១លានរៀល ឬប្រហែល ២៥០ដុល្លារអាមេរិកក្នុងសិស្សម្នាក់ក្នុងមួយឆ្នាំសិក្សា។

ការវិនិយោគលើសិស្សនេះស្របតាមការរកឃើញពីរបាយការណ៍របស់អង្គការយូនីសេហ្វ ដែលបង្ហាញនៅក្នុងឆ្នាំ ២០២១ សម្រាប់សាលាជំនាន់ថ្មី រដ្ឋាភិបាលរួមជាមួយការរួមចំណែករបស់មាតាបិតាសិស្ស ចវិកាចំណាយលើចំនួន ៥១៥ដុល្លារសម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំ ច្រើនជាងទ្វេដងដែលចំណាយសម្រាប់សិស្សម្នាក់នៅក្នុងសាលាសាធារណៈធម្មតា (២៤០ដុល្លារ)។ តួលេខទាំងនេះបង្ហាញពីភាពខុសគ្នានៃការវិភាជធនធានប្រភេទផ្សេងៗនៃស្ថាប័នអប់រំ[22]។

ផែនការយុទ្ធសាស្ត្រអប់រំរបស់កម្ពុជាឆ្នាំ ២០២៤-២០២៨ មានតម្រូវការថវិកា ២,១០% នៃផលិតផលក្នុងស្រុកសរុបសម្រាប់អនុវត្តនៅឆ្នាំ ២០២៥។ តម្រូវការនេះឆ្លុះបញ្ចាំងពីការប្រែប្រួលនៃការវិនិយោគក្នុងវិស័យអប់រំ ដោយសារផែនការយុទ្ធសាស្ត្រនាពេលកន្លងមក (២០១៩-២០២៣) បានកំណត់តម្រូវការធនធានចំនួន១៩,១% នៃថវិកាជាតិ (៣,១% នៃ GDP) នៅត្រឹមឆ្នាំ ២០២៣។ ប្រទេសកម្ពុជា ដែលជាប្រទេសហត្ថលេខីនៃក្របខណ្ឌការអប់រំឆ្នាំ ២០៣០ ហើយត្រូវបានលើកទឹកចិត្តឱ្យបែងចែក ៤%-៦% នៃ GDP ឬ ១៥%-២០% នៃការចំណាយសាធារណៈសម្រាប់វិស័យអប់រំ[23]។ ដើម្បីបំពេញតាមស្តង់ដារអន្តរជាតិ រដ្ឋាភិបាលគប្បីវិភាជថវិកាពីការចំណាយដែលមិនចាំបាច់ដើម្បីផ្តល់អាទិភាពចំណាយដល់ប្រពលរដ្ឋដែលជួបការលំបាក។

ក្នុងចំណោមថវិកាអប់រំចំនួន ១.០៧៩.៨២ លានដុល្លាររបស់កម្ពុជា ៤៥៣ លានដុល្លារអាមេរិក (៤២%) ត្រូវបានបែងចែកទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកើនឡើង ៥,៣% ពីឆ្នាំ ២០២៤។ នេះរួមបញ្ចូលទាំង ៤៣១ លានដុល្លារសម្រាប់រដ្ឋបាលក្រុង ស្រុក និង ២២ លានដុល្លារសម្រាប់រដ្ឋបាលខេត្ត។ រដ្ឋាភិបាលមានគោលបំណងលើកកម្ពស់គុណភាពអប់រំតាមរយៈវិមជ្ឈការ ដោយផ្តោតលើកុមារតូច បឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែង

[21] Page 06, https://www.unicef.org/cambodia/media/7871/file/Education%20Budget%20Brief%202020%20-%20English.pdf

[22] Page6, EDUCATION BUDGET BRIEF 2021, Semptember 2021 by NICEF Cambodia

[23] Page:9, Incheon Declaration and Framework for Action for the implementation of Sustainable Development Goal 4 https://uis.unesco.org/sites/default/files/documents/education-2030-incheon-framework-for-action-implementation-of-sdg4-2016-en_2.pd

ទាំងនេះ ក្រសួងអប់រំគួរតែលើកកម្ពស់ការយល់ដឹងជាសាធារណៈ ការចូលរួម និងតម្លាភាពក្នុងការគ្រប់គ្រងថវិកាចំណាយទាំងនោះ។

ធនាគារពិភពលោកសង្កត់ធ្ងន់ថា ការផ្តល់មូលនិធិអប់រំគ្រប់គ្រាន់មានសារៈសំខាន់ណាស់សម្រាប់ការលើកកម្ពស់គុណភាពសាលារៀន។ ថវិកាប្រតិបត្តិការរបស់សាលាមានចាប់ពី USD ២៤៨ ដល់ USD ២៥.៨៣៣ ជារៀងរាល់ឆ្នាំ តាមរយៈ School Improvement Grants (SIG)។ ក្នុងឆ្នាំ ២០២៥-២០១៦ សាលាបឋមសិក្សា និងមធ្យមសិក្សាបានចំណាយជាមធ្យមចំនួន USD ១១៨ នៃមូលនិធិ SIG លើការកែលម្អគុណភាព។ ទោះបីជាមានការគ្រប់គ្រងរឹងមាំក៏ដោយ សាលារៀនតូចៗប្រឈមមុខនឹងបញ្ហាក្នុងការលើកកម្ពស់គុណភាពអប់រំ ដោយសារធនធានមានកម្រិត[24]។

## VII.2 វិស័យសុខាភិបាល

ក្នុងឆ្នាំ ២០២៥ ថវិកាសុខាភិបាលរបស់កម្ពុជានៅតែមិនប្រែប្រួលខុសពីឆ្នាំ ២០២៤ ដែលមានចំនួន ៦៥៦ លានដុល្លារអាមេរិក ប៉ុន្តែបើធៀបនឹង ផលិតផលក្នុងស្រុកសរុប និងការចំណាយជាតិ ថវិកានេះមានថយចុះបន្តិចជាភាគរយ។ ថវិកាសុខាភិបាលនេះធ្លាក់ចុះចំនួន ៧១,៨ លានដុល្លារក្នុងឆ្នាំ ២០២៣ ពីឆ្នាំ ២០២២ ដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរអាទិភាពរបស់រដ្ឋាភិបាល នៅពេលដែលជំងឺរាតត្បាតបានធ្លាក់ចុះ។ ការធ្លាក់ចុះជាបន្តបន្ទាប់ក្នុងឆ្នាំ ២០២៤ និងឆ្នាំ ២០២៥ បង្កើនការព្រួយបារម្ភអំពីសុខភាពសាធារណៈដែលមានតួនាទីយ៉ាងសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចដែលត្រូវបានព្យាករណ៍ប្រមាណ ៦% ។ រដ្ឋាភិបាលគប្បីផ្តល់អាទិភាពដល់សុខភាពសាធារណៈ តាមរយៈវិភាជថវិកាពីការកាត់បន្ថយការចំណាយដែលមិនចាំបាច់។

ថវិកាសុខភាពសាធារណៈ២០២៤ និង២០២៥ របស់កម្ពុជាចំនួន ៦៥៦ លានដុល្លារអាមេរិក គឺមិនទាន់ឈានដល់គោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រសុខភាពឆ្នាំ ២០១៦-២០២០ ក្នុងចំនួនថវិកាចំនួន ៧៤៥ លានដុល្លារ។ ការចំណាយលើសុខភាពសាធារណៈមានការប្រែប្រួលក្នុងរយៈពេល ០៥ ឆ្នាំចុងក្រោយនេះ ពោលគឺ ៨.៨៧% នៃការចំណាយថ្នាក់ជាតិក្នុងឆ្នាំ ២០២២ មុនពេលធ្លាក់ចុះមកត្រឹម ៧.៨៧% នៅឆ្នាំ ២០២៣ និង ៧.៧៣% នៅឆ្នាំ ២០២៤ និង ២០២៥ ហើយអាត្រានេះទាបជាងអត្រាកម្រិតមធ្យមក្នុងតំបន់ ៨,៥% នៅអាស៊ីអាគ្នេយ៍[25]។

[24] PUBLIC EXPENDITURE TRACKING AND QUALITY OF SERVICE DELIVERY SURVEY: page 13-14, World Bank: t.ly/DsWE0

[25] Augustine D Asante, Por Ir, Bart Jacobs, Limwattananon Supon, Marco Liverani, Andrew Hayen, Stephen Jan, Virginia Wiseman, October 2019, Who benefits from healthcare spending in Cambodia? Evidence for a universal health coverage policy, https://doi.org/10.1093/heapol/czz011

**VII.3 កិច្ចគាំពារសង្គម និងការអនុវត្តថវិកាជំនួយសង្គមសម្រាប់ប្រជាពលរដ្ឋ ក្នុងគណនី ៦២០២៨**

ថវិការបស់ក្រសួងសង្គមកិច្ចបានកើនឡើងពី ០,៨៣% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០២៣ ដល់ ១,២១% ក្នុងឆ្នាំ ២០២៤ ដោយធ្លាក់ចុះបន្តិចមកត្រឹម ១,១១ នៅឆ្នាំ ២០២៥។ ការវិភាជក្នុងឆ្នាំ២០២៥ ស្ទើរតែមិនប្រែប្រួល បើធៀបនឹងឆ្នាំ ២០២៤ ទោះបីជាមានការអត្រាអតិផរណា (២,៥%) ក៏ដោយ។ ផែនការរយៈពេល ០៣ ឆ្នាំរបស់ក្រសួងបានកំណត់គោលដៅសម្រាប់ធនធានថវិកាចំនួន៤២១ លានដុល្លារនៅឆ្នាំ ២០២៣ ស្របពេលដែល ៥៦៩ លានដុល្លារត្រូវវិភាជក្នុងឆ្នាំ ២០២៤ ដែលឆ្លុះបញ្ចាំងពីកិច្ចគាំពារសង្គមជាតម្រូវការអាទិភាព[26]។ នៅទូទាំងពិភពលោក កិច្ចគាំពារសង្គមត្រូវបានកំណត់ចំនួន១២,៨% នៃផលិតផលក្នុងស្រុកសរុប ជាមធ្យម ៧,៥% នៅអាស៊ី នេះបង្ហាញថាកម្ពុជាមានការវិភាជចំណាយទាបនៅឡើយ។

ឯកតា លានរៀល

| ការចំណាយសរុបដោយក្រសួងថ្នាក់កណ្តាល ឬស្ថាប័នជាតិ លើអនុគណនីចំណាយជំនួយសង្គមផ្សេងៗដល់ប្រជាពលរដ្ឋ (62028) | ឆ្នាំ ២០២៣ | % | ឆ្នាំ ២០២៤ | % |
|---|---|---|---|---|
| | **624,371.10** | | **594,041.50** | |
| ព្រឹទ្ធសភា | 4,000.00 | 0.64% | 4,000.00 | 0.67% |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 82,000.00 | 13.13% | 172,000.00 | 28.95% |
| រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 10,000.00 | 1.60% | 10,000.00 | 1.68% |
| ក្រសួងមហាផ្ទៃរដ្ឋបាលទូទៅ | 1,160.00 | 0.19% | 1,185.00 | 0.20% |
| ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 2,300.00 | 0.37% | 2,300.00 | 0.39% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 120.00 | 0.02% | 120.00 | 0.02% |
| ក្រសួងព័ត៌មាន | 250.00 | 0.04% | 270.00 | 0.05% |
| ក្រសួងសុខាភិបាល | 516,000.00 | ##### | 386,000.00 | 64.98% |
| ក្រសួងអប់រំ យុវជននិងកីឡា | 2,804.10 | 0.45% | 5,439.50 | 0.92% |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 497.00 | 0.08% | 487.00 | 0.08% |
| ក្រសួងបរិស្ថាន | 730.00 | 0.12% | 730.00 | 0.12% |
| ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | 1,900.00 | 0.30% | 1,900.00 | 0.32% |
| ក្រសួងយុត្តិធម៌ | 2,600.00 | 0.42% | 2,600.00 | 0.44% |
| តុលាការកំពូល | 10.00 | 0.00% | 10.00 | 0.00% |
| ក្រសួងផែនការ | | | 7,000.00 | 1.18% |

ប្រភព: ចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និង២០២៤ ដោយអគ្គនាយកដ្ឋានថវិកា

ទោះបីជាមានការកើនឡើងនៃការបែងចែកថវិការបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ ២០២៤ សម្រាប់ការគាំពារសង្គមក៏ដោយ ក៏ប្រទេសនេះនៅតែស្ថិតនៅពីក្រោយស្តង់ដារតំបន់ និងសកលលោកក្នុងការចំណាយរបស់រដ្ឋាភិបាល។ យោងតាម ILO ប្រទេសដែលមានប្រាក់ចំណូលទាបទាមទារការវិនិយោគបន្ថែមចំនួន ៧៧.៩ ពាន់លានដុល្លារក្នុងមួយឆ្នាំ (១៥,៩% នៃផលិតផលក្នុងស្រុកសរុប) ដើម្បីធានាសន្តិសុខសង្គមជាមូលដ្ឋាន។ សម្រាប់ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ដូចជាកម្ពុជាផងដែរ ថវិកាសម្រាប់វិភាជលើវិស័យនេះត្រូវបានលើកទឹកចិត្តចំនួន ៥,១% នៃផលិតផលក្នុងស្រុកសរុប។ កម្ពុជាត្រូវតែជំរុញការចំណាយលើកិច្ចគាំពារសង្គមរបស់ខ្លួនយ៉ាងសំខាន់ ដើម្បីបំពេញតាមអនុសាសន៍ទាំងនេះ។

កិច្ចគាំពារសង្គមនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយក្រសួងជាច្រើន។ ក្រសួងសង្គមកិច្ចត្រួតពិនិត្យកម្មវិធីសំខាន់ៗ ខណៈដែលក្រសួងសុខាភិបាលគ្រប់គ្រងប័ណ្ណសមធម៌សុខភាពសម្រាប់ក្រុមងាយរងគ្រោះ។ ក្រសួងផែនការដំណើរការកម្មវិធីបណ្ណក្រីក្រ ហើយក្រសួងអប់រំអនុវត្តគោលនយោបាយអាហារូបត្ថម្ភ និងអាហារូបករណ៍។ លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តាមរយៈក្រុមប្រឹក្សាជាតិគាំពារសង្គម) និងក្រសួងការងារ (តាមរយៈបេឡាជាតិរបបសន្តិសុខសង្គម) សម្របសម្រួលរបបសន្តិសុខសង្គម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីផ្ទេរប្រាក់។

[26] Executive Summary of Budget Law 2014

នៅឆ្នាំ ២០២៤ ១៦% នៃថវិកាចំនួន ៥.៨៥២ លានដុល្លារអាមេរិកដែលបានវិភាគសម្រាប់ការចំណាយចរន្ត បានកំណត់មុខសញ្ញាចំណាយអត្ថប្រយោជន៍សង្គម ដោយ៣៥% ត្រូវបានកំណត់សម្រាប់ជំនួយសង្គមដល់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ១៥៥ លានដុល្លារអាមេរិក ត្រូវបានវិភាជក្នុងការចំណាយ "ជំនួយផ្សេងទៀត" (ស្មើ ៤៨% នៃជំនួយសង្គមដល់ប្រជាពលរដ្ឋ) ត្រូវបានចែកចាយទៅស្ថាប័នរដ្ឋាភិបាលកណ្តាលផ្សេងៗ ដែលមិនជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងក្របខ័ណ្ឌការគាំពារសង្គម ដូចជាទីស្តីការគណៈរដ្ឋមន្ត្រី ដែលទទួលបាន ២៨% និងអង្គភាពផ្សេងទៀតដូចជា លេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងព្រឹទ្ធសភា។

អង្គការសង្គមស៊ីវិលកោតសរសើរនូវការកើនឡើងនៃការចំណាយសង្គម ប៉ុន្តែការចំណាយនេះត្រូវយកចិត្តទុកដាក់ចំពោះតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់ថវិកា។ ថវិកាគាំពារសង្គមគួរតែត្រូវបានគ្រប់គ្រងដោយផ្ទាល់ដោយក្រសួងដែលមានទំនួលខុសត្រូវ ដើម្បីបង្កើនប្រសិទ្ធភាព និងកាត់បន្ថយចំណាយប្រតិបត្តិការក្នុងស្ថាប័នដែលមិនពាក់ព័ន្ធ។

មតិយោបល់៖

ដើម្បីជំរុញការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព រដ្ឋាភិបាលគួរតែផ្តល់អាទិភាពដល់ការវិភាជថវិកាសម្រាប់ការអប់រំ សុខភាពសាធារណៈ និងកិច្ចគាំពារសង្គម ស្របពេលជាមួយកែលម្អការផ្តល់សេវាសាធារណៈផងដែរ។ ថវិកាសុខភាពសាធារណៈអាចត្រូវបានធ្វើឱ្យប្រសើរដោយការលើកទឹកចិត្តដល់កិច្ចសហការរវាងមណ្ឌលសុខភាព និងមេឃុំ/សង្កាត់ ដើម្បីបង្កើនសេវា និងបរិក្ខារសុខាភិបាលនៅតាមមូលដ្ឋាន។ ការដោះស្រាយវិសមភាពនៅតាមជនបទទាមទារការកៀរគរធនធានមនុស្ស និងធានាឱ្យមានលទ្ធភាពទទួលបានសេវាប្រកបដោយសមធម៌។ កម្មវិធីកសាងសមត្ថភាពគួរផ្តោតលើការលើកកម្ពស់សុចរិតភាព គណនេយ្យភាព និងអភិបាលកិច្ចប្រកបដោយក្រមសីលធម៌។ ម៉្យាងវិញទៀត ដើម្បីកាត់បន្ថយការចំណាយសុខភាពប្រជាជនលើជម្ងឺទូទៅឬជម្ងឺមិនឆ្លង រដ្ឋាភិបាលគួរពិចារណាក្នុងការចំណាយថ្លៃពិនិត្យសុខភាពដល់ប្រជាជនទូទៅចាប់ពីអាយុ ៣៥ ដល់ ៥០ឲ្យបាន២ដងក្នុងមួយឆ្នាំ ដើម្បីធានាថាការថែទាំសុខភាពមុនឈានទៅដល់ការចំណាយច្រើន។

**សម្រាប់វិស័យអប់រំ**

- រាជរដ្ឋាភិបាលកម្ពុជា គួរវិភាជថវិកាជាបន្តបន្ទាប់ដល់ចំនួន ២០% នៃចំណាយថ្នាក់ជាតិ លើវិស័យអប់រំ ដូចដែលបានសន្យានៅឆ្នាំ ២០២១។ ទន្ទឹមនឹងនេះ គប្បីខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពខុសគ្នានៃគុណភាពរវាងសាលារៀនឯកជន និងសាលារៀនរដ្ឋនៅទូទាំងប្រទេស។ ការបង្កើនថវិកានេះគប្បីត្រូវបានវិនិយោគលើការពង្រឹងគុណភាពនៃការអប់រំ (ទាំងគុណភាពនៃការរៀនសូត្រ និងគុណភាពនៃការបង្រៀន) ជាពិសេស ការអប់រំមូលដ្ឋានរយៈ

ពេលប្រាំបួនឆ្នាំ។ កុមារគប្បីទៅរៀននៅសាលារៀនល្អៗនោះគឺ "សាលារៀនគំរូ" នៅក្នុងទីតាំងដែលពួកគេអាចធ្វើដំណើរទៅដល់បាន ហេតុនេះ រាជរដ្ឋាភិបាលគប្បីវិនិយោគលើការគាំទ្រដល់សាលារៀននៅតាមទីជនបទ ដើម្បីឱ្យក្លាយទៅជា "សាលារៀនគំរូ"។

មតិយោបល់សំខាន់ៗ៖

- ធានាបាននូវលទ្ធភាពទទួលបានការអប់រំរយៈពេលប្រាំបួនឆ្នាំសម្រាប់កុមារទាំងអស់ រួមទាំងមានការគាំទ្របន្ថែមសម្រាប់ក្រុមជួបការលំបាកក្រោយជំងឺកូវីដ-១៩។
- បែងចែកថវិកាសម្រាប់ការជួសជុលសាលារៀន ហេដ្ឋារចនាសម្ព័ន្ធ សៀវភៅសិក្សា និងការកែលម្អបច្ចេកវិទ្យា។
- ការពង្រឹងការបណ្តុះបណ្តាលគ្រូបង្រៀនដោយប្រើប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត (CPD) និងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់នាយកសាលា និងគ្រូបង្រៀន។
- កៀរគរធនធាន និងភាពជាដៃគូជាមួយសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍ ដើម្បីបង្កើនគុណភាពអប់រំ។
- ការលើកកម្ពស់តម្លាភាព និងការផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអំឡុងពេលផ្ទេរមុខងារ និងធនធាន។

សម្រាប់វិស័យកិច្ចគាំពារសង្គម៖

រាជរដ្ឋាភិបាលគប្បីពង្រីកវិសាលភាព និងសមធម៌នៃគោលនយោបាយកិច្ចគាំពារសង្គម ដើម្បីគ្របដណ្តប់ទៅដល់ក្រុមងាយរងគ្រោះ ដូចជាអ្នកទាំងឡាយដែលធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មនុស្សចាស់ ជនមានពិការភាព និងសហគមន៍ជនជាតិដើម។ គោលនយោបាយទាំងនេះគប្បីចាត់អាទិភាពលើសន្តិសុខប្រាក់ចំណូល សម្រាប់យុវជន ពលករចំណាកស្រុក និងជនអត់ការងារធ្វើ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពង្រីកការគ្របដណ្តប់នៃកិច្ចគាំពារសង្គមទៅដល់សហគ្រាសមីក្រូខ្នាតតូច និងមធ្យម (MSMEs) និងកសិករម្ចាស់ចម្ការតូចៗនៅក្នុងវិស័យនានា ដូចជា ចម្ការកៅស៊ូ អំពៅ ចេក និងវិស័យកសិកម្មផ្សេងទៀត។ ការតម្រូវឲ្យបានទាំងស្រុងអំពីការពង្រឹងការអនុវត្តកាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម និងនិយោជក ចំពោះការផ្តល់នូវរបបសន្តិសុខសង្គមដល់និយោជិត តាមរយៈការដាក់ចេញនូវការអនុវត្តច្បាប់កាន់តែម៉ឺងម៉ាត់ពីសំណាក់ មន្ត្រី ប.ស.ស និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងធានាបានថាបុគ្គលទាំងនេះអាចទទួលបានអត្ថប្រយោជន៍ពីវិធានការកិច្ចគាំពារសង្គម។

មតិយោបល់សំខាន់ៗ៖

- វិភាជថវិកា ៥,១% នៃ GDP ដល់កិច្ចគាំពារសង្គម តាមអនុសាសន៍សកលសម្រាប់ប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។
- ការបង្កើនថវិកាសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ចាស់ជរា និងជនពិការ រួមទាំងការពិនិត្យឡើងវិញនូវគោលនយោបាយសោធននិវត្តន៍ និងការបង្កើតមណ្ឌលថែទាំសុខភាព។
- ការពង្រីកអត្ថប្រយោជន៍ថែទាំសុខភាពរបស់បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីបង្កើនគុណភាពសេវាកម្ម ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា និងការជឿទុកចិត្ត។
- សាកល្បងគម្រោងវិភាគទាន និងឧបត្ថម្ភធនសម្រាប់កម្មករក្រៅផ្លូវការ និងកសិករខ្នាតតូច ដើម្បីបង្កើនបរិយាប័ន្ន និងនិរន្តរភាព។
- ផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ហិរញ្ញវត្ថុ និងសវនកម្មរបស់ បេឡាជាតិរបបសន្តិសុខសង្គម និងមូលនិធិជំនួយសង្គមជាតិ ដើម្បីធានាតម្លាភាព។
- កំណត់អង្គភាពស្ថាប័នដែលទទួលខុសត្រូវចំពោះគោលនយោបាយគាំពារសង្គម ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកាក្រោមគណនីរង ៦២០២៨ ដែលគាំទ្រដល់ប្រយោជន៍សាធារណៈ។
- វាយតម្លៃ និងធ្វើវិសោធនកម្មប្រចាំលើការងារចំណាយថវិកា របស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យមានប្រសិទ្ធភាព និងតម្លាភាព គណនេយ្យភាព កាត់បន្ថយអំពើពុករលួយ។

## VIII. ស្ថាប័នត្រួតពិនិត្យ៖

ឯកតា លានរៀល

| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | | | | | | | | | | | | | | ប្រែប្រួលថវិកា (%) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2019 | | 2020 | | 2021 | | 2022 | | 2023 | | 2024 | | 2025 | | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
| សរុបថវិកាចំណាយថ្នាក់ជាតិ | 25,765,028.0 | % | 31,095,855.0 | % | 30,491,336.0 | % | 32,576,866.0 | % | 36,603,698.0 | % | 34,497,444.0 | % | 35,398,175.0 | % | | | | | | |
| រដ្ឋសភា | 183,783.0 | 0.71% | 193,937.0 | 0.62% | 162,699.0 | 0.53% | 200,586.0 | 0.62% | 211,120.0 | 0.58% | 219,313.0 | 0.64% | 191,643.00 | 0.54% | 5.52% | -16.11% | 23.29% | 5.25% | 3.88% | -12.62% |
| ព្រឹទ្ធសភា | 87,233.0 | 0.34% | 87,309.0 | 0.28% | 76,052.0 | 0.25% | 69,866.0 | 0.21% | 74,021.0 | 0.20% | 86,003.0 | 0.25% | 97,995.00 | 0.28% | 0.09% | -12.89% | -8.13% | 5.95% | 16.19% | 13.94% |
| អាជ្ញាធរសវនកម្មជាតិ | 14,905.0 | 0.06% | 14,986.0 | 0.05% | 12,948.0 | 0.04% | 12,310.0 | 0.04% | 13,837.0 | 0.04% | 15,313.0 | 0.04% | 15,880.0 | 0.04% | 0.54% | -13.60% | -4.93% | 12.40% | 10.67% | 3.70% |
| ស្ថាប័នប្រយុទ្ធប្រឆាំងអំពើពុករលួយ | 46,536.4 | 0.18% | 50,815.0 | 0.16% | 42,549.0 | 0.14% | 41,872.0 | 0.13% | 48,442.0 | 0.13% | 52,549.0 | 0.15% | 55,216.0 | 0.16% | 9.19% | -16.27% | -1.59% | 15.69% | 8.48% | 5.08% |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០១៩ ដល់ ២០២៥

នៅកម្ពុជា អង្គភាពត្រួតពិនិត្យចម្បងៗរួមមានព្រឹទ្ធសភា និងរដ្ឋសភា និងស្ថាប័នត្រួតពិនិត្យផ្សេងទៀតដូចជា អាជ្ញាធរសវនកម្មជាតិ និងការិយាល័យអធិការកិច្ចហិរញ្ញវត្ថុ និងស្ថាប័នប្រឆាំងអំពើពុករលួយ ជាដើម។ ដោយសាររាជរដ្ឋាភិបាលអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ របស់ខ្លួន ដែលផ្តោតលើគណនេយ្យភាព សមិទ្ធិកម្ម ស្ថាប័នត្រួតពិនិត្យចាំបាច់ត្រូវអនុវត្តភារកិច្ចរបស់ខ្លួនដោយឯករាជ្យ និងតម្លាភាព ដើម្បីធានាគណនេយ្យភាពសាធារណៈកាន់តែខ្លាំងពាក់ព័ន្ធនឹងការប្រើប្រាស់ថវិការដ្ឋ។

ការអង្កេតអំពីថវិកា បើកចំហ (Open Budget Survey) ដែលបង្កើតឡើង ដោយអង្គការភាពជាដៃគូថវិកាអន្តរជាតិ (International Budget Partnership) បានវាយតម្លៃមុខងារត្រួតពិនិត្យរបស់កម្ពុជានៅខ្សោយនៅឡើយ។ នៅឆ្នាំ២០២១ និង ២០២៣ កម្ពុជាបានទទួលពិន្ទុតែ ៥០/១០០ប៉ុណ្ណោះ ទៅលើការត្រួតពិនិត្យថវិកា។[27] លទ្ធផលនៃការអង្កេតនេះបានបង្ហាញថា អង្គនីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូលនៅកម្ពុជាធ្វើការត្រួតពិនិត្យតិចតួចខ្លាំងណាស់ទៅលើដំណាក់កាលទាំងអស់នៃដំណើរការថវិកា។ មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាផ្តល់សិទ្ធិដល់តំណាងរាស្ត្រក្នុងការដាក់សំណួរជាលាយលក្ខណ៍អក្សរដល់មន្ត្រីរដ្ឋាភិបាល ដោយត្រូវតែបញ្ជូនទៅប្រធានរដ្ឋសភាជាមុន។ រដ្ឋមន្ត្រីម្នាក់ឬច្រើននាក់ត្រូវឆ្លើយសំណួរនោះ។ ប្រសិនបើសំណួរនោះផ្តោតគោលដៅលើគោលនយោបាយជារួមរបស់រដ្ឋាភិបាលនាយករដ្ឋមន្ត្រីត្រូវ ឆ្លើយតប។ មន្ត្រីរដ្ឋាភិបាលអាចឆ្លើយតបដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរនៅក្នុងរយៈពេលប្រាំពីរថ្ងៃ។ ក្នុងករណីឆ្លើយតបដោយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចចិត្តថា តើត្រូវរៀបចំការជជែកដេញដោលដោយបើកចំហទៅលើបញ្ហានោះដែរ ឬទេ។ បើទោះបីជាសេចក្តីសម្រេច អនុញ្ញាតឱ្យមានកិច្ចពិភាក្សារវាងតំណាងរាស្ត្រ និងមន្ត្រីរដ្ឋាភិបាលក្តី ចម្លើយឆ្លើយតបពីរបស់មន្ត្រីរដ្ឋាភិបាលនឹងបញ្ចប់ការសួរដេញដោល ។ ចំណុចនេះក៏អនុវត្តចំពោះចម្លើយជាលាយលក្ខណ៍អក្សរផងដែរ ដោយសារចម្លើយនេះត្រូវបានចាត់ទុកថាជាចម្លើយចុងក្រោយ។

ការធានាបានថា អង្គនីតិប្បញ្ញត្តិអាចទទួលបានធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានភស្តុភារដែលចាំបាច់សម្រាប់ការប្រតិបត្តិមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព គឺជាការចាំបាច់។ ថវិកាសម្រាប់អង្គនីតិប្បញ្ញត្តិត្រូវបានការធានានៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែគ្មានការបញ្ជាក់អំពីចំនួនអប្បបរមាឡើយ។ ថវិកាសម្រាប់អង្គនីតិប្បញ្ញត្តិត្រូវបានបញ្ចូលនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ដែលគេហៅជាទូទៅថាថវិកាជាតិប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងច្បាប់នេះ ហើយមុនពេលសេចក្តីព្រាងច្បាប់សម្រេចគណៈរដ្ឋមន្ត្រី គ្មានបទប្បញ្ញត្តិកំណត់ឱ្យមានការពិគ្រោះយោបល់ជាមួយអង្គនីតិប្បញ្ញត្តិនៅដំណាក់កាលរៀបចំសេចក្តីព្រាងច្បាប់នេះឡើយ។ ចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៥ ថវិកាវិភាជន៍នីតិបញ្ញត្តិ ជាមធ្យម 0.៦% នៃថវិកាថ្នាក់ជាតិ។ នៅឆ្នាំ ២០២៥ ភាគរយនៃថវិកានេះថយចុះបន្តិចពី 0.៦៤% ក្នុងឆ្នាំ ២០២៤ មកត្រឹម 0.៥៤% ដែលឆ្លុះបញ្ចាំងពីការធ្លាក់ចុះ ១២% បើប្រៀបធៀបចំនួនថវិកាឆ្នាំ២០២៤ ខណៈពេលចំនួនថវិការបស់ព្រឹទ្ធសភាបានកើនឡើង ១៣%។

27 https://internationalbudget.org/open-budget-survey/country-results/2021/cambodia

អាជ្ញាធរសវនកម្មជាតិ (NAA) ដែលមានភារកិច្ចធ្វើសវនកម្មអង្គភាពរដ្ឋាភិបាល និងលើកកម្ពស់តម្លាភាពហិរញ្ញវត្ថុ ទទួលបានត្រឹមតែ ០.០៤% (៣.៩ លានដុល្លារអាមេរិក) នៃថវិកាឆ្នាំ ២០២៥ ។ ថវិកាដែលវិភាជឲ្យស្ថាប័ននេះ នៅតែមិនប្រែប្រួលចាប់តាំងពីឆ្នាំ ២០១៩ ដោយមានការកើនឡើងតិចតួចគឺ៣% នៅឆ្នាំ ២០២៥។ ថវិការបស់ NAA មានចំនួនតិចជាងថវិកានៃស្ថាប័នប្រឆាំងអំពើពុករលួយចំនួនប្រមាណ០៤ដង។ នេះ ធ្វើឲ្យមានការព្រួយបារម្ភអំពីសមត្ថភាពរបស់ស្ថាប័ននេះក្នុងការបំពេញអាណត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**មតិយោបល់៖**

- ស្ថាប័ននីតិប្បញ្ញត្តិដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យការចំណាយ និងចំណូលសាធារណៈ។ CSO BWG ផ្តល់អនុសាសន៍ឱ្យមានការចូលរួមរបស់ស្ថាប័នរដ្ឋសភាឲ្យកាន់តែពេញលេញក្នុងវដ្តថវិកាទាំងមូល - ពីការកសាងផែនការថវិកា រហូតដល់ការអនុវត្ត និងការត្រួតពិនិត្យ ជាជាងផ្តោតតែលើសវនកម្មក្រោយពេលអនុវត្តចប់។
- ដើម្បីបង្កើនការធ្វើសេចក្តីសម្រេចប្រកបដោយការយល់ដឹង តាមរយៈការបង្កើតការិយាល័យថវិការបស់សភា នៅព្រឹទ្ធសភា និងរដ្ឋសភាដែលមានធនធានគ្រប់គ្រាន់ដើម្បីឱ្យការិយាល័យនេះបំពេញមុខងារប្រកបដោយប្រសិទ្ធភាព។
- រដ្ឋាភិបាលគួរពង្រឹង វិតបន្តឹងលើប្រព័ន្ធត្រួតពិនិត្យការចំណាយថវិកាសូមឲ្យមានតម្លាភាព និងមានវិធានការលើមន្ត្រីខិលខូច ដោយប្រើប្រាស់ច្បាប់ប្រយុទ្ធប្រឆាំងអំពើរពុករលួយ។

IX. **ការប្រើប្រាស់កម្ចីបរទេសទៅលើការវិនិយោគសាធារណៈសំខាន់ៗ៖** នៅឆ្នាំ ២០២៥ ការចំណាយមូលធនរបស់កម្ពុជាសម្រាប់ហិរញ្ញប្បទានវិនិយោគ ក្នុងស្រុក ត្រូវបានព្យាករណ៍ថា មានចំនួន ១.២៣៤,៩៧ លានដុល្លារអាមេរិក ដូចគ្នាទៅនឹងឆ្នាំ ២០២៤ បន្ទាប់ពីធ្លាក់ចុះ ៣៩% ពីឆ្នាំ ២០២៣។ គម្រោងវិនិយោគផ្ទាល់ដែលផ្តល់មូលនិធិដោយចំណូលក្នុងស្រុកតែមួយគត់ ថយចុះយ៉ាងខ្លាំងចំនួន៣៧% ស្មើនឹង ២០ លានដុល្លារអាមេរិក។ នេះប៉ះពាល់ដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងការបង្កើនការពឹងផ្អែកលើជំនួយ និងការខ្ចីប្រាក់ពីបរទេស។

| ក្រសួង/ ស្ថាប័នរដ្ឋ | ការវិភាគថវិកាជា % នៃកម្ចីបរទេស សម្រាប់ការវិនិយោគសាធារណៈ (២០១៨-២០២៥) | | | | | | | |
|---|---|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
| រដ្ឋសភាជាតិ | 0.00 | 0.00 | 0.00 | 0.00 | 0.46 | 0.32 | 0.52 | N/A |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 3.19 | 2.59 | 1.67 | 1.74 | 1.73 | 1.71 | 0.05 | N/A |
| ក្រសួងអធិការកិច្ច | 0.00 | 0.02 | 0.02 | 0.05 | 0.02 | 0.04 | N/A | N/A |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 0.35 | 0.61 | 0.33 | 0.16 | 0.23 | 0.31 | 0.33 | 1.29 |
| ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | 0.25 | 0.53 | 0.33 | 0.49 | 0.52 | 1.40 | 1.31 | 0.89 |
| ស្ថាប័នប្រឆាំងអំពើពុករលួយ | 0.02 | 0.01 | 0.02 | N/A | N/A | N/A | N/A | N/A |
| ក្រសួងមុខងារសាធារណៈ | 0.01 | 0.02 | 0.01 | 0.11 | 0.02 | 0.07 | N/A | N/A |
| ក្រសួងមហាផ្ទៃ-អគ្គនាយកដ្ឋានរដ្ឋបាល | 1.04 | 1.41 | 0.64 | 0.49 | 1.55 | 1.23 | 0.85 | 2.20 |
| ក្រសួងយុត្តិធម៌ | 0.20 | 0.13 | 0.11 | 0.13 | 0.12 | 0.13 | N/A | N/A |
| ក្រសួងព័ត៌មាន | 0.09 | 0.05 | 0.36 | 0.12 | 0.08 | 0.15 | N/A | N/A |
| ក្រសួងសុខាភិបាល | 12.62 | 5.17 | 7.71 | 9.28 | 13.09 | 9.52 | 5.96 | 6.52 |
| ក្រសួងអប់រំ យុវជន និងកីឡា | 6.87 | 8.12 | 5.71 | 3.44 | 2.54 | 2.56 | 3.80 | 4.44 |
| ក្រសួងធម្មការ និងសាសនា | 0.01 | N/A | N/A | N/A | N/A | N/A | N/A | N/A |
| ក្រសួងកិច្ចការនារី | 0.03 | N/A | N/A | N/A | N/A | N/A | N/A | N/A |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 0.25 | 0.47 | 1.07 | 2.07 | 0.63 | 1.83 | 1.64 | 1.77 |
| រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 0.19 | 0.37 | 0.66 | 0.31 | 0.00 | 0.13 | N/A | N/A |
| ក្រសួងរ៉ែ និងថាមពល | 15.45 | 8.65 | 8.33 | 12.22 | 13.53 | 6.50 | 9.04 | 9.97 |
| ក្រសួងពាណិជ្ជកម្ម | 1.16 | 1.34 | 2.11 | 2.62 | 2.56 | 3.18 | 0.98 | 1.77 |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 3.11 | 3.48 | 5.35 | 7.13 | 3.32 | 5.98 | 5.50 | 6.74 |
| ក្រសួងអភិវឌ្ឍន៍ជនបទ | 6.94 | 7.06 | 4.66 | 6.16 | 9.31 | 11.01 | 15.01 | 14.89 |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 0.44 | 0.39 | 0.76 | 3.34 | 0.30 | 3.35 | 2.62 | 2.96 |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | 33.71 | 39.50 | 38.47 | 31.80 | 32.16 | 32.96 | 34.29 | 28.02 |
| ក្រសួងទេសចរណ៍ | 0.74 | 1.19 | 1.02 | 0.79 | 0.43 | 0.49 | 0.36 | N/A |
| ក្រសួងធនធានទឹក និងឧតុនិយម | 10.68 | 11.31 | 13.27 | 10.77 | 7.08 | 7.67 | 11.13 | 14.98 |
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 1.95 | 6.88 | 6.75 | 5.92 | 9.34 | 8.41 | 5.30 | 2.96 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០១៨ ដល់ ២០២៥

បំណុលសាធារណៈបានកើនឡើងជាបន្តបន្ទាប់ពី ៦,៧៩៧ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៨ ដល់ ១២,៨៥ពាន់លានដុល្លារក្នុងឆ្នាំ ២០២៤។ ហើយត្រូវបានគេព្យាករណ៍ថានឹងកើនឡើងដល់ ១៣,៧០ពាន់លានដុល្លារក្នុងឆ្នាំ ២០២៥។ រដ្ឋាភិបាលគ្រោងនឹងចំណាយ ១.៦៨៨ លានដុល្លារក្នុងឆ្នាំ ២០២៥ លើគម្រោងវិនិយោគសាធារណៈ ពោលគឺកើនឡើង ១០% ពីឆ្នាំ២០២៤ ហើយភាគច្រើនលើសលុបជាប្រាក់កម្ចីពីបរទេស។ ខណៈពេលដែលការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគឺគួរឱ្យអបអរសាទរ តម្លាភាព គណនេយ្យភាព និងគោលនយោបាយមិនអត់ឱនចំពោះអំពើពុករលួយមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងថវិកានេះប្រកបដោយប្រសិទ្ធភាព។

ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) ទទួលបានចំណែកវិភាគច្រើនជាងគេពីប្រាក់កម្ចីបរទេសសម្រាប់ការវិនិយោគសាធារណៈក្នុងឆ្នាំ ២០២៥ គឺ ២៨% ។ ក្រសួងអភិវឌ្ឍន៍ជនបទ និងធនធានទឹកទទួលបានចំណែកបន្ទាប់គឺ ១៤% ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់រដ្ឋាភិបាលលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធប្រើប្រាស់។

ផ្ទុយទៅវិញ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ប្រឈមនឹងការថយចុះពី ៩,៣៤% ក្នុងឆ្នាំ ២០២២ មកត្រឹម ២,៩៦% ក្នុងឆ្នាំ ២០២៥។ ដូចគ្នានេះដែរ ថវិកាវិនិយោគលើសុខភាពសាធារណៈបានធ្លាក់ចុះយ៉ាងខ្លាំងពី ១២,៦២% ក្នុងឆ្នាំ ២០១៨ មកនៅត្រឹម ៦,៥២% ក្នុងឆ្នាំ២០២៥។ ការវិនិយោគសាធារណៈការអប់រំ កើនឡើង ពី២,៥៤% ក្នុងឆ្នាំ ២០២២ ដល់ ៤,៤៤% ក្នុងឆ្នាំ ២០២៥ ប៉ុន្តែនៅតែមិនគ្រប់គ្រាន់ ដោយសារតម្រូវការក្នុងការអភិវឌ្ឍន៍ធនធានមនុស្សដែលមានជំនាញ។ ទន្ទឹមនឹងនេះ ថវិកាវិភាគរបស់ក្រសួងមហាផ្ទៃកើនឡើងពី ០,៨៥% ក្នុងឆ្នាំ ២០២៤ ដល់ ២,២០% ក្នុងឆ្នាំ ២០២៥។

ដើម្បីធានាបាននូវការគ្រប់គ្រងថវិកាកម្ចីបរទេសបានត្រឹមត្រូវ រដ្ឋាភិបាលត្រូវពង្រឹងការអនុវត្តលទ្ធកម្មសាធារណៈ ដើម្បីតម្លាភាពក្នុងគម្រោងវិនិយោគសាធារណៈ។ ការអនុលោមតាមស្តង់ដារលទ្ធ

កម្មមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តគម្រោងសាធារណៈ និង BOT ព្រោះការខកខានមិនបានបំពេញតាមស្តង់ដារទាំងនេះបង្កឱ្យមានហានិភ័យសង្គម និងសេដ្ឋកិច្ចយ៉ាងសំខាន់។

រដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពដល់ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការវិនិយោគសាធារណៈ និងកិច្ចព្រមព្រៀង BOT ជាពិសេសជាមួយក្រុមហ៊ុនសាជីវកម្មនៃប្រទេសចិន។ ទោះជាយ៉ាងណា វិធីសាស្រ្តលទ្ធកម្មរបស់ប្រទេសចិនប្រឈមនឹងការរិះគន់ចំពោះការខ្វះតម្លាភាព[28]។ ការធានាបាននូវភាពបើកចំហ និងសុចរិតភាពក្នុងលទ្ធកម្ម គឺចាំបាច់ណាស់ក្នុងការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងអំឡុងពេលនៃការផ្ទេរគម្រោងក្រោយគម្រោង។ បញ្ហាប្រឈមរួមមានការមិនផ្សព្វផ្សាយ កិច្ចសន្យាជាសាធារណៈស្តីពីគម្រោង BOT ដូចជាគម្រោងព្រលានយន្តហោះ ដែលដាក់នូវដែនកំណត់ចំពោះការត្រួតពិនិត្យ និងគណនេយ្យភាពជាសាធារណៈ។

**មតិយោបល់៖**

- ការប្រើប្រាស់ប្រាក់កម្ចីប្រកបដោយប្រសិទ្ធភាពគឺចាំបាច់ដើម្បីជៀសវាងការជាប់បំណុល និងធានាបាននូវអត្ថប្រយោជន៍រយៈពេលវែង។ ការវិនិយោគគួរតែផ្តល់អាទិភាពដល់គម្រោងដែលអាចសម្រេចបានផ្នែកសេដ្ឋកិច្ច លើកកំពស់សុខុមាលភាពសង្គម និងគាំទ្រដល់ក្រុមដែលងាយរងគ្រោះរួមមានស្រ្តី កុមារ និងមនុស្សចាស់។ រាជរដ្ឋាភិបាលគប្បីប្រើប្រាស់កម្ចីជាលក្ខណៈយុទ្ធសាស្រ្ត ដើម្បីបង្កើតភាពរីកចម្រើនរយៈពេលវែងលើផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ គឺជារឿងសំខាន់ ដើម្បីពង្រឹងការភ្ជាប់ទំនាក់ទំនង និងភាពប្រកួតប្រជែងសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយបន្ទុកចំណាយផ្នែកភស្តុភារ និងផលិតកម្ម។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគប្បីកើតឡើងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងគម្រោងនៅថ្នាក់ឃុំសង្កាត់ ដូចជា បណ្តាញដឹកជញ្ជូន ការផ្គត់ផ្គង់ទឹក អគ្គិសនី និងការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត។
- រាជរដ្ឋាភិបាលគប្បីអនុវត្តគោលនយោបាយដែលមិនអត់ឱនចំពោះអំពើពុករលួយ គឺ ចាំបាច់នៅក្នុងការគ្រប់គ្រងថវិកាសាធារណៈ។ តម្លាភាពដំណើរការលទ្ធកម្មសាធារណៈ សវនកម្មឯករាជ្យ និងការបង្ហាញជាសាធារណៈនូវកិច្ចសន្យា កិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងសាធារណៈ និង BOT គឺចាំបាច់ដើម្បីធានាឱ្យមានគណនេយ្យភាព និងការចូលរួមជាសាធារណៈ។
- រដ្ឋាភិបាលគួរមានការប្រុងប្រយ័ត្នខ្ពស់ចំពោះកម្ចីណាដែលបានផ្តល់ហានិភ័យដល់ប្រទេសជាតិទាំងមូល និងមានផលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរបស់ខ្លួន និងប៉ាន់ប្រមាណសមត្ថភាពកម្រិតចំណូលជាតិប្រចាំឆ្នាំ និងចំណាយប្រចាំឆ្នាំ និងការសងត្រឡប់ទៅឲ្យគេវិញ។

[28] Craig Fagan (2011), op. cit.

- រដ្ឋាភិបាលគួរយកកម្ចីណាដែលជួយសម្រាលដល់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ផ្នែកសេដ្ឋកិច្ច ឬចរន្តសេដ្ឋកិច្ចដែលប្រជាពលរដ្ឋរបស់ខ្លួនកំពុងអាស្រ័យផល ពឹងផ្អែកលើសេដ្ឋកិច្ចរបស់ពួកគាត់ប្រចាំថ្ងៃ ជាឧទាហរណ៍ផ្នែកកសិកម្មជាដើម។
- រដ្ឋាភិបាលគួរពិចារណាលើការសាងសង់ផ្លូវ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើយ៉ាងណាកុំឲ្យមានការចំណាយប្រចាំឆ្នាំរហូត និងបង្កើនគុណភាពផ្លូវឲ្យបានរឹងមាំ យូរអង្វែង កុំឲ្យថវិកាជាតិរវល់តែគិតលើហេដ្ឋារចនាសម្ព័ន្ធប្រចាំ នោះថវិកាជាតិនិងមិនការអភិវឌ្ឍ អាទិភាពផ្សេងទៀតបានច្រើនទៀតទេនៅឆ្នាំបន្ទាប់។

## X. តម្លាភាព និងគណនេយ្យភាពថវិកា៖

រដ្ឋាភិបាលមានទំនួលខុសត្រូវយ៉ាងសំខាន់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិជាតិ ប្រាក់កម្ចីពីបរទេស និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព ដោយសារប្រជាពលរដ្ឋរបស់ខ្លួននៅទីបំផុតត្រូវទទួលបន្ទុកនៃការសងបំណុល។ គណនេយ្យភាព និងតម្លាភាពមានសារៈសំខាន់ក្នុងការកសាងទំនុកចិត្តសាធារណៈ និងធានាការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ជៀសវាងវិបត្តិទាក់ទងនឹងបំណុល ឬការថយចុះធនធានទាំងនោះ។

ស្របពេលដែលបានចេញផ្សាយជាសាធារណៈនូវសេចក្តីព្រាងច្បាប់ថវិកាពេញលេញ ការខិតខំប្រឹងប្រែងមួយចំនួនដូចជាការផលិត និងផ្សព្វផ្សាយថវិកាសង្ខេប និងការរៀបចំវេទិកាសាធារណៈគួរជាទីអបអរសារទរ។ ប៉ុន្តែការមិនចេញផ្សាយនូវសេចក្តីសង្ខេបប្រតិបត្តិនៃសេចក្តីព្រាងច្បាប់ថវិកាក្នុងឆ្នាំ២០២៥ បង្កឲ្យមានឧបសគ្គដល់ការទទួលបានព័ត៌មានរបស់សាធារណៈ និងភាគីពាក់ព័ន្ធអំពីសូចនាករសេដ្ឋកិច្ចសំខាន់ៗនៃការរៀបចំថវិកា។ ការបង្កើត MTFF ២០២៥-២០២៧ គឺជាជំហានវិជ្ជមានមួយ ប៉ុន្តែតម្លាភាពអាចត្រូវបានពង្រឹងបន្ថែមទៀតដោយការចេញផ្សាយឯកសារថវិកាសំខាន់ៗទាំងប្រាំបីឲ្យបានទាន់ពេលវេលា និងការចូលរួមពីភាគីពាក់ព័ន្ធក្នុងអំឡុងពេលកសាង អនុវត្ត និងការវាយតម្លៃថវិកា។

រដ្ឋាភិបាលគួរដាក់ចេញនូវយុទ្ធសាស្ត្រស្តីពីការចូលរួមជាសាធារណៈប្រកបដោយភាពច្នៃប្រតិដ្ឋ ដូចជាវេទិកាអនឡាញ ដោយរៀនសូត្រពីការអនុវត្តល្អបំផុតពីបណ្តាប្រទេសក្នុងតំបន់។ សវនកម្មខាងក្រៅ វិធានការបង្ការអំពើពុករលួយ និងការធ្វើបង្ហាញព័ត៌មានអំពីចំណាត់ថ្នាក់ថវិកាលម្អិតនៅថ្នាក់ក្រោមជាតិ គឺចាំបាច់ ដើម្បីពង្រឹងគណនេយ្យភាព និងការទទួលបានព័ត៌មានជាសាធារណៈ។

**មតិយោបល់៖**

រដ្ឋាភិបាលចាំបាច់ បង្កើតវេទិកាអនឡាញ ដើម្បីប្រមូល និងបញ្ចូលមតិសាធារណជនទៅក្នុងគោលនយោបាយសារពើពន្ធ និងការកសាងផែនកាថវិកា ហើយជំរុញឱ្យមានមានតម្លាភាព និងរួមបញ្ចូលនូវធាតុចូលកាន់តែប្រសើរឡើងក្នុងដំណើរការថវិកា។

រដ្ឋាភិបាលចាំបាច់បើកចំហព័ត៌មានថវិកា និងព័ត៌មានលទ្ធកម្មសាធារណៈ ប្រកបដោយតម្លាភាព គណនេយ្យភាព តាមរយៈប្រព័ន្ធអនឡាយ ឬការផ្សព្វផ្សាយជាសាធារណៈផ្សេងៗ ដើម្បីឲ្យប្រជាពលរដ្ឋបានដឹង និងចូលរួមធ្វើសេចក្តីសម្រេចចិត្ត មតិកែកម្មលើចំណូលចំណាយ សាធារណៈផ្សេងរបស់រដ្ឋ ដើម្បីកាត់បន្ថយចំណាយណាដែលឥតប្រយោជន៍ បង្កើនចំណាយណាដែលមានប្រយោជន៍សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរបស់ខ្លួនកាន់តែប្រសើរ

## XI. ការចំណាយមិនបានគ្រោងទុក (ថវិកាបម្រុង)៖

ឯកតា លានរៀល

| សេចក្តីបរិយាយ | ឆ្នាំ2019 | | ឆ្នាំ2020 | | ឆ្នាំ2021 | | ឆ្នាំ2022 | |
|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| សរុបចំណាយថ្នាក់ជាតិ | 25,765,028.00 | | 31,095,855.00 | | 30,491,336.00 | | 32,576,866.00 | |
| ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | 5,006,459.00 | 19.43 | 8,592,575.00 | 27.63 | 10,322,966.00 | 33.86 | 11,591,345.00 | 35.58 |
| ចំណាយមិនបានគ្រោងទុក | 1,069,010.00 | 4.15 | 838,884.00 | 2.70 | 697,000.00 | 2.29 | 1,618,264.00 | 4.97 |

| សេចក្តីបរិយាយ | ឆ្នាំ2023 | | ឆ្នាំ2024 | | ឆ្នាំ2025 | | ប្រែប្រួល2024-2025 | |
|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| សរុបចំណាយថ្នាក់ជាតិ | 36,603,698.00 | | 34,497,444.00 | | 35,398,175.00 | | 900,731.00 | 2.61 |
| ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | 11,409,580.40 | 31.17 | 8,335,304.70 | 24.16 | 8,770,872.90 | 24.78 | 435,568.20 | 5.23 |
| ចំណាយមិនបានគ្រោងទុក | 1,713,847.00 | 4.68 | 2,454,267.00 | 7.11 | 1,672,599.50 | 4.73 | -781,667.50 | -31.85 |

ប្រភព: ច្បាប់ថវិកាជាតិ ឆ្នាំ២០១៩ ដល់ ២០២៥

នៅឆ្នាំ២០២៤ ថវិកា ចំណាយមិនបានគ្រោងទុក (ថវិកាបម្រុង) ត្រូវបានព្យាករណ៍ថាមានចំនួន ៦០៣,៧៥ លានដុល្លា ស្មើនឹង ៤,៧៣%នៃថវិកាថ្នាក់ជាតិ ដែលថយចុះពី ៧,១១% នៅឆ្នាំ ២០២៤។ ការធ្លាក់ចុះនេះ បន្ទាប់ពីការប្រែប្រួលជាច្រើនឆ្នាំ ធ្វើឲ្យធ្លាក់ចុះឱនភាពថវិកា។ ការចំណាយមិនបានគ្រោងទុកបានឈានដល់ ៤,៩៧% ក្នុងឆ្នាំ ២០២២ និង ៧,១១% ក្នុងឆ្នាំ ២០២៤ បន្ទាប់ពីអាត្រាជា មធ្យមនៅ ២,៧០% និង ២,២៩% ក្នុងឆ្នាំ ២០២០ និង ២០២១។

បើទោះបីជាមានភាពសមហេតុផលចំពោះការវិភាជការចំណាយមិនបានគ្រោងទុកសម្រាប់ឆ្លើយតបបញ្ហាគ្រោះអាសន្ន រាជរដ្ឋាភិបាលចាំបាច់ត្រូវប្រកាន់អនុលោមទៅតាមលក្ខខណ្ឌសំខាន់ៗឲ្យបានម៉ឺងម៉ាត់ និងធានាថាថវិកានេះស្ថិតក្រោមការគ្រប់គ្រង និងប្រើប្រាស់ ត្រឹមត្រូវស្រមតាមនីតិវិធីហិរញ្ញវត្ថុ ដើម្បីការពារភាពមិនប្រក្រតី។ សវនកម្ម និងការត្រួតពិនិត្យឯករាជ្យដោយស្ថាប័ននានាដូចជា

សភា គឺជាកត្តាសំខាន់សម្រាប់ធានានូវសុចរិតភាព។ ការបង្កើតបទប្បញ្ញត្តិកាតព្វស្តីអំពីការប្រើប្រាស់ថវិកាទាំងនេះអាចលើកកម្ពស់តម្លាភាព និងគណនេយ្យភាព។

ដើម្បីបង្កើនការជឿទុកចិត្តរបស់សាធារណជន រដ្ឋាភិបាលគួរតែធានាឱ្យបាននូវការផ្តល់ព័ត៌មានសំខាន់ៗអំពីការចំណាយមិនបានគ្រោងទុក ទៅដល់សាធារណជន ប្រព័ន្ធផ្សព្វផ្សាយ អ្នកពាក់ព័ន្ធ និងស្ថាប័ននីតិប្បញ្ញត្តិ។ បញ្ហាប្រឈមបច្ចុប្បន្នក្នុងការផ្ទៀងផ្ទាត់ការចំណាយទាំងនេះគួរត្រូវយកចិត្តទុកដាក់ដោះស្រាយ ដោយសារការធ្វើការប្រៀបធៀបនៅមានដែនកំណត់ក្នុងការប្រៀបធៀបជាមួយនឹងច្បាប់នៃការទូទាត់ថវិកា។

**មតិយោបល់៖**

- ថវិកាមិនបានគ្រោងទុកប្រចាំឆ្នាំរបស់កម្ពុជា គប្បីត្រូវបានកំណត់នៅត្រឹម ៣% ក្នុងមួយឆ្នាំ ដែលហើយរៀបវិភាជកាន់តែច្រើនដល់វិស័យសំខាន់ៗដូចជា សុខាភិបាល ការអប់រំ កិច្ចគាំពារសង្គម និងថវិកាអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។

## XII. ថវិកាប្រតិបត្តិការសម្រាប់មន្ទីររាជធានី ខេត្ត និងក្រសួងថ្នាក់កណ្តាល៖

នៅឆ្នាំ២០២៥ ៨៣,៦១% នៃការចំណាយប្រតិបត្តិការថ្នាក់ជាតិត្រូវបានវិភាជទៅលើរដ្ឋបាលកណ្តាលថ្នាក់ជាតិ ហើយមានតែ១៦,៣៦% ត្រូវបានវិភាជដល់មន្ទីររាជធានី/ខេត្ត របស់ក្រសួងទាំងអស់។ មន្ទីរ នៃក្រសួងសំខាន់ៗដូចជា ការងារ កសិកម្ម អភិវឌ្ឍន៍ជនបទ និងសាធារណៈការ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាសាធារណៈ និងជំរុញកំណើនសេដ្ឋកិច្ច។

ឯកតា លានរៀល

| ការវិភាជចំណាយប្រតិបត្តិការឆ្នាំ២០២៥ (%) សម្រាប់ក្រសួងថ្នាក់កណ្តាល និងមន្ទីររាជធានី/ខេត្ត | | | | | |
|---|---|---|---|---|---|
| សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | % | សេចក្តីបរិយាយ | ចំនួនទឹកប្រាក់ | % |
| សរុបរួមចំណាយប្រតិបត្តិការ | 3562461.90 | | ក្រសួងធម្មការ និងសាសនា | 19667.40 | |
| សរុបចំណាយប្រតិបត្តិការក្រសួងថ្នាក់កណ្តាល | 2978398.80 | 83.61 | ក្រសួងថ្នាក់កណ្តាល | 8459.60 | 43.01 |
| សរុបចំណាយប្រតិបត្តិការមន្ទីររាជធានី/ខេត្ត | 584063.10 | 16.39 | មន្ទីររាជធានី/ខេត្ត | 11207.80 | 56.99 |
| ក្រសួងអធិការកិច្ច | 24631.00 | | ក្រសួងកិច្ចការនារី | 24108.00 | |
| ក្រសួងថ្នាក់កណ្តាល | 11974.00 | 48.61 | ក្រសួងថ្នាក់កណ្តាល | 9815.00 | 40.71 |
| មន្ទីររាជធានី/ខេត្ត | 12657.00 | 51.39 | មន្ទីររាជធានី/ខេត្ត | 14293.00 | 59.29 |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 191667.20 | | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 102834.40 | |
| ក្រសួងថ្នាក់កណ្តាល | 173150.20 | 90.34 | ក្រសួងថ្នាក់កណ្តាល | 85817.30 | 83.45 |
| មន្ទីររាជធានី/ខេត្ត | 18517.00 | 9.66 | មន្ទីររាជធានី/ខេត្ត | 17017.10 | 16.55 |
| ក្រសួងផែនការ | 27278.40 | | ក្រសួងរ៉ែ និងថាមពល | 30557.00 | |
| ក្រសួងថ្នាក់កណ្តាល | 13738.40 | 50.36 | ក្រសួងថ្នាក់កណ្តាល | 17322.00 | 56.69 |
| មន្ទីររាជធានី/ខេត្ត | 13540.00 | 49.64 | មន្ទីររាជធានី/ខេត្ត | 13235.00 | 43.31 |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 32931.00 | | ក្រសួងពាណិជ្ជកម្ម | 52616.00 | |
| ក្រសួងថ្នាក់កណ្តាល | 19464.00 | 59.11 | ក្រសួងថ្នាក់កណ្តាល | 38376.00 | 72.94 |
| មន្ទីររាជធានី/ខេត្ត | 13467.00 | 40.89 | មន្ទីររាជធានី/ខេត្ត | 14240.00 | 27.06 |
| ក្រសួងមុខងារសាធារណៈ | 22856.00 | | ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | 98918.10 | |
| ក្រសួងថ្នាក់កណ្តាល | 8856.00 | 38.75 | ក្រសួងថ្នាក់កណ្តាល | 62337.10 | 63.02 |
| មន្ទីររាជធានី/ខេត្ត | 14000.00 | 61.25 | មន្ទីររាជធានី/ខេត្ត | 36581.00 | 36.98 |
| ក្រសួងយុត្តិធម៌ | 91760.00 | | ក្រសួងអភិវឌ្ឍន៍ជនបទ | 185687.00 | |
| មន្ទីររាជធានី/ខេត្ត | 46269.00 | 50.42 | ក្រសួងថ្នាក់កណ្តាល | 152203.00 | 81.97 |
| ក្រសួងព័ត៌មាន | 37864.00 | | មន្ទីររាជធានី/ខេត្ត | 33484.00 | 18.03 |
| ក្រសួងថ្នាក់កណ្តាល | 23709.00 | 62.62 | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 88132.00 | |
| មន្ទីររាជធានី/ខេត្ត | 14155.00 | 37.38 | ក្រសួងថ្នាក់កណ្តាល | 75614.00 | 85.80 |
| ក្រសួងសុខាភិបាល | 169470.00 | | មន្ទីររាជធានី/ខេត្ត | 12518.00 | 14.20 |
| ក្រសួងថ្នាក់កណ្តាល | 161049.00 | 95.03 | ក្រសួងសាធារណការ និងដឹកជញ្ជូន | 367303.00 | |
| ក្រសួងអប់រំ យុវជន និងកីឡា | 326312.90 | | ក្រសួងថ្នាក់កណ្តាល | 347182.00 | 94.52 |
| មន្ទីររាជធានី/ខេត្ត | 166130.30 | 50.91 | មន្ទីររាជធានី/ខេត្ត | 20121.00 | 5.48 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 29724.40 | | ក្រសួងទេសចរណ៍ | 36029.00 | |
| ក្រសួងថ្នាក់កណ្តាល | 15482.40 | 52.09 | ក្រសួងថ្នាក់កណ្តាល | 22936.00 | 63.66 |
| មន្ទីររាជធានី/ខេត្ត | 14242.00 | 47.91 | មន្ទីររាជធានី/ខេត្ត | 13093.00 | 36.34 |
| ក្រសួងបរិស្ថាន | 34534.00 | | ក្រសួងធនធានទឹក និងឧតុនិយម | 135830.00 | |
| ក្រសួងថ្នាក់កណ្តាល | 19775.00 | 57.26 | ក្រសួងថ្នាក់កណ្តាល | 111652.00 | 82.20 |
| មន្ទីររាជធានី/ខេត្ត | 14759.00 | 42.74 | មន្ទីររាជធានី/ខេត្ត | 24178.00 | 17.80 |
| ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | 35158.00 | | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 34580.00 | |
| ក្រសួងថ្នាក់កណ្តាល | 15698.00 | 44.65 | ក្រសួងថ្នាក់កណ្តាល | 21618.00 | 62.52 |
| មន្ទីររាជធានី/ខេត្ត | 19460.00 | 55.35 | មន្ទីររាជធានី/ខេត្ត | 12962.00 | 37.48 |

## XIII. ថវិកាចំណាយលើលាភការ និងប្រាក់បំណាច់នៃមន្ត្រីអំណាចសាធារណៈ (គណនី ៦៤០១)៖

ការចំណាយបន្ទុកបុគ្គលិក ដែលបែងចែកក្រោមការចំណាយជំពូកទី៦៤ បានថយចុះពី ២.១៧១.៩១ លានដុល្លារក្នុងឆ្នាំ ២០២៣ មកត្រឹម ១. ៩៦៩,២០ លានដុល្លារក្នុងឆ្នាំ ២០២៤។ ទោះជាយ៉ាងណាក៏ដោយ ចំណាយសម្រាប់លាភការ និងប្រាក់បំណាច់នៃមន្ត្រីអំណាចសាធារណៈ (អនុគណនេយ្យ៦៤០១) បានកើនឡើង ១១% ។ បន្ទាប់ពីវិសោធនកម្មមាត្រា ១១៨ (ថ្មី) នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជា រដ្ឋលេខាធិការលែងជាសមាជិកគណៈរដ្ឋមន្ត្រីទៀតហើយ ដោយផ្លាស់ប្តូរនីតិវិធីក្នុងការតែងតាំងក៏ត្រូវបានផ្លាស់ប្តូរ ប៉ុន្តែកង្វះបទប្បញ្ញត្តិដែលកំណត់ចំនួនអនុរដ្ឋលេខាធិការបានធ្វើឲ្យមានការកើនឡើងនូវតួនាទីជាប្រចាំ។

ការវិភាគអំពីការវិភាជថវិកាក្នុងឆ្នាំ ២០២៣ និង ២០២៤ បង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃចំណាយលើលាភការ និង ប្រាក់បំណាច់នៃមន្ត្រីអំណាចសាធារណៈ។ គួរកត់សម្គាល់ថា ប្រាក់បំណាច់ សម្រាប់នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី (អនុគណនេយ្យ ៦៤០១៣) កើនឡើង ១៣៣% បើធៀបនឹងឆ្នាំ ២០២៣ ។ ប្រាក់បំណាច់សម្រាប់រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ កើនឡើង ២៣% ស្របពេលប្រាក់បំណាច់សម្រាប់ទីប្រឹក្សា និងជំនួយការបានកើនឡើង ១០% ។ នៅឆ្នាំ ២០២៤ ៧១% នៃថវិកាចំណាយលើប្រាក់បំណាច់មុខងារ (៦៤០១) ត្រូវបានវិភាគជាបីប្រភេទនេះ៖ ៣០% សម្រាប់រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ៣១% សម្រាប់ទីប្រឹក្សា និង ១០% សម្រាប់ជំនួយការ។

ឯកតា លានរៀល

| លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ | 2023 | | 2024 | | ប្រែប្រួលជា% |
|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | (2023-2024) |
| | 226,911.20 | | 252,018.80 | | 11% |
| ខុទ្ទកាល័យព្រះបរមរាជវាំង (64011) | 20,400.00 | 8.99% | 20,400.00 | 8.09% | 0% |
| ប្រាក់បំណាច់ប្រធាន អនុប្រធាន និងសមាជិកស្ថានប័នកំពូល (64012) | 43,670.40 | 19.25% | 43,648.40 | 17.32% | 0% |
| ប្រាក់បំណាច់ នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី (64013) | 216.00 | 0.10% | 504.00 | 0.20% | 133% |
| ប្រាក់បំណាច់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ (64014) | 62,154.60 | 27.39% | 76,614.60 | 30.40% | 23% |
| ប្រាក់បំណាច់អង្គទូត (64015) | 5,320.00 | 2.34% | 5,436.00 | 2.16% | 2% |
| លាភការទីប្រឹក្សា (64016) | 71,790.90 | 31.64% | 79,051.20 | 31.37% | 10% |
| លាភការអ្នកជំនួយការ (64018) | 23,359.30 | 10.29% | 26,364.60 | 10.46% | 13% |

ប្រភព: ចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងឆ្នាំ២០២៤ ដោយអគ្គនាយកដ្ឋានថវិកា

## XIV. ការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖

គិតដល់ឆ្នាំ២០២៤ ការវិភាជថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនឡើងជាបន្តបន្ទាប់ ដោយកើនឡើងពី ១៣% នៅឆ្នាំ២០២៣ ទៅ ប្រមាណ១៩% នៅឆ្នាំ២០២៤ ហើយរក្សាបានកម្រិត ១៩% នៅឆ្នាំ២០២៥។ការកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ ២០២៤ គឺដោយសារមានការផ្ទេរថវិកាអប់រំទៅរដ្ឋបាលស្រុក។ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិរួមបញ្ចូលការចំណាយសម្រាប់រដ្ឋបាលខេត្ត/រាជ

ធានី ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ហើយថវិការដ្ឋបាលស្រុកកើនឡើងពី ១,៦៥% នៃការចំណាយរដ្ឋនៅឆ្នាំ ២០២៣ ដល់ ៦% ក្នុងឆ្នាំ ២០២៤ និង ២០២៥។ ទោះបីជាយ៉ាងណា ថ្វីបើមាននិន្នាការកើនឡើងបែបនេះក្តី ចំណែកជាភាគរយនៃការវិភាជថវិកានៅតែទាបគួរឱ្យកត់សម្គាល់ បើធៀបនឹងការចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ ដែលមានចំនួនរហូតដល់ ៨១% ។ ភាពខុសគ្នានៃទំហំថវិកាដែលវិភាជ ជះឥទ្ធិពលលើសេចក្តីសម្រេចសំខាន់ៗផ្នែកគោលនយោបាយទៅលើកិច្ចប្រតិបត្តិការ ឬអនុវត្តថវិកា ដែលធ្វើឡើងដោយរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការណ៍នេះ គឺផ្ទុយពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលក្នុងការពង្រឹងសិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

គប្បីកត់សម្គាល់ថា រដ្ឋបាលឃុំ/សង្កាត់សរុបចំនួនប្រមាណ ១.៦៥២ ទទួលបានចំណែក ៣,៤%

ឯកតា លានរៀល

| សេចក្តីបរិយាយ | ឆ្នាំ2019 | | ឆ្នាំ2020 | | ឆ្នាំ2021 | | Year 2022 | |
|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| **ចំណាយថវិការដ្ឋ** | 27,164,996.00 | | 33,339,660.00 | | 32,009,742.00 | | 34,708,630.00 | |
| **ចំណាយថ្នាក់ជាតិ**<br>(ដក: ថវិកាឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ និងថវិកាប្រគល់មុខងារអប់រំ និងសុខាភិបាល) | 24,965,360.00 | 91.90 | 30,010,397.00 | 90.01 | 28,606,805.00 | 89.37 | 30,433,568.00 | 87.68 |
| **ចំណាយថ្នាក់ក្រោមជាតិ** | 2,199,636.00 | 8.10 | 3,329,263.00 | 9.99 | 3,402,937.00 | 10.63 | 4,275,062.00 | 12.32 |
| ការចំណាយរាជធានី/ខេត្តរួមបញ្ចូលការឧបត្ថម្ភរដ្ឋបាលរាជធានី/ខេត្ត | 1,476,946.00 | 5.44 | 2,278,691.00 | 6.83 | 2,203,579.00 | 6.88 | 2,859,652.00 | 8.24 |
| ការចំណាយក្រុង/ស្រុក | 198,890.00 | 0.73 | 247,228.00 | 0.74 | 489,810.00 | 1.53 | 568,053.00 | 1.64 |
| ការចំណាយរដ្ឋបាលឃុំ/សង្កាត់ | 523,800.00 | 1.93 | 803,317.00 | 2.41 | 709,548.00 | 2.22 | 847,357.00 | 2.44 |

| សេចក្តីបរិយាយ | Year 2023 | | Year 2024 | | Year 2025 | | ប្រែប្រួល 2024-2025 | |
|---|---|---|---|---|---|---|---|---|
| | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| **ចណាយថវការដ្ឋ** | 39,206,205.00 | | 37,110,403.60 | | 37,950,385.00 | | 839,981.40 | |
| **ចំណាយថ្នាក់ជាតិ**<br>(ដក: ថវិកាឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ និងថវិកាប្រគល់មុខងារអប់រំ និងសុខាភិបាល) | 34,147,892.60 | 87.10 | 30,141,245.30 | 81.22 | 30,756,721.10 | 81.04 | 615,475.80 | -0.18 |
| **ចំណាយថ្នាក់ក្រោមជាតិ** | 5,058,312.40 | 12.90 | 6,969,158.30 | 18.78 | 7,193,663.90 | 18.96 | 224,505.60 | 0.18 |
| ការចំណាយរាជធានី/ខេត្តរួមបញ្ចូលការឧបត្ថម្ភរដ្ឋបាលរាជធានី/ខេត្ត | 3,436,250.00 | 8.76 | 3,563,474.80 | 9.60 | 3,554,502.00 | 9.37 | -8972.8 | -0.24 |
| ការចំណាយក្រុង/ស្រុក | 647,139.40 | 1.65 | 2,255,284.50 | 6.08 | 2,341,519.90 | 6.17 | 86,235.40 | 0.09 |
| ការចំណាយរដ្ឋបាលឃុំ/សង្កាត់ | 974,923.00 | 2.49 | 1,150,399.00 | 3.10 | 1,297,642.00 | 3.42 | 147,243.00 | 0.32 |

ប្រភព៖ ច្បាប់ថវិកាជាតិឆ្នាំ២០១៩, ២០២០, ២០២១, ២០២២, ២០២៣, ២០២៤ និង ២០២៥

ហើយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួនប្រហែល ២០៤ ទទួលបាន ៦% ខណៈរដ្ឋបាលរាជធានី ខេត្ត ចំនួន ២៥ ទទួលបានប្រហែល ១០% នៃការចំណាយសរុបរបស់រដ្ឋ។ យោងតាមអនុសាសន៍ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ការចំណាយរបស់រដ្ឋាភិបាលថ្នាក់កណ្តាល ឬរដ្ឋបាលថ្នាក់ជាតិគប្បីត្រូវបានកាត់បន្ថយមកនៅត្រឹមប្រហែល ២៧%-៣២% នៃការចំណាយសរុបរបស់រដ្ឋ។ របាយការណ៍នេះសង្កត់ធ្ងន់ថា រដ្ឋបាលស្រុក និងក្រុង គប្បីជាចំណុចសំខាន់នៃកិច្ចខិតខំប្រឹងប្រែងធ្វើវិមជ្ឈការ ហើយថវិកាសម្រាប់រដ្ឋបាលទាំងនេះ គប្បីមានចំនួន ៣០%-៣៥% នៃការចំណាយសរុបរបស់រដ្ឋ។ រដ្ឋបាលរាជធានី/ខេត្ត ដែលដើរតួនាទីសំខាន់នៅក្នុងការសម្របសម្រួល និងការត្រួតពិនិត្យក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គប្បីកាត់បន្ថយថវិកាមកត្រឹមប្រហែលពី៥,៥% ទៅ ៣,០% នៃការ

ចំណាយរបស់រដ្ឋ[29]។ តាមអនុសាសន៍របស់ ADB យ៉ាងហោចណាស់ មួយភាគបីនៃការចំណាយសរុបរបស់រដ្ឋ គប្បីត្រូវវិភាជទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មតិយោបល់៖**

- រាជរដ្ឋាភិបាលគប្បីបង្កើនចំណែកនៃថវិកា ដែលត្រូវវិភាជទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបង្កើនទៅដល់ ៣០% នៃការចំណាយប្រចាំឆ្នាំរបស់រដ្ឋ ដែល១០% គប្បីត្រូវវិភាជសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំណែកឯ ១០% ទៀតគប្បីត្រូវវិភាជទៅដល់រដ្ឋបាលឃុំ/សង្កាត់។ ការវិភាជថវិកាបន្ថែម នេះនឹងផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ជាតិទាំងនេះនៅក្នុងការបំពេញភារកិច្ចជាកាតព្វកិច្ចរបស់ពួកគាត់ប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយភាពខ្វះខាត ក្នុងការចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល និងមុខងារថ្មីៗ។
- រាជរដ្ឋាភិបាលគប្បីតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាពនូវការអនុវត្តអនុក្រឹត្យលេខ ១៥២ និង១៥៣ ដែលបានណែនាំរដ្ឋបាលឃុំសង្កាត់ និងក្រុង ស្រុកខណ្ឌវិភាជថវិកាដល់កិច្ចការសង្គមកិច្ច ការពារធនធានធម្មជាតិ និងបរិស្ថាន ព្រមទាំងការសម្របខ្លួនទៅតាមការប្រែប្រួលអាកាសធាតុ។
- រាជរដ្ឋាភិបាលគប្បីពង្រឹងសមត្ថភាពរបស់មន្ត្រីក្នុងការគ្រប់គ្រង និងអនុវត្តថវិកាឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈកម្មវិធីកសាងសមត្ថភាពដែលឆ្លើយតបទៅនឹងតម្រូវការ។ កម្មវិធីទាំងនេះគប្បីបញ្ចូលវដ្តនៃការគ្រប់គ្រងថវិកា ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀនសូត្រ (MEL) រួមជាមួយនឹងសវនកម្មផ្ទៃក្នុង។
- រាជរដ្ឋាភិបាលគប្បីបង្កើត និងអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធសវនកម្មផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងពេលតំណាលគ្នានេះដែរ រដ្ឋាភិបាលគប្បីធានានូវការបំពេញមុខងារ តួនាទីត្រួតពិនិត្យពេញលេញ និងប្រកបដោយប្រសិទ្ធភាពទៅលើក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនៅក្នុងការពិនិត្យតាមដានវឌ្ឍនភាពនៃអនុវត្តថវិកា។
- រាជរដ្ឋាភិបាលគប្បីសកម្មក្នុងការលើកទឹកចិត្តការចូលរួមរបស់ប្រជាពលរដ្ឋ និងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការរៀបចំថវិកា ដើម្បីជំរុញភាពជាម្ចាស់របស់ប្រជាពលរដ្ឋទៅលើផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគាត់។

[29] Tariq H. Niazi, Deconcentration and Decentralization Reforms in Cambodia Recommendations for an Institutional Framework, Page 71, 2011, Asian Development Bank

## XV. រចនាសម្ព័ន្ធនៃឯកសារថវិកា៖

នៅពេលអង្គនីតិប្បញ្ញត្តិ និងព្រះមហាក្សត្រ អនុម័ត និងឡាយព្រះហស្តលេខាដាក់ឲ្យប្រើប្រាស់ច្បាប់ថវិកាប្រចាំឆ្នាំ អង្គនីតិប្រតិបត្តិទទួលខុសត្រូវលើការអនុវត្តថវិកា និងដាក់ជូនអង្គនីតិប្បញ្ញត្តិ ពោលគឺរដ្ឋសភានូវរបាយការណ៍គ្រប់ជ្រុងជ្រោយស្តីពីលទ្ធផលនៃការអនុវត្តថវិកា។ ជាលទ្ធផល នៅចុងបញ្ចប់នៃឆ្នាំសារពើពន្ធនីមួយៗ រដ្ឋាភិបាលត្រូវរៀបចំរបាយការណ៍ អំពីការអនុវត្តថវិកា និងបង្ហាញរបាយការណ៍នោះជូនរដ្ឋសភា នៅក្នុងទម្រង់ដែលអាចផ្ទៀងផ្ទាត់បានទៅតាមរចនាសម្ព័ន្ធនៃថវិកាដែលត្រូវបានអនុម័ត។ រចនាសម្ព័ន្ធដែលស្របគ្នា នឹងសម្រួលដល់ការពិនិត្យ និងការផ្ទៀងផ្ទាត់ទាំងស្រុងរបស់រដ្ឋសភា និងអ្នកពាក់ព័ន្ធទៅលើការអនុវត្តចំណូល និងចំណាយថវិកា។

បន្ថែមលើនេះ វាជាការចាំបាច់ក្នុងការផ្សាយព័ត៌មាន និងទិន្នន័យសំខាន់ៗក្នុងឯកសារថវិកាទាំងប្រាំបី នៅក្នុងរយៈពេលសមស្រប ដើម្បីទុកពេលគ្រប់គ្រាន់ឱ្យរដ្ឋសភា អ្នកពាក់ព័ន្ធ និងសាធារណជនពិនិត្យមើលព័ត៌មាន និងទិន្នន័យទាំងនោះប្រកបដោយអត្ថន័យ។ ឯកសារទាំងប្រាំបីនេះរួមមាន ប្រកាស ឬសារាចរណែនាំមុនពេលរៀបចំថវិកា សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំលម្អិត សេចក្តីសង្ខេបប្រតិបត្តិថវិកាប្រចាំឆ្នាំ ច្បាប់ថវិកាប្រចាំឆ្នាំ របាយការណ៍ការណ៍ការអនុវត្តថវិកាប្រចាំខែ ឬត្រីមាស របាយការណ៍ការអនុវត្តថវិកាប្រចាំឆមាស របាយការណ៍ការអនុវត្តថវិកាប្រចាំឆ្នាំ របាយការណ៍សវនកម្ម និងព័ត៌មានថវិការបស់ប្រជាពលរដ្ឋ។ ទោះបីជាបច្ចុប្បន្ន កម្ពុជាមានឯកសារទាំងនេះក្តី រចនាសម្ព័ន្ធ ឬគណនីថវិកាដែលប្រើប្រាស់ និងកត់ត្រាក្នុង ច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំខុសគ្នាពីរចនាសម្ព័ន្ធ ឬគណនីថវិកាក្នុងច្បាប់ថវិកាប្រចាំឆ្នាំ។ ភាពខុសគ្នានៃរចនាសម្ព័ន្ធរវាងច្បាប់ថវិកាប្រចាំឆ្នាំ និងច្បាប់ស្តីពីការទូទាត់ថវិការារាំងការផ្ទៀងផ្ទាត់ និងការប្រៀបធៀប និងធ្វើឲ្យមានភាពស្មុគស្មាញដល់ការវិភាគប្រកបដោយប្រសិទ្ធភាព។

**មតិយោបល់៖**

រាជរដ្ឋាភិបាល ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គប្បីពង្រឹងការយល់ដឹងជាសាធារណៈអំពីថវិកាសាធារណៈ និងតម្លាភាពនៃការអនុវត្តថវិកា ជាពិសេសបើកចំហរព័ត៌មានលទ្ធកម្មសាធារណៈ និងលើកកម្ពស់ការចូលរួម តាមរយៈការបង្កើតក្របខណ្ឌ និងទម្រង់ជាស្តង់ដាសម្រាប់ច្បាប់ទាំងពីរប្រភេទនេះ ដែលសម្របសម្រួលដល់ការផ្ទៀងផ្ទាត់ និងការពិនិត្យមើលថវិកាឡើងវិញ

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖ លោក ម៉ារ សុផល លេខាធិការនៃក្រុមការងារថវិកានៃអង្គការសង្គមស៊ីវិល និងប្រធានកម្មវិធីនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ទូរស័ព្ទ៖ ០១២ ៨៤៥ ០៩១ ឬ sophal@ngoforum.org.kh